# របាយការណ៍ស្តីពីដំណើរការ

# ការស្តាប់សម្លេងស្រ្តី
# ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
# ស្តីពីហិង្សាយេនឌ័រពេលមានជម្លោះ

២០១២

**ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា**

ភ្នំពេញ ខែធ្នូ ឆ្នាំ២០១២

រៀបរៀងដោយ ៖ ថេរ៉េសា ឌីឡាងហ្គីស

កែសម្រួលដោយ ៖ អែដវីដ ហ្គូក និង បេនី យ៉េ

ថតរូបដោយ ៖ ទីភ្នាក់ងារ ម៉េឡិន រ៉ូក

# មាតិកា


បុព្វកថា ..................................................................................................................................៣

សេចក្តីផ្តើម.................................................................................................................................. ៥

ដំណើរការនៃការស្តាប់សម្លេងស្ត្រី ..........................................................................................................៧

ក. សវនាការចំពោះមនសិការ ៖ សារអំពីសាមគ្គីភាពរបស់ស្ត្រីនៃប្រទេសហ្គោតាម៉ាឡា .............................. ៩

ខ. សក្ខីកម្មរបស់អ្នកជំនាញការ............................................................................................ ១០

១. សារពីគណៈវិនិច្ឆ័យតាមរយៈខ្សែអាត់វីដេអូ ....................................................................... ១០

២. សក្ខីកម្មរបស់អ្នកជំនាញការ ៖ ជម្លោះដែលទាក់ទងទៅនឹងហិង្សាយេនឌ័រលើស្ត្រី និងកុមារី ............ ១១

៣. សក្ខីកម្មរបស់អ្នកជំនាញការ ៖ អភិក្រមតាមរយៈប្រព័ន្ធយុត្តិធម៌ និង អភិក្រមមិនមែនតាមរយៈ ប្រព័ន្ធយុត្តិធម៌ចំពោះបញ្ហាយុត្តិធម៌យេនឌ័រ ......................................................................... ១២

៤. សក្ខីកម្មរបស់អ្នកជំនាញការ ៖ ស្ត្រី សន្តិភាព និងសន្តិសុខ ...................................................... ១៤

គ. ការផ្តល់សក្ខីកម្មដោយជនរងគ្រោះ និងសាក្សី ........................................................................ ១៦

១. កម្ពុជា ............................................................................................................................. ១៦

២. បង់ក្លាដេស ......................................................................................................................២០

៣. ទីម័រខាងកើត....................................................................................................................២៤

៤. នេប៉ាល់...........................................................................................................................២៨

សម្លេងពីអ្នកចូលរួម ....................................................................................................................៣១

សេចក្តីថ្លែងរបស់គណៈវិនិច្ឆ័យ ....................................................................................................... ៣៣

មេរៀនបទពិសោធន៍ ....................................................................................................................៣៥

សេចក្តីថ្លែងអំណរគុណ.................................................................................................................. ៤១

អ្នករៀបចំកម្មវិធី ........................................................................................................................៤៣

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ក ៖ របៀបវារៈកម្មវិធីការស្តាប់សម្លេងស្ត្រី ............ ៤៥
ឧបសម្ព័ន្ធ ខ ៖ សក្ខីកម្មលាយលក្ខណ៍អក្សររបស់ជនរងគ្រោះ និងសាក្សី ............ ៤៧
ឧបសម្ព័ន្ធ គ ៖ សេចក្ដីថ្លែងរបស់គណៈវិនិច្ឆ័យ ............ ៥៨
ឧបសម្ព័ន្ធ ឃ ៖ ប្រវត្តិរូបសង្ខេប ( ជីវប្រវត្តិ ) ............ ៧៩

# បុព្វកថា

អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រនៅពេលមានជម្លោះ គឺជាបញ្ហាមួយដែលកើតឡើងយ៉ាងទូលំទូលាយ ប៉ុន្តែកម្រត្រូវបានគេរាយការណ៍ណាស់។ ការប្រើប្រាស់តួនាទីយេនឌ័រដែលមានលក្ខណៈបែបប្រពៃណី និងពុំមានភាពស្មើភាពគ្នា ដើម្បីទាញប្រយោជន៍ពីភាពស្តាប់បង្គាប់របស់ស្ត្រី ជនល្មើសប្រព្រឹត្តសកម្មភាពទាំងនេះ ក្នុងលក្ខណៈជាផ្នែកមួយនៃយុទ្ធសាស្ត្រសង្គ្រាម សំដៅធ្វើឱ្យបាត់បង់ទំនុកចិត្តរបស់សហគមន៍ និងបង្កើនឋានៈរបស់ពួកគេ។ ក្នុងអំឡុងរបបខ្មែរក្រហម ការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ត្រូវបានគេហាមឃាត់ ហើយជនណាដែលមិនអនុវត្តតាមវិន័យនេះនឹងត្រូវប្រឈមទៅនឹងការសម្លាប់។ ដោយសារតែតថភាពដែលមនុស្សគ្រប់រូបបានដឹងឮគ្រប់គ្នានេះហើយ ទើបបទល្មើសផ្លូវភេទដែលត្រូវបានប្រព្រឹត្តក្រោមរបបខ្មែរក្រហមត្រូវបានគេមើលរំលង ឬប៉ាន់ប្រមាណមិនបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ។ ប៉ុន្តែតថភាពជាក់ស្តែងដ៏ក្រៀមក្រំ គឺកម្មាភិបាលខ្មែរក្រហមរមែងតែងបានប្រព្រឹត្តបទល្មើសមួយចំនួនធំដែលទាក់ទងទៅនឹងហិង្សាផ្លូវភេទដោយពុំមានការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្មអ្វីឡើយ។ ការពិតជាក់ស្តែងដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តក្រោមរូបភាពនៃនិទណ្ឌភាពទាំងស្រុងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃវិធីសាស្ត្រក្រៅប្រព័ន្ធតុលាការក្នុងការផ្តល់នូវភាពយុត្តិធម៌។ ព្រឹត្តិការណ៍មួយចំនួន ដូចជាការស្តាប់សម្លេងស្ត្រីផ្តល់ឱ្យជនរងគ្រោះនូវឱកាសមួយដើម្បីប្រាប់អំពីរឿងរ៉ាវរបស់ពួកគេ និងជួយបង្កើតឱ្យមាននូវកំណត់ត្រាប្រវត្តិសាស្ត្រ មួយដ៏ត្រឹមត្រូវអំពីបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលមានជម្លោះ។

នៅពេលដែលការស្តាប់សម្លេងស្ត្រីលើកដំបូង (២០១១) ត្រូវបានប្រារព្ធធ្វើឡើង គេមានមន្ទិលមួយជាខ្លាំងអាស្រ័យដោយគេមិនដឹងថា តើជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទមានឆន្ទៈក្នុងការនិយាយអំពីបទពិសោធន៍របស់ពួកគេដែរឬទេ? ប៉ុន្តែអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺមានស្ត្រីក្លាហានចំនួន៥រូប បានមកនិយាយប្រាប់អំពីរឿងរ៉ាវរបស់ពួកគេ។ ផ្អែកលើជោគជ័យកាលពីឆ្នាំកន្លងមកចំពោះការងារនេះ យើងបានពង្រីកវិសាលភាពនៃការស្តាប់សម្លេងស្ត្រីនៅក្នុងឆ្នាំនេះ ដើម្បីធ្វើការរាប់បញ្ចូលជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ក្នុងអំឡុងពេលមានជម្លោះពីប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការពង្រីកបែបនេះ នឹងអនុញ្ញាតឱ្យមាននូវការសិក្សាប្រៀបធៀបមួយដែលមានសារៈប្រយោជន៍ពុំមែនចំពោះតែអ្នកពាក់ព័ន្ធផ្នែកច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានសារៈប្រយោជន៍ចំពោះជនរងគ្រោះដែលនឹងមើលឃើញថា ពួកគេពុំមែននៅតែម្នាក់ឯងឡើយ។

ដើម្បីបញ្ចប់ហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រមិនត្រឹមតែនៅក្នុងតំបន់ ប៉ុន្តែទូទាំងសកល យើងត្រូវទម្លាយភាពស្ងៀមស្ងាត់ទាក់ទងទៅនឹងហិង្សាផ្លូវភេទដែលបានកើតឡើងក្នុងអំឡុងពេលនៃជម្លោះ និងបញ្ហានិទណ្ឌភាពដែលបានកើតឡើង។ ជនរងគ្រោះដែលបាននិយាយនៅឯវេទិកាស្តាប់សម្លេងស្ត្រីឆ្នាំ២០១២ បានជួយទម្លាយភាពស្ងៀមស្ងាត់នេះ ហើយពួកគេបានធ្វើយ៉ាងដូច្នេះ បើទោះបីជាពួកគេស្ថិតនៅក្នុងអំឡុងឆ្នាំដែលពោរពេញទៅដោយការរើសអើង និងការមាក់ងាយដែលពួកគេបានជួបប្រទះពីសហគមន៍ គ្រួសារ និងដៃគូរបស់ពួកគេក៏ដោយ។ សេចក្តីក្លាហានរបស់

ពួកគេបានដាក់បញ្ចូលបញ្ហាហិង្សាផ្លូវភេទនៅពេលមានជម្លោះទៅក្នុងរបៀបវារៈជាតិ និងអន្តរជាតិ ហើយយើងសូមថ្លែងអំណរគុណ និងសូមសម្តែងនូវការគោរពចំពោះអ្នកទាំងអស់នោះ៕

**សុក សំអឿន**



**នាយកប្រតិបត្តិ**
**ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា**

# សេចក្ដីផ្ដើម

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ វេទិកាក្រៅប្រព័ន្ធតុលាការស្ដីពីការប្រាប់អំពីការពិត ត្រូវបានប្រារព្ធធ្វើឡើងជុំវិញពិភពលោក។ ភាគច្រើនវេទិកាទាំងនេះត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងភាពអសមត្ថភាព ឬការដែលយន្តការតុលាការក្នុងប្រព័ន្ធពុំមានឆន្ទៈក្នុងការផ្ដល់នូវភាពយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទល្មើស យេនឌ័រនៅពេលមានជម្លោះប្រដាប់អាវុធ ឬស្ថិតក្រោមរបបផ្ដាច់ការ។ នៅប្រទេសកម្ពុជា ខែធ្នូ ឆ្នាំ២០១១ គម្រោងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ក្រោមកិច្ចសហការជាមួយជំនាញការជាតិ និងអន្តរជាតិ បានរៀបចំប្រារព្ធធ្វើឡើងនូវវេទិកាលើកដំបូងស្ដីពីការប្រាប់ការពិតអំពីហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម "សម្លេងពិតរបស់ស្ត្រីអំពីហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម" (២០១១)។ វេទិកាស្ដាប់សម្លេងនេះមានគោលបំណងផ្ដល់ឱកាសសម្រាប់ជនរងគ្រោះ និងសាក្សី ដើម្បីឱ្យពួកគេទម្លាយភាពស្ងៀមស្ងាត់របស់ពួកគេរាប់ទសវត្សរ៍មកហើយ អំពីបទល្មើសផ្លូវភេទ និងលើកកម្ពស់ឱ្យមានការទទួលស្គាល់ជាសាធារណៈអំពីធាតុផ្សំជាក់លាក់នៃអំពើហិង្សាគួរឱ្យរន្ធត់ដែលបានកើតឡើងជាទូទៅនេះ។ គេបានធ្វើយ៉ាងដូច្នេះ ដើម្បីឆ្លើយតបទៅនឹងតថភាពជាក់ស្ដែងថា ការរំលោភបំពានផ្លូវភេទទាំងស្រុងដែលបានកើតឡើងក្រោមរបបប្រល័យពូជសាសន៍ នឹងមិនត្រូវបានយកមកធ្វើការវិនិច្ឆ័យដោយសវនាការផ្លូវការឡើយ។

ព្រឹត្តិការណ៍ឆ្នាំ២០១១ បានបង្កឱ្យមាននូវផលប៉ះពាល់ដ៏ជ្រាលជ្រៅមួយទៅលើអ្នកផ្ដល់សក្ខីកម្ម និងជាពិសេសគឺជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ក្នុងការឆ្លុះបញ្ចាំងអំពីតួនាទីនៃហិង្សាផ្លូវភេទក្នុងលក្ខណៈជាផ្នែកមួយនៃអំពើហិង្សាទាំងមូលដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាក្នុងរបបប្រល័យពូជសាសន៍ ដែលជម្រុញឱ្យមាននូវកិច្ចសន្ទនា និងការពិភាក្សានៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ។ សំខាន់ជាងនេះទៀត ព្រឹត្តិការណ៍នេះ បានបង្ហាញឱ្យជនរងគ្រោះបានដឹងថា ពួកគេពុំមែនឯកោ ឬនៅតែម្នាក់ឯងឡើយ ប៉ុន្តែក៏មានអ្នកដទៃទៀត ដែលកំពុងខិតខំស្វែងរកការដោះស្រាយ និងមធ្យោបាយតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ផងដែរសម្រាប់បទល្មើសទាំងនេះ។

ដោយមើលឃើញអំពីសារៈសំខាន់ក្នុងការបញ្ចូលបទពិសោធន៍របស់ស្ត្រី ទៅក្នុងវេទិកាស្ដីពីការប្រាប់អំពីការពិត ក្រោយពេលជម្លោះនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀតក្នុងតំបន់អាស៊ី វេទិកាស្ដីពីការស្ដាប់សម្លេងស្ត្រីលើកទី២ ដែលត្រូវបានប្រារព្ធធ្វើឡើងក្នុងប្រទេសកម្ពុជា បានពង្រីកវិសាលភាពដើម្បីបញ្ចូលសក្ខីកម្មដទៃទៀតពីក្នុងតំបន់។ ការស្ដាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកស្ដីពីហិង្សាយេនឌ័រពេលមានជម្លោះ ឆ្នាំ២០១២ បានប្រមូលស្ត្រីចំនួន១០រូប មកពីប្រទេសកម្ពុជា បង់ក្លាដេស ទីម័រខាងកើត និងនេប៉ាល់ ចាប់ពីអាយុ ២៣ឆ្នាំ រហូតដល់ ៨០ឆ្នាំ ដើម្បីធ្វើការចែករំលែកបទពិសោធន៍របស់ពួកគេជាសាធារណៈអំពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រនៅពេលមានជម្លោះក្នុងប្រទេសរបស់ពួកគេ។ មានអ្នកចូលរួមប្រមាណ២៥០នាក់ ដែលបានចូលរួមនៅក្នុងថ្ងៃនីមួយៗដើម្បីធ្វើជាសាក្សីចំពោះការផ្ដល់សក្ខីកម្មដ៏ខ្លាំងក្លាទាំងនេះ។

សេចក្ដីថ្លែងចុងក្រោយចំពោះការស្ដាប់សម្លេងស្ត្រីឆ្នាំ២០១២ របស់ក្រុមអ្នកជំនាញការបានសង្កត់ធ្ងន់ថា គេមិនអាចនិយាយពន្លើសឱ្យហួសប្រមាណអំពីតម្លៃនៃការស្ដាប់អំពីការប្រាប់ការពិតបានឡើយ។ បើទោះបីជាសវនាការ ផ្លូវការ គណៈកម្មការទទួលបន្ទុកការពិត និងការសម្របសម្រួល និងរដ្ឋាភិបាលបណ្ដោះអាសន្ន កំពុងត្រូវបានបង្កើតឡើងដើម្បីផ្ដល់យុត្តិធម៌ជូនដល់ជនរងគ្រោះ និងផ្ដន្ទាទោសជនល្មើសក៏ដោយ ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទតម្រូវឃើញ

បទល្មើសដែលបានកើតឡើងចំពោះពួកគេ ត្រូវបានយកមកដោះស្រាយខ្លាំងណាស់ ហើយពួកគេបានបន្តធ្វើការសង្កត់ធ្ងន់អំពីសេចក្តីត្រូវការឱ្យមាននូវជម្រើសដោយឡែកសម្រាប់រៀបរាប់ប្រាប់អំពីដំណើររឿងរបស់ស្ត្រី។ វេទិកាមួយចំនួនដូចជា ការស្តាប់សម្លេងស្ត្រីឆ្នាំ២០១២ បានបង្កលក្ខណៈឱ្យជនរងគ្រោះអាចប្រាប់អំពីដំណើររឿងទាំងមូលនៃបទពិសោធន៍របស់ពួកគេដែលទាក់ទងទៅនឹងហិង្សាផ្លូវភេទនៅពេលមានជម្លោះ និងតើដំណើររឿងទាំងនោះស្របទៅនឹងបរិបទនៃការរំលោភបំពានដទៃទៀត ដែលជាចំណែកមួយនៃជម្លោះប្រដាប់អាវុធដូចម្តេចដែរ ព្រមទាំងផលប៉ះពាល់នៃបទល្មើសផ្លូវភេទដែលបន្តកើតឡើងទៅលើជីវិតរស់នៅរបស់ជនរងគ្រោះ និងកូនរបស់ពួកគេក្រោយពេលដែលជម្លោះប្រដាប់អាវុធត្រូវបានបញ្ចប់ជាផ្លូវការ។



ស្ត្រីដែលបានធ្វើការចែករំលែកសក្ខីកម្មរបស់ពួកគេនៅក្នុងរបាយការណ៍នេះ បានបង្ហាញអំពីភាពក្លាហានក្នុងការបដិសេធន៍មិនព្រមរក្សាភាពស្ងៀមស្ងាត់នៅចំពោះមុខភាពអយុត្តិធម៌។ នៅពេលឡើងមកនិយាយជាសាធារណៈ យើងទទួលស្គាល់ថា ពួកគេមានសេចក្តីក្លាហានក្នុងការពុះពារប្រាប់អំពីហេតុការណ៍ដ៏គួរឱ្យតក់ស្លុត និងបានបំផ្លិចបំផ្លាញទៅលើខ្លួនរបស់ពួកគេ។ នៅក្នុងសកម្មភាពនេះ ពួកគេបានបង្ហាញអំពីកម្លាំងដ៏មហិមារបស់ពួកគេ ក្នុងនាមជាជនរងគ្រោះដ៏រឹងមាំ និងក្នុងនាមជាមេដឹកនាំដែលប្រកបដោយគំនិតច្នៃប្រឌិត។ វាគឺជាកិត្តិយសដែលបានថតសម្លេងរបស់ពួកគេ និងសម្លេងអ្នកគាំទ្ររបស់ពួកគេជារួម ក្នុងលក្ខណៈជាផ្នែកមួយនៃការស្តាប់សម្លេងស្ត្រីតំបន់អាស៊ីប៉ាស៊ីហ្វិក ឆ្នាំ២០១២ ដោយបានធ្វើឱ្យកាន់តែមានភាពច្បាស់លាស់ចំពោះការអំពាវនាវសំដៅបញ្ចប់អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រ ព្រមទាំងសម្រេចឱ្យបាននូវយុត្តិធម៌យេនឌ័រសម្រាប់បទល្មើសទាំងនេះ។

*"សូមទទួលការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ បណ្ឌិត ថេរេសា ឌីឡាងហ្គីស*
*អ្នកធ្វើរបាយការណ៍ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១២"។*

# ដំណើរការនៃការស្តាប់សម្លេងស្ត្រី




*"យើងខ្ញុំដឹងអំពីអារម្មណ៍ និងរសជាតិនៃការឈឺចាប់របស់អ្នក..... តំបន់ និងពិភពលោកទាំងមូលត្រូវការស្តាប់អំពីអ្វីដែលបានកើតឡើង និងភាពសោកសៅដែលបន្តនៅមាន"។*

**ឯកឧត្តម ឱម យិនទៀង** ប្រធានគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាននទទួលបន្ទុកសិទ្ធិមនុស្ស ប្រទេសកម្ពុជានៅថ្ងៃទី១០ និង ១១ ខែតុលា ឆ្នាំ២០១២ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ក្រោមភាពជាដៃគូជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (TPO) និងអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានរៀបចំការស្តាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាយេនឌ័រពេលមានជម្លោះនៅក្នុងរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

វេទិកានេះត្រូវបានបើកទូលាយចំពោះសាធារណជន និងមានការចូលរួមពីតំណាងរាជរដ្ឋាភិបាលកម្ពុជា អគ្គ-លេខាធិការអាស៊ាន សមាជិកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដើមបណ្តឹងរដ្ឋប្បវេណីនៃ អ.វ.ត.ក មន្ត្រីជាន់ខ្ពស់ និងបុគ្គលិកអង្គការសហប្រជាជាតិ ភ្ញៀវកិត្តិយសមកពីតំបន់អាស៊ាន អង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាតិ និងអន្តរជាតិ សាកលវិទ្យាល័យ មហាវិទ្យាល័យ និងនិស្សិត។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានផ្តល់ឱ្យស្ត្រីដែលជាជនរងគ្រោះ និងសាក្សីនៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រនៅពេលមានជម្លោះ (ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ) នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនូវវេទិកាមួយដើម្បីទន្លាយភាពស្ងៀមស្ងាត់ ជុំវិញបញ្ហាការរំលោភបំពានទៅលើស្ត្រីនៅក្នុងស្ថានភាពមានជម្លោះ និងដើម្បីទាមទារយុត្តិធម៌។ សក្ខីកម្មត្រូវបានផ្តល់ជូនដោយជនរងគ្រោះ និងសាក្សីនៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃជម្លោះចំនួន៤ ដែលបានកើតឡើងនៅក្នុងតំបន់ ៖ កម្ពុជា (១៩៧៥-១៩៧៩) បង់ក្លាដេស (១៩៧១) នេប៉ាល់ (១៩៩៦-២០០៦) និងទីម័រខាងកើត (១៩៧៤-១៩៩៩)។ វេទិកានេះត្រូវបានសហការសម្រប

សម្រួលដោយ ប៉ុក បញ្ញាវិចិត្រ (កម្ពុជា) និងកាស៊ូមិ ណាកាហ្គាវ៉ា (ជប៉ុន)។

ក្រុមអ្នកជំនាញការ និងអ្នកគាំទ្រមួយក្រុមដែលរួមមាន លី វេជ្ជតា (ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា)[១] វ៉ាហ៊ីដា ណៃណា (ជំនាញការយេនឌ័រ និងសិទ្ធិមនុស្ស ឥណ្ឌា) ឌីអាណេ អូតូ (សាស្ត្រាចារ្យច្បាប់ អូស្ត្រាលី) និងអ្យូរ៉ា ចាវ៉ាត់ ឌីឌីអូស (តំណាងហ្វីលីពីននៃគណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងកិច្ចការពារសិទ្ធិស្ត្រី និងកុមារ (ACWC)។ នៅពេលបញ្ចប់ការស្តាប់សម្លេងស្ត្រី ក្រុមគណៈវិនិច្ឆ័យបានផ្តល់អនុសាសន៍មួយចំនួនជូនដល់រដ្ឋាភិបាលនៃប្រទេសនីមួយៗ ក្នុងចំណោមប្រទេសទាំង៤ ស្ថាប័នយុត្តិធម៌ជាតិ និងអន្តរជាតិដែលមាននៅក្នុងប្រទេសទាំងនោះ សហគមន៍អន្តរជាតិរាប់បញ្ចូលទាំងអង្គការសហប្រជាជាតិ និងសង្គមស៊ីវិលព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល។

ក្នុងអំឡុងពេលនៃការស្តាប់សម្លេងស្ត្រី សក្ខីកម្មរបស់ជនរងគ្រោះបានទទួលការកោតសរសើរពីគណៈវិនិច្ឆ័យនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក។ វេទិកានេះ បានចាប់ផ្តើមជាមួយនឹងសុន្ទរកថាតាមរយៈខ្សែអាត់វីដេអូមួយដែលធ្វើឡើងដោយ ហៃរ្យណាប់ បង់ហ្គូរ៉ា ដែលជាតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកហិង្សាផ្លូវភេទនៅពេលមានជម្លោះ។ គណៈវិនិច្ឆ័យអន្តរជាតិបានធ្វើបទបង្ហាញអំពីបញ្ហាយេនឌ័រ ច្បាប់អន្តរជាតិ យុត្តិធម៌អន្តរកាល និងស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងលក្ខណៈជាក្របខ័ណ្ឌគតិយុត្តិ និងក្របខ័ណ្ឌបទដ្ឋានសម្រាប់ដោះស្រាយបញ្ហាហិង្សាផ្លូវភេទ ព្រមទាំងការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនៅក្នុងដំណើរការសន្តិភាព និងសន្តិសុខ។ វេទិកានេះក៏បានបញ្ចូលនូវសារមួយអំពីសាមគ្គីភាពពីអ្នករៀបចំកម្មវិធីជាស្ត្រីរបស់សវនាការចំពោះមនសិការនៃប្រទេសហ្គោតាម៉ាឡា "សម្ព័ន្ធស្ត្រីទម្លាយភាពស្ងៀមស្ងាត់" និងពីអ្នកគាំទ្រសិទ្ធិមនុស្សសម្រាប់ស្ត្រីជនជាតិដើមភាគតិច និងជនរងគ្រោះនៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះក្នុងប្រទេសហ្គោតាម៉ាឡា ដែលមានឈ្មោះថា ម៉ូនីកា ភីនហ្សូន (អ្នកជំនាញការផ្នែកចិត្តសង្គមនៃការសិក្សាសហគមន៍ និងសកម្មភាពផ្នែកចិត្តសាស្ត្រ (ECAP) ហ្គោតាម៉ាឡា)។ តាងនាមឱ្យអ្នកចូលរួមគ្រប់រូប ក្រុមគណៈវិនិច្ឆ័យបានសម្តែងអំពីសាមគ្គីភាពចំពោះជនរងគ្រោះជាស្ត្រីនៅក្នុងប្រទេស ហ្គោតាម៉ាឡា សំដៅគាំទ្រដល់ការទាមទារយុត្តិធម៌របស់ពួកគេ។

**លោកជំទាវ ហោ ម៉ាលីន** (អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារីនៃរាជរដ្ឋាភិបាលកម្ពុជា) បានផ្តល់ចំណាប់អារម្មណ៍បើកកម្មវិធីនៅក្នុងវេទិកាស្តាប់សម្លេងស្ត្រី ដោយលោកជំទាវបានបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយអំពើហិង្សាផ្លូវភេទ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារឱ្យបានត្រឹមឆ្នាំ២០១៥ ក្នុងប្រទេសកម្ពុជា ព្រមទាំងទទួលស្គាល់ការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះ និងសាក្សីដែលបានអញ្ជើញមកពីបណ្តាប្រទេសនានានៅក្នុងតំបន់ដើម្បីចូលរួមនៅក្នុងវេទិកានេះ។ ចំណាប់អារម្មណ៍បិទកម្មវិធីត្រូវបានថ្លែងដោយ **ឯកឧត្តម ឱម យិនទៀង** (ប្រធានគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា) ដោយ ឯកឧត្តម បានថ្លែងអំណរគុណចំពោះអ្នកផ្តល់សក្ខីកម្មដែលអញ្ជើញមកពីប្រទេសទាំង៤ ចំពោះការចែករំលែករឿងរ៉ាវឈឺចាប់របស់ពួកគេ។

(១) លោកស្រី លី វេជ្ជតា មិនអាចចូលរួមកម្មវិធីសម្លេងនេះបានដោយសារបញ្ហាសុខភាព ប៉ុន្តែនៅតែបន្តទំនាក់ទំនងសម្រាប់ការវិវត្តន៍របស់គណៈវិនិច្ឆ័យ។

**លោក សុខ សំអឿន** នាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានថ្លែងនូវពាក្យពេចន៍ចុងក្រោយដែលញ៉ាំងឱ្យមានការស្ងឹងស្ងាធ៍មួយភ្លែត សម្រាប់អ្នកផ្តល់សក្ខីកម្មមួយរូបដែលបានចូលរួមនៅក្នុងវេទិកាកាលពីឆ្នាំមុន និងបានលាចាកលោកនេះទៅ ហើយលោកបានកោតសរសើរចំពោះអ្នកផ្តល់សក្ខីកម្មសម្រាប់ភាពក្លាហានរបស់ពួកគេ និងថ្លែងអំណរគុណចំពោះអ្នកចូលរួមដែលបាននៅធ្វើជាសាក្សី។

## ក. សវនាការចំពោះមនសិការ ៖ សារអំពីសាមគ្គីភាពរបស់ស្ត្រីនៃប្រទេសហ្គាតាម៉ាឡា

**ម៉ូនីកា ភីនហ្សូន** ដែលជាអ្នកចិត្តសាស្ត្រ សាស្ត្រាចារ្យ និងអ្នកគាំទ្រសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិច បានបង្ហាញសារមួយអំពីសាមគ្គីភាពពីប្រជាជនហ្គាតាម៉ាឡា "សម្ព័ន្ធស្ត្រីទម្លាយភាពស្ងៀមស្ងាត់"។ សម្ព័ន្ធនេះ រួមមាន ECAP, ការរួបរួមជាតិ - ស្ត្រីហ្គាតាម៉ាឡា (UNAMG) និង ស្ត្រីផ្លាស់ប្តូរពិភពលោក (MPM)។

តុលាការមនសិការនិមិត្តរូបមួយ ត្រូវបានរៀបចំឡើងនៅក្នុងខែមីនា ឆ្នាំ២០១០ ដើម្បីផ្តោតយកចិត្តទុកដាក់ទៅលើភាពអយុត្តិធម៌នៅក្នុងសង្គម ដែលទាក់ទងទៅនឹងជម្លោះ។ នៅក្នុងវេទិកានេះ និងវេទិកាដទៃទៀត ស្ត្រី ជនជាតិដើមភាគតិចបានចេញមុខដើម្បីនិយាយអំពីបទពិសោធន៍របស់ពួកគេ ក្រោយរយៈពេល២៨ឆ្នាំ នៃភាពស្ងៀមស្ងាត់ដែលពួកគេធ្លាប់ទទួលរងនូវអំពើហិង្សារយៈពេល៣៦ឆ្នាំ នៃជម្លោះនៅក្នុងប្រទេសរបស់ពួកគេ (បច្ចុប្បន្ន ពួកគេភាគ





ច្រើនស្ថិតនៅក្នុងវ័យ៨០ឆ្នាំ)។ លោកស្រី ភីនហ្សូន បានគូសបញ្ជាក់អំពីស្ថានភាពដែលស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជា និងប្រទេសដទៃទៀត ព្រមទាំងផលប៉ះពាល់ធ្ងន់ធ្ងរទៅលើជនរងគ្រោះដែលរួមមានដូចជា ការរំខានចំពោះផែនការជីវិតរស់នៅ ការពន្យារពេល ឬការផ្លាស់ប្តូរចំពោះការកាន់មរណទុក្ខ PTSD ភាពស្ងៀមស្ងាត់ ភាពអស់សង្ឃឹម ភាពរន្ធត់ ភាពរឹងរ៉េ ការភ័យខ្លាច ភាពក្រីក្រធ្ងន់ធ្ងរ គ្មានសិទ្ធិទទួលបានការពិត ឬអនុស្សាវរីយ៍នានា និងការផ្តាច់ខ្លួនចេញពីសង្គម។ ស្ត្រីដែលបានធ្វើសេចក្តីថ្លែងជុំវិញពិភពលោក ស្វែងរកយុត្តិធម៌ដើម្បីបញ្ចប់និទណ្ឌភាព និងបង្កើតឱ្យមាននូវនិមិត្តរូបនៃភាពយុត្តិធម៌។

***"ខ្ញុំសូមនាំមកនូវសារមួយ ជូនអ្នកទាំងអស់គ្នាដែលជាស្ត្រីនៃប្រទេសកម្ពុជា នេប៉ាល់ បង់ក្លាដេស។ ស្ត្រីនៃប្រទេសហ្គោតាម៉ាឡា ស្ថិតនៅជាមួយអ្នកទាំងអស់គ្នា ព្រោះអ្វីដែលបានកើតឡើងចំពោះស្ត្រីម្នាក់ គឺកើតឡើងចំពោះស្ត្រីគ្រប់រូប។ យើងដឹងថា អ្នកនិយាយអំពីការពិត ហើយយើងសូមនិយាយថា សម្រាប់ជនរងគ្រោះ គឺពុំមានការអៀនខ្មាស និងពុំមានការខុសឆ្គងអ្វីទៀតឡើយ។ យើងនឹងផ្តោតការអៀនខ្មាស និងការបន្ទោសទៅលើអ្នកដែលទទួលខុសត្រូវ។ យើងសូមលើកទឹកចិត្តឱ្យអ្នកស្វែងរកយុត្តិធម៌ បើទោះបីជាវាមើលទៅហាក់បីដូចជាមិនអាចទៅរួចក៏ដោយ និងសូមចងចាំថា យើងគឺជាសម្ព័ន្ធមិត្តរបស់អ្នក"*** ។



## ២. សក្ខីកម្មរបស់អ្នកជំនាញការ

### ១. សារពីគណៈវិនិច្ឆ័យតាមរយៈខ្សែអាត់វីដេអូ

*ហ្សៃណាប់ បង់ហ្គូរ៉ា តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកហិង្សាផ្លូវភេទនៅពេលមានជម្លោះ*

***"យើងត្រូវធានាថា ពិភពលោកដឹងអំពីភាពគួរឱ្យរន្ធត់នៃហិង្សាផ្លូវភេទ..... យើងបានមើលឃើញអំពីផលប៉ះពាល់នៃហិង្សាយេនឌ័រ ដែលបង្កការបំផ្លិចបំផ្លាញនៅក្នុងទ្វីបអឺរ៉ុប អាហ្វ្រិក អាស៊ី និងអាមេរិក។ ហិង្សាផ្លូវភេទ គឺជាសោកនាដកម្មសកល ហើយអ្នកទាំងអស់ គ្នាដែលកំពុងផ្តល់សក្ខីកម្មនៅថ្ងៃនេះ ពីតំបន់អាស៊ីប៉ាស៊ីហ្វិក តំណាងឱ្យស្ត្រីរាប់ពាន់នាក់ដែលបន្តឈឺចាប់នៅក្នុងភាពអៀនខ្មាស និងភាពស្ងៀមស្ងាត់"***។

**ហ្សៃណាប់ បង់ហ្គូរ៉ា** តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកហិង្សាផ្លូវភេទនៅពេលមានជម្លោះ

**ហ្សៃណាប់ បង់ហ្គូរ៉ា** ដែលជាគណៈវិនិច្ឆ័យកិត្តិយស និងជាតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកហិង្សាផ្លូវភេទនៅពេលមានជម្លោះ បានចូលរួមតាមរយៈសារវីដេអូ។ លោកស្រី បានកោតសរសើរចំពោះការស្តាប់សម្លេងស្ត្រីតំបន់អាស៊ីប៉ាស៊ីហ្វិក ថាជាមធ្យោបាយក្នុងការផ្តល់នូវវេទិកាមួយសម្រាប់ស្ត្រី ដើម្បីចែករំលែករឿងរ៉ាវរបស់ពួកគេអំពីហិង្សាផ្លូវភេទនៅពេលមានជម្លោះ។ បើទោះបីជាជម្លោះបានបញ្ចប់អស់រយៈពេលរាប់ទសវត្សរ៍កន្លងមកហើយក៏ដោយ ស្ត្រីដែលបានមកឡើងនិយាយអំពីរឿងរ៉ាវរបស់ពួកគេជួយធានាថា បទល្មើសផ្លូវភេទគឺជាចំណែកមួយនៃកំណត់ហេតុប្រវត្តិសាស្ត្រ និងកំណត់ហេតុគតិយុត្តិជាផ្លូវការនៃជម្លោះ។ និទណ្ឌភាពត្រូវតែបញ្ចប់

ហើយជនល្មើសត្រូវដឹងថា រាល់ធនធានទាំងអស់នៃសហគមន៍អន្តរជាតិ នឹងត្រូវយកមកប្រើប្រាស់ដើម្បីធ្វើការចាប់ខ្លួន និងចោទប្រកាន់ចំពោះបទល្មើសទាំងនោះទៅតាមច្បាប់ជាអតិបរមា។ ជាញឹកញាប់ ស្ត្រីរមែងតែងទទួលរងការបដិសេធន៍ចំពោះយុត្តិធម៌របស់ពួកគេពីប្រព័ន្ធមួយដែលមានកាតព្វកិច្ចក្នុងការបង្ការហិង្សាយេនឌ័រ និងការពារជនរងគ្រោះ។ ការខ្មាសអៀន និងការមាក់ងាយទៅលើជនរងគ្រោះ ត្រូវតែបង្វែរទៅកាន់រដ្ឋាភិបាល និងជនល្មើសវិញ។ យើងត្រូវតែច្បាស់ក្នុងចិត្តថា ស្ត្រីបានទទួលរងការបដិសេធន៍ចំពោះយុត្តិធម៌របស់ពួកគេអស់រយៈពេលជាយូរណាស់មកហើយ។ លោកស្រី បង់ហ្គូរ៉ា បានថ្លែងអំណរគុណ និងកោតសរសើរដល់អ្នកផ្តល់សក្ខីកម្មចំពោះភាពក្លាហានរបស់ពួកគេ ការទាមទារយុត្តិធម៌របស់ពួកគេ និងតួនាទីរបស់ពួកគេក្នុងការបញ្ចប់និទណ្ឌភាព។

## ២. សក្ខីកម្មរបស់អ្នកជំនាញការ ៖ ជម្លោះដែលទាក់ទងទៅនឹងហិង្សាយេនឌ័រលើស្ត្រី និងកុមារី

*ស៊ីលគី ស្ទូដហ្សីនស្គី មេធាវីអន្តរជាតិ សម្រាប់ភាគីស៊ីវិលនៅចំពោះមុខ អ.វ.ត.ក និងជាមេធាវីនៅទីក្រុងប៊ែកឡាំង ប្រទេសអាល្លឺម៉ង់*



**លោកស្រី ស្ទូដហ្សីនស្គី** បានបង្ហាញអំពីនិយមន័យ មូលហេតុ ឫសគល់ និងទម្រង់នៃហិង្សាផ្លូវភេទនៅពេលមានជម្លោះ ដោយលោកស្រីបានគូសបញ្ជាក់ចំពោះពាក្យថា "ហិង្សាផ្លូវភេទ" ក្នុងលក្ខណៈជាវិធីមួយដើម្បីធ្វើការផ្តោតឱ្យបានប្រសើរបំផុតទៅលើទិដ្ឋភាពផ្លូវភេទនៃប្រភេទបទល្មើសទាំងនេះ។ មូលហេតុ ឫសគល់នៃហិង្សាផ្លូវភេទមានទំនាក់ទំនងជាមូលដ្ឋានទៅនឹងជម្លោះប្រដាប់អាវុធ ហើយហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រត្រូវកំណត់និយមន័យឱ្យបានទូលំទូលាយ ដើម្បីឱ្យមានសន្តិភាព និងយុត្តិធម៌ប្រកបដោយនិរន្តរភាព។ មូលហេតុឫសគល់ចម្បងមួយនៃហិង្សាយេនឌ័រ គឺជាការបន្តមាននូវវិសមភាពអំណាចយេនឌ័រ និងឋានៈរបស់ស្ត្រីនៅក្នុងសង្គមដែលទាបជាងបុរស។ ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ រំលោភបំពានទៅលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ស្ត្រី និងជាធាតុផ្សំដែលរួមចំណែកបង្កឱ្យមាននូវសកម្មភាពឧក្រិដ្ឋមួយ។ អំពើហិង្សាបែបនេះ រាប់បញ្ចូលសកម្មភាពដែលអនុញ្ញាត ឬប្រព្រឹត្តដោយរដ្ឋ សកម្មភាពហិង្សាដែលបន្តកើតឡើងទៅលើស្ត្រីនៅពេលមានសន្តិភាព និងសង្គ្រាម ព្រមទាំងនៅក្នុងបរិបទក្រោយជម្លោះ និងរាប់បញ្ចូលការរំលោភសេពសន្ថវៈ ការបៀតបៀន ការបង្ខំឱ្យមានផ្ទៃពោះ ការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ការបញ្ឈប់កំណើត និងការបង្ខំឱ្យរំលូតកូន ការច្រិបប្រដាប់ភេទ ការបង្ខំឱ្យធ្វើជាទាសករ ការបង្ខំឱ្យចូលរួមនៅក្នុងសកម្មភាពពេស្យាចារ និងការជួញដូរ ព្រមទាំងសកម្មភាពដទៃទៀត។ អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រ គឺជាចរិកលក្ខណៈមួយនៃជម្លោះប្រដាប់អាវុធជាសកល ដោយជនល្មើសរីករាយទៅនឹងនិទណ្ឌភាពសម្រាប់សកម្មភាពរបស់ពួកគេ។

ផលប៉ះពាល់នៃហិង្សាផ្លូវភេទទៅលើជនរងគ្រោះរាប់បញ្ចូលការបាត់បង់មុខរបរ និងឱកាសសេដ្ឋកិច្ច ព្រមទាំងឱកាសអប់រំ ហើយវាបណ្តាលឱ្យមានការរំខាន និងបំផ្លិចបំផ្លាញចំពោះជីវិតរស់នៅរបស់ជនរងគ្រោះ។ ការរំលោភសេពសន្ថវៈគឺជាប្រភេទនៃអំពើហិង្សាទៅលើស្ត្រី និងកុមារីនៅមានជម្លោះ ដែលត្រូវបានគេប្រើប្រាស់ទូលំទូលាយជាងគេបំផុត ប៉ុន្តែបើទោះជាដូច្នេះក្តី បទល្មើសនេះនៅតែបន្តជាបទល្មើសដែលទទួលរងការថ្កោលទោសតិចតួចបំផុតនៅកម្រិតអន្តរជាតិ។ ដើម្បីឱ្យយល់កាន់តែច្បាស់ជាងនេះ និងលុបបំបាត់ហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ នៅពេលមានជម្លោះ គេត្រូវចាត់ទុកបទល្មើសនេះ ថាជាការគំរាមកំហែងមួយចំពោះសន្តិភាព និងសន្តិសុខ និងត្រូវដោះស្រាយក្នុងលក្ខណៈជាផ្នែកមួយនៃអំពើហិង្សាដែលបន្តកើតឡើងទៅលើស្ត្រី និងការរើសអើងយេនឌ័រ នៅមុនពេលក្នុងអំឡុងពេល និងក្រោយពេលសង្គ្រាម ដែលជាចំណែកមួយនៃការបង្ហាញអំពីការគ្រប់ដណ្តប់ទៅលើស្ត្រី។ មានតែដូច្នេះទេ ទើបយើងអាចលុបបំបាត់អំពើហិង្សាយេនឌ័រ និងផលប៉ះពាល់អវិជ្ជមានរបស់វាទៅលើបុគ្គលដែលជាជនរងគ្រោះ គ្រួសាររបស់ពួកគេ និងសហគមន៍ទាំងមូល។

## ៣. សក្ខីកម្មរបស់អ្នកជំនាញការៈ អភិក្រមតាមរយៈប្រព័ន្ធយុត្តិធម៌ និងអភិក្រមមិនមែនតាមរយៈប្រព័ន្ធយុត្តិធម៌ចំពោះបញ្ហាយុត្តិធម៌យេនឌ័រ



*ស៊ូហ្សាណា សាកូតូ , អនុបណ្ឌិត ប្រធានការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម និងសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ សាកលវិទ្យាល័យវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិក*

**សាស្ត្រាចារ្យ សាកូតូ** បានបង្ហាញអំពីការវិវឌ្ឍន៍ បញ្ហាប្រឈមដែលនៅសេសសល់ និងមេរៀនបទពិសោធន៍ដែលទទួលបានពីការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើបទល្មើសហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រនៅពេលមានជម្លោះ ដោយតុលាការអន្តរជាតិ តុលាការកូនកាត់ និងតុលាការក្នុងស្រុក ព្រមទាំងមេរៀន បទពិសោធន៍ មួយចំនួនអំពីដំណោះស្រាយក្រៅប្រព័ន្ធតុលាការចំពោះបញ្ហាយុត្តិធម៌យេនឌ័រ។ បើទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ចំពោះប្រព្រឹត្តកម្មនៃបញ្ហាហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ ក្រោមច្បាប់អន្តរជាតិក៏ដោយ សាស្ត្រាចារ្យ សាកូតូ បានធ្វើការកត់សម្គាល់ថា បញ្ហាប្រឈមនៅតែបន្តមាន។ មេរៀនបទពិសោធន៍ រួមមានដូចជា ៖

- ប្រសិនបើពុំមានគោលនយោបាយស្ថាប័ន ដើម្បីគាំទ្រដល់ការចោទប្រកាន់ទៅលើបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះទេ នោះព្រះរាជអាជ្ញារមែងតែងមិនអាចធ្វើការចោទប្រកាន់ទៅលើជនល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ បើទោះបីជាពួកគេមានភស្តុតាងពាក់ព័ន្ធក៏ដោយ។ ដូច្នេះ ការបង្កើតឱ្យមាននូវយុទ្ធសាស្ត្រសម្រាប់ធ្វើការចោទប្រកាន់មួយដែលមានការសម្របសម្រួល និងមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីកំណត់អាទិភាពទៅលើបទល្មើស ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះពីដំបូងមានសារៈសំខាន់ខ្លាំងណាស់ចំពោះការស៊ើបអង្កេត និងការចោទប្រកាន់បទល្មើសទាំងនេះប្រកបដោយប្រសិទ្ធភាព។

- ជនរងគ្រោះរមែងតែងមានភាពស្ទាក់ស្ទើរក្នុងការរាយការណ៍អំពីបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ។ ដូច្នេះការអនុវត្តន៍ ស៊ើបអង្កេតត្រូវពិចារណាទៅលើសេចក្តីត្រូវការរបស់ជនរងគ្រោះតាមរយៈការបង្កើតឱ្យមាននូវ (ក្នុងករណីដែលអាចធ្វើទៅបាន) សមាហរណកម្ម សេវាកម្មមួយចំនួនដែលជម្រុញដល់ការប្រមូលភស្តុតាងឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយក្នុងបរិយាកាសមួយដែលផ្តល់ការគាំទ្រចំពោះជនរងគ្រោះរាប់បញ្ចូលការផ្តល់សេវាវេជ្ជសាស្រ្ត សេវាប្រឹក្សា និងសេវាច្បាប់។
- ជនរងគ្រោះ/សាក្សី អាចមានការភ័យខ្លាចចំពោះការតបតទៅលើខ្លួនពួកគេ ឬគ្រួសាររបស់ពួកគេវិញប្រសិនបើពួកគេធ្វើការកំណត់អត្តសញ្ញាណជនល្មើសនៅក្នុងតុលាការ ឬប្រសិនបើពួកគេជួយដល់ការស៊ើបអង្កេត ឬការចោទប្រកាន់ចំពោះបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ ដូច្នេះ កិច្ចការពារសាក្សីនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីតុលាការមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឱ្យការចោទប្រកាន់ទៅលើបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះទទួលបានជោគជ័យ។
- ចៅក្រមដែលមិនសូវមានការយល់ដឹងអំពីបញ្ហានេះ ឬចៅក្រមដែលខ្វះបទពិសោធន៍ ប្រឈមទៅនឹងការធ្វើឱ្យសាក្សីលែងឯកភាព និងធ្វើឱ្យធ្លាក់ចុះនូវតម្លៃសក្ខីកម្មដែលមានសារៈសំខាន់ក្នុងការចោទប្រកាន់ទៅលើបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រកបដោយជោគជ័យ ដូច្នេះចៅក្រមគួរទទួលបានការបណ្តុះបណ្តាលអំពីវិសាលភាពធម្មជាតិ និងផលប៉ះពាល់នៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ ព្រមទាំងយុត្តិសាស្រ្តដែលទាក់ទងទៅនឹងធាតុផ្សំនៃបទល្មើសហិង្សាផ្លូវភេទ និងបទល្មើសហិង្សាយេនឌ័រ ព្រមទាំងការអនុវត្តន៍ច្បាប់ចំពោះស្ថានភាពជាក់ស្តែងផ្សេងៗគ្នាដែលពាក់ព័ន្ធទៅនឹងហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេល មានជម្លោះ។

**សាស្រ្តាចារ្យ សាគូតូ** ក៏បានពិភាក្សាផងដែរអំពីមេរៀនបទពិសោធន៍ ដែលទាក់ទងទៅនឹងយន្តការក្រៅប្រព័ន្ធតុលាការ ក្នុងការដោះស្រាយបទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ ក្នុងនោះរួមមានដូចជា៖ សេចក្តីត្រូវការឱ្យមាននូវយន្តការក្រៅប្រព័ន្ធតុលាការ ដើម្បីកំណត់ទៅលើអាណត្តិការងារយេនឌ័រមួយពីដំបូងដែលសង្កត់ធ្ងន់អំពីការចូលរួមរបស់ស្រ្តី នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការងាររបស់ពួកគេ និងធានាថា ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ ដែលជាបទល្មើសគោលដៅ ត្រូវបានគេធ្វើការស៊ើបអង្កេត ព្រមទាំងសារៈសំខាន់នៃការជួយដល់ជនរងគ្រោះ ក្នុងការទទួលបានយន្តការក្រៅប្រព័ន្ធតុលាការ ឧទាហរណ៍តាមរយៈការអនុញ្ញាតឱ្យមានក្របខ័ណ្ឌពេលវេលាទូលំទូលាយបំផុតសម្រាប់ជនរងគ្រោះ ដើម្បីចូលរួមនៅក្នុងកម្មវិធីបែបនេះ ការអនុម័តជ្រើសរើសយកនីតិវិធីដែលផ្តោតយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ សម្រាប់ការយកសក្ខីកម្ម ការចាប់ដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារជាមួយជនដែលទទួលរងផលប៉ះពាល់ពីហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ និងការផ្តល់ការរក្សាការសម្ងាត់ និងវិធានការដទៃទៀត ដើម្បីការពារសុវត្ថិភាព និងសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងគ្រោះ។

## ៤. សក្ខីកម្មរបស់អ្នកជំនាញការ ៖ ស្ត្រី សន្តិភាព និងសន្តិសុខ

*អាន-ម៉ារី ហ្គូត , PhD ប្រធានទីប្រឹក្សាកម្មវិធីអភិបាលកិច្ច សន្តិភាព និងសន្តិសុខ UN Women*



**បណ្ឌិត ហ្គូត** បានរំលឹកដល់អ្នកចូលរួមថា សូម្បីតែការរំលោភសេពសន្ថវៈតែមួយនៅក្នុងសង្គ្រាម ដែលធ្វើឡើងដោយទាហានមួយរូបអាចជាធាតុផ្សំដែលរួមចំណែកឱ្យមាននូវឧក្រិដ្ឋកម្មនៅពេលមានសង្គ្រាម។ វាមានសារៈសំខាន់ក្នុងការការពារស្ត្រីដែលមានទំនាស់ និងការធានាឱ្យមាននូវការដឹកនាំរបស់ស្ត្រីនៅក្នុងសន្តិភាព គឺជាដំណើរការនយោបាយមួយដែលស្របទៅនឹងសំនួរបច្ចេកទេសផ្នែកច្បាប់។ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិបានអនុម័តទៅលើសេចក្តីសម្រេចចំនួន៥ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (UN SCR 1325 [2000], UNSCR 1820 [2008], UN SCR 1888 [2010], UN SCR 1889 [2010], UN SCR 1960 [2011])។ បើទោះបីជាសេចក្តីសម្រេចស្តីពីសន្តិសុខដែលទាក់ទងទៅនឹងហិង្សាផ្លូវភេទមានលក្ខណៈគួរឱ្យកត់សម្គាល់ក៏ដោយ ក៏សេចក្តីសម្រេចទាំងនេះមិនអាចមានប្រសិទ្ធភាពឡើយ ប្រសិនបើពុំមានការវិនិយោគស្របគ្នាមួយទៅលើការផ្តល់ភាពអង់អាចដល់ស្ត្រី។



អំពើហិង្សាផ្លូវភេទ បុព្វហេតុ និងផលវិបាកនៃអំពើហិង្សាផ្លូវភេទ ត្រូវបានអតីតអ្នកយកព័ត៌មានពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើស្ត្រីពណ៌នាថាជា "ឧក្រិដ្ឋកម្មនៅពេលមានសង្គ្រាមដែលត្រូវបានគេផ្តន្ទាទោសតិចតួចបំផុត" (១៩៩៤) ហើយបទពិសោធន៍ឆ្លងតាមរយៈការចោទប្រកាន់ទៅលើបទល្មើសបែបនេះ នៅក្នុងសវនាការសម្រាប់អតីតយូហ្គោស្លាវី (ICTY) , រ៉ាវ៉ាន់ដា (ICTR) និងសៀរ៉ាឡេអូង (SCSL) បានបង្ហាញថា សេចក្តីថ្លែងនេះ នៅតែបន្តមានលក្ខណៈពិតយ៉ាងដូច្នេះ។ ទាក់ទងទៅនឹងការប៉ុនប៉ងរបស់យោធា និងកម្រិតនៃគ្រោះថ្នាក់ចំពោះជនរងគ្រោះ ការរំលោភសេពសន្ថវៈបានកើតឡើងក្នុងលក្ខណៈជាចរិកលក្ខណៈមួយនៃជម្លោះដែលគេបានកំណត់នៅក្នុងសម័យកាលរបស់យើងដែលនោះគឺជាវិធីសាស្ត្រមួយដែលមិនចំណាយថវិកាច្រើន ប៉ុន្តែមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើតឱ្យមាននូវជម្លោះ ការបង្កការភ័យខ្លាចចំពោះសហគមន៍ និងការបង្ខំជម្លៀសជនស៊ីវិល។

បើទោះជាដូច្នេះក្តី ការឆ្លើយតបភាគច្រើនពុំមានលក្ខណៈខុសប្លែកពីគ្នាឡើយ ក្រៅពីការខឹងសម្បារ។ សេចក្តីសម្រេចទាំង៥ របស់ក្រុមប្រឹក្សាសន្តិសុខ បានធ្វើការកំណត់ឡើងវិញទៅលើហិង្សាផ្លូវភេទនិងយេនឌ័រក្នុងពេលមានជម្លោះ ថាជាការគំរាមកំហែងមួយចំពោះសន្តិសុខ ដែលទាមទារឱ្យមាននូវការឆ្លើយតបផ្នែកនយោបាយ និងសន្តិសុខជាពិសេសគឺត្រង់ថា អំពើហិង្សាបែបនេះបង្កឱ្យមានការរាំងស្ទះចំពោះការស្តារឡើងវិញនូវសេដ្ឋកិច្ច ទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌ និងការបង្កើតនីតិរដ្ឋ។ យ៉ាងណាមិញ នៅពេលដែលហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះត្រូវបានកំណត់ត្រឹមតែជាបញ្ហាសន្តិសុខ និងមិនបានដោះស្រាយបញ្ហាឋានៈសង្គមរបស់ស្ត្រីដែលទាបជាងបុរសមានន័យថា ស្ត្រីត្រូវបានបញ្ចូលទៅក្នុងរបៀបវារៈសន្តិសុខក្នុងលក្ខណៈត្រឹមតែជាជនរងគ្រោះ ឬជាជនរងគ្រោះសក្តានុពលជាជាងអ្នកដឹកនាំ និងជាអ្នកចង្អុលទិសនៃសន្តិភាព។

ការឆ្លើយតបផ្នែកយោធាតែម៉្យាង នឹងមិននាំមកនូវការផ្លាស់ប្តូរដែលចាំបាច់ដើម្បីដោះស្រាយបញ្ហាការផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងគោលដៅលុបបំបាត់អំពើហិង្សាលើស្ត្រីឡើយ។ UN SCR 1325 បានធ្វើការអំពាវនាវយ៉ាងច្បាស់លាស់សំដៅឱ្យមានការចូលរួមរបស់ស្ត្រីក្នុងនាមជាអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងដំណើរការសន្តិភាព និងដំណើរការសន្តិសុខ ហើយ UN SCR 1820 អំពាវនាវឱ្យស្ត្រី ជាពិសេសជនរងគ្រោះធ្វើការដឹកនាំលើបញ្ហាកិច្ចការពារ និងដំណើរការសន្តិភាព។ ប៉ុន្តែកន្លងមក សកម្មភាពលើបញ្ហានេះ ឬការបញ្ចូលហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះទៅក្នុងការពិភាក្សាជាផ្លូវការអំពីបញ្ហាសន្តិភាពនៅមានកម្រិតទាបនៅឡើយ។ ពុំមានកិច្ចព្រមព្រៀងណាមួយក្នុងចំណោមកិច្ចព្រមព្រៀងទាំងនេះ កំណត់ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះថា មានទំនាក់ទំនងទៅនឹងការស្តារសេដ្ឋកិច្ចឡើងវិញឡើយ។

UN Women កំពុងផ្តោតយកចិត្តទុកដាក់ទៅលើវិស័យមួយចំនួន ដើម្បីបន្តជម្រុញឱ្យមានគណនេយ្យភាពក្នុងចំណោមរដ្ឋជាសមាជិក ព្រមទាំងប្រព័ន្ធអង្គការសហប្រជាជាតិលើបញ្ហាហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ រាប់បញ្ចូលការស្វែងរកការគាំទ្រដល់អភិក្រមមួយដែលផ្តោតយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ចំពោះការបែងចែកថវិកាដែលសន្សំបានពីការកាត់បន្ថយទិញគ្រឿងសព្វាវុធក្នុងដំណាក់កាល ក្រោយពេលមានជម្លោះរាប់ចាប់ពីការទទួលបានដោយពេញលេញ និងស្មើភាពគ្នារបស់ស្ត្រីនូវសេវាមូលដ្ឋានរហូតដល់ការចូលរួមប្រកបដោយអត្ថន័យនៅក្នុងកិច្ចពិភាក្សាជាផ្លូវការអំពីសន្តិភាព និងកិច្ចខិតខំស្តារឡើងវិញនូវសេដ្ឋកិច្ច និងទីផ្សារ។ សេចក្តីសម្រេចទាំង៥អំពីបញ្ហាសន្តិសុខ ដែលបង្កើតឱ្យមាននូវរបៀបវារៈស្តីពីសន្តិភាព និងសន្តិសុខរបស់ UN Women ត្រូវអនុវត្តស្របពេលជាមួយគ្នា និងតំណាលគ្នាដើម្បីធានាថា ការផ្តល់ភាពអង់អាចដល់ស្ត្រីមានទំនាក់ទំនងទៅនឹងកិច្ចការពារ។ ជាចុងក្រោយ កិច្ចការពារស្ត្រី និងកុមារីក្នុងអំឡុងពេល និងក្រោយពេលជម្លោះមិនអាចធ្វើទៅបានឡើយ ប្រសិនបើពុំមានការផ្តល់ភាពអង់អាចដល់ស្ត្រី និងការចូលរួមរបស់ស្ត្រីដែលជាដំណើរការនយោបាយមួយរយៈពេលវែង។





*អ្នកផ្តល់សក្ខីកម្មដែលជាជនជាតិខ្មែរ ៖ (ពីស្តាំទៅឆ្វេង) ហុង សាវ៉ាត , ជុំ លី , សុខ សាមិត , គឹម ខែម*

## គ. ការផ្តល់សក្ខីកម្មដោយជនរងគ្រោះ និងសាក្សី

ក្នុងអំឡុងពេលនៃវេទិកាស្តីពីការស្តាប់សម្លេងស្ត្រីតំណាងសង្គមស៊ីវិលមួយរូប (CSR) មកពីប្រទេសនីមួយៗ បានផ្តល់ទិដ្ឋភាពទូទៅមួយអំពីជម្លោះ និងក្រោយមកទើបផ្តល់ការណែនាំជូនដល់ជនរងគ្រោះតាមរយៈសក្ខីកម្មរបស់ពួកគេ។ ជនរងគ្រោះនីមួយៗបានផ្តល់សក្ខីកម្មជាក់ស្តែងជាភាសាជាតិរបស់ខ្លួន ហើយគាត់មានសេរីភាពក្នុងការបញ្ចប់សក្ខីកម្មរបស់គាត់នៅពេលណាមួយក៏បាន។ ការសង្ខេបដែលផ្តល់ជូននៅក្នុងរបាយការណ៍នេះ មានគោលបំណងជម្រាបអំពីសាច់រឿងរបស់ស្ត្រីតាមរយៈសម្លេងរបស់ពួកគេ និងផលប៉ះពាល់ផ្នែកសតិអារម្មណ៍ដែលបន្តកើតឡើងតាមរយៈព្រឹត្តិការណ៍ទាំងនេះ។ ដើម្បីរៀបចំធ្វើការចែករំលែករឿងរ៉ាវរបស់ពួកគេឱ្យបានគ្រប់គ្រាន់នៅចំពោះមុខសាធារណ-ជនដ៏ច្រើនកុះករ អ្នកផ្តល់សក្ខីកម្មបានរៀបចំសក្ខីកម្មលាយលក្ខណ៍អក្សរដោយមានការគាំទ្រពីតំណាងសង្គមស៊ីវិលមុនពេលមកដល់ប្រទេសកម្ពុជា។ សក្ខីកម្មលាយលក្ខណ៍អក្សរដែលមានខ្លឹមសារ ទាំងស្រុងទាំងអស់នេះ អាចរកមើលនៅក្នុងឧបសម្ព័ន្ធ ខ។

## ១. ប្រទេសកម្ពុជា



***លោក ជួង សាវឌន*** *មន្ត្រីសម្របសម្រួលគម្រោងហិង្សាយេនឌ័រ ក្នុងរបបខ្មែរក្រហមនៃអង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដើរតួនាទីជាតំណាងសង្គមស៊ីវិល។*

*កម្ពុជាបានរងគ្រោះពីសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៩៩។ របបខ្មែរក្រហមបានកាន់អំណាចចន្លោះពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩។ ស្ថិតក្រោមរបបនេះ ប្រជាជនចំនួនជិតពីរលាននាក់ (ក្នុងចំណោមប្រជាជនសរុបចំនួនប្រាំពីរលាននាក់) បានស្លាប់បាត់បង់ជីវិតដោយសារតែការបង្ខំឱ្យធ្វើពលកម្ម ភាពអត់ឃ្លាន និងការកាប់សម្លាប់ ព្រមទាំងមូលហេតុដទៃទៀត។ គ្រួសារត្រូវបានបង្ខំឱ្យរស់នៅបែកពីគ្នា ហើយបុរស និងស្ត្រីត្រូវបានបង្ខំឱ្យរៀបការជាមួយគ្នា។ អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាយេនឌ័រ បានកើតឡើងក្នុងភាពស្ងៀមស្ងាត់អស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកហើយ ប៉ុន្តែនាពេលថ្មីៗនេះ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងអង្គការដទៃទៀតបានធ្វើការចងក្រងឯកសារអំពីករណីរំលោភសេពសន្ថវៈ ដែលរាប់បញ្ចូលការរំលោភជាក្រុម ការរំលោភដោយមនុស្សច្រើននាក់ និងការរំលោភមុនពេលសម្លាប់ ព្រមទាំងការដាក់ទោសចំពោះ "ការខុសសីលធម៌" សម្រាប់រាល់ទម្រង់នៃទំនាក់ទំនងរវាងបុរស និងស្ត្រី មិនចំពោះថាទម្រង់នៃទំនាក់ទំនងទាំងនោះមានលក្ខណៈជាការព្រមព្រៀង ឬបង្ខិតបង្ខំឡើយ។ បច្ចុប្បន្ននេះខណៈពេលដែល អ.វ.ត.ក បន្តធ្វើការវិនិច្ឆ័យទៅលើបទល្មើសដែលបានប្រព្រឹត្តក្រោមរបបខ្មែរក្រហម មានជនរងគ្រោះជាងប្រាំពីររយនាក់ ចំពោះករណីបង្ខំឱ្យរៀបការបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្ប-វេណី។*

**លោកស្រី ហុង សាវ៉ាត** (អាយុ ៤៧ឆ្នាំ) គឺជាសិស្សម្នាក់ដែលរស់នៅក្នុងទីក្រុងភ្នំពេញ មុនពេលដែលរបបខ្មែរក្រហមបានកាន់អំណាច ហើយក្រោយមកគ្រួសាររបស់គាត់ត្រូវបានគេបង្ខំជម្លៀសទៅកាន់ខេត្តមួយនៅឯទី

ជនបទ។ កាលនោះលោកស្រីមានអាយុ១៤ឆ្នាំ ហើយលោកស្រីបានចូលរួមនៅក្នុងកងកុមារ ដើម្បីគាស់គល់ឈើចំនួន៣ ដែលនេះគឺជាការងារមួយដ៏លំបាក។ ថ្ងៃមួយបងប្រុសរបស់គាត់បានលួចដំឡូង ដើម្បីយកទៅឱ្យគ្រួសាររបស់គាត់ហូប ប៉ុន្តែគាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់បាន ហើយយកទៅសម្លាប់ចោល។ បងស្រីរបស់គាត់ចំនួន២នាក់ ត្រូវបានបង្ខំឱ្យរៀបការជាហ្វូងដែលមានប្តីប្រពន្ធចំនួន២០គូ។ នៅពេលដែលបងស្រីម្នាក់របស់គាត់បានរត់ទ្រហោយំទៅកាន់ម្តាយរបស់គាត់ ក្រោយពេលដែលបានស្បថរួចកម្មាភិបាលម្នាក់បានយកគាត់ទៅខាងក្រៅ ហើយយកចំពុះទុងចាក់ខ្នងរបស់គាត់។ លោកស្រី សា៉ាត ក៏បានឃើញប្អូនស្រីរបស់គាត់ស្លាប់ដោយការអត់ឃ្លានផងដែរ ប៉ុន្តែគេមិនអនុញ្ញាតឱ្យលោកស្រីបញ្ចុះសពប្អូនស្រីរបស់គាត់ឡើយ ដោយគេទុកឱ្យសាកសពរលួយបន្តិចម្តងៗរហូតដល់នៅសល់តែឆ្អឹង។ ឪពុករបស់លោកស្រីបានលួចមាន់មួយ និងបបរជ្រូកដើម្បីកុំឱ្យគ្រួសារដាច់ពោះស្លាប់ ហើយឪពុក និងម្តាយរបស់លោកស្រីក៏ត្រូវបានគេចាប់ខ្លួន។

ថ្ងៃមួយនៅពេលដែល **លោកស្រី សា៉ាត** ត្រឡប់មកពីស្រែវិញ គាត់ក៏បានឃើញឪពុកម្តាយរបស់គាត់ត្រូវបានគេ ចងនៅឯវាលពិឃាតមួយក្នុងចំណោមគំនរសាកសពជាច្រើន។ **លោកស្រី សា៉ាត** បានរត់ទៅឪបម្តាយរបស់គាត់ ហើយក៏ត្រូវកម្មាភិបាលឃើញ។ ឪពុករបស់លោកស្រីត្រូវបានគេចាក់សម្លាប់ ហើយម្តាយរបស់លោកស្រីត្រូវបានគេវាយដំរហូតដល់ស្លាប់ផងដែរ។ លោកស្រីត្រូវបានគេចាប់យកទៅក្នុងព្រៃក្បែរនោះ បន្ទាប់មកត្រូវបានគេបង្ខំដោះសម្លៀកបំពាក់ ចាប់ចង និងរំលោភម្តងហើយម្តងទៀត ដោយឈ្លបចំនួន៣នាក់ ដែលចុងក្រោយបានទុកឱ្យគាត់នៅតែម្នាក់ឯង។ ព្រឹកស្អែកឡើង គាត់បានដឹងខ្លួនដោយគ្មានសម្លៀកបំពាក់នៅជាប់នឹងខ្លួនឡើយ ហើយគាត់ក៏បានលួចសម្លៀកបំពាក់ពីសាកសពនៅឯវាលពិឃាត ដើម្បីធ្វើការរត់គេចខ្លួន។ គាត់ត្រូវបានជនល្មើសម្នាក់ព្រមានថា ប្រសិនបើគាត់វិលត្រឡប់ទៅសហកររបស់គាត់វិញ គាត់នឹងត្រូវគេយកទៅសម្លាប់ចោលមិនខាន។ គាត់បានប្តូរឈ្មោះ ហើយទៅរស់នៅក្នុងសហករមួយទៀត។ លោកស្រី សា៉ាត បានមានផ្ទៃពោះពីការរំលោភជាក្រុម ហើយគាត់បានផ្តល់កំណើតឱ្យទារកម្នាក់ ក្រោយពេលដែលរបបនេះបានដួលរលំអស់រយៈពេល ៤ខែ។

នៅពេលដែលសាកសួរអំពីផលប៉ះពាល់នៃបទពិសោធន៍របស់គាត់ លោកស្រី សា៉ាត បានតបឱ្យដឹងថា គាត់មានបញ្ហាឈាមស្មួនរហូតមកទល់នឹងសព្វថ្ងៃ។ ការរៀបការមានលក្ខណៈខុសប្លែកពីទំនៀមទម្លាប់ប្រពៃណី និងសាសនាព្រមទាំងអត្ថន័យរបស់វា ហើយលោកស្រីមានការអៀនខ្មាសដោយសារតែលោកស្រីពុំមានឪពុកម្តាយធ្វើជាមេបាដូចអ្នកដទៃ ដែលចំណុចនេះមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងព្រះពុទ្ធសាសនា និងវប្បធម៌ខ្មែររបស់គាត់។

**លោកស្រី គឹម ខែម** (អាយុ ៨០ឆ្នាំ) បានទទួលរងការវាយដំ ការធ្វើទារុណកម្ម ការបង្ខំឱ្យធ្វើពលកម្ម និងបានឃើញការធ្វើទារុណកម្មផ្លូវភេទលើស្ត្រីនៅក្នុងរបបនោះ។ គាត់បានសម្តែងអំពីការភ័យខ្លាចរបស់គាត់ក្នុងការមកផ្តល់សក្ខីកម្មនាថ្ងៃនេះ ដោយបានថ្លែងថា *"ខ្ញុំគិតថា ខ្ញុំនឹងត្រូវគេសម្លាប់ដូចនៅជំនាន់ប៉ុលពតទៅហើយប៉ុន្តែថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ និងធូរស្បើយដែលបានចែករំលែករឿងរ៉ាវរបស់ខ្ញុំ។"* គាត់បានពន្យល់អំពីរបៀបដែលរបបនេះបានបំបែកគ្រួសារឱ្យរស់នៅបែកពីគ្នា និងមិនស្គាល់គ្នា។ គាត់បានបាត់បងប្អូនបង្កើតរបស់គាត់ទាំង៦នាក់ក្នុងអំឡុងពេលនៃជម្លោះនេះ។ ស្វាមីរបស់គាត់ក៏ត្រូវបានគេសម្លាប់ផងដែរ ហើយនៅពេលដែលម្តាយរបស់គាត់ស្លាប់ហើយ គាត់

ស្នើសុំបញ្ចុះសពម្ដាយរបស់គាត់ គេបានប្រាប់គាត់ឱ្យ "បោះសាកសពម្ដាយរបស់គាត់ចោល"។ គាត់ត្រូវបានគេចាប់ខ្លួន និងឃុំឃាំងដោយសារតែគាត់បដិសេធក្នុងការទុកចោលកូនរបស់គាត់ដែលមានអាយុ១៣ខែ។ គេបានចាប់គាត់ចងស្លាបសេក និងយកកូនរបស់គាត់ចងជុំវិញករបស់គាត់ដោយបន្សល់នូវស្លាកស្នាមរហូតមកទល់នឹងសព្វថ្ងៃ។

នៅពេលដែលគាត់ទៅដល់កន្លែងវាលពិឃាត គាត់បានឃើញមនុស្ស១១នាក់ផ្សេងទៀត ដែលកំពុងរង់ចាំឱ្យគេសម្លាប់។ ប៉ុន្តែសំណាងល្អគាត់បានរួចផុតពីការស្លាប់ ហើយវាចេញពីរណ្ដៅសាកសពជាមួយកូនរបស់គាត់ដែលនៅចងជាប់នឹងករបស់គាត់នៅឡើយ។ នៅពេលដែលគេបានរកឃើញគាត់ ពួកកម្មាភិបាលមានភាពភ្ញាក់ផ្អើលជាខ្លាំង ហើយគេបានយកគាត់ទៅឃុំឃាំងក្នុងពន្ធនាគារ។ គេនៅតែបន្តចងគាត់នៅក្នុងពន្ធនាគារអស់រយៈពេល៧ថ្ងៃទើបស្រាយចំណងឱ្យគាត់។ នៅពេលដែលគាត់មានបំណងបម្រុងទៅរកទឹក ឆ្មាំពន្ធនាគារបានទាត់ធាក់កូនរបស់គាត់។ កូនរបស់គាត់បានរត់មករកគាត់ ប៉ុន្តែវាពុំមានកម្លាំងគ្រប់គ្រាន់ដើម្បីរត់ចូលទៅក្នុងរង្វង់ដៃរបស់គាត់ឡើយ។ ឆ្មាំពន្ធនាគារបានយកជើងជាន់ក្បាលកូនរបស់គាត់ ដែលធ្វើឱ្យកូនរបស់គាត់ស្លាប់ភ្លាមមួយរំពេច និងបន្សល់សាកសពនៅលើដីឱ្យគេដើរជាន់ ព្រមទាំងប្រើប្រាស់ខ្សែដែលស្ថិតនៅជុំវិញកកូនរបស់គាត់ ដើម្បីទាញសាកសពកូនឱ្យផុតពីដៃរបស់គាត់។

**លោកស្រី គឹម ខែម** បានធ្វើការប៉ាន់ប្រមាណថា មានមនុស្សជាងប្រាំមួយរយនាក់នៅក្នុងពន្ធនាគារ ហើយស្ត្រីស្រស់ស្អាតក្មេងៗដែលប្រហែលជាស្ត្រីនៅព្រហ្មចារីផងនោះ ត្រូវបានបង្ខំឱ្យរួមភេទជាមួយកម្មាភិបាលរៀងរាល់យប់ហើយក្រោយមកក៏បាត់ខ្លួន។ គាត់បានស្ដាប់ឮសំលេងស្រែកទ្រហោយំរបស់ពួកគេ *"តើមិត្តឯងប្រុងធ្វើអីហ្នឹង? កុំ......កុំ!"*។ ថ្ងៃមួយនៅពេលដែលគាត់ត្រឡប់មកពីស្រែវិញ គាត់បានឃើញសកម្មភាពរំលោភបំពានទៅលើស្ត្រីម្នាក់ទៀត ដែលត្រូវបានគេចោទប្រកាន់ថាបានព្យាយាមរត់គេចខ្លួន។ កម្មាភិបាលបានហែកសម្លៀកបំពាក់ និងប្រើប្រាស់អង្កត់អុសដែលកំពុងឆេះ ដើម្បីរំលោភស្ត្រីម្នាក់នោះ។ នៅពេលដែលលោកស្រី គឹម ខែម បានឃើញ ទិដ្ឋភាពបែបនេះ គាត់បានគិតថា *"វាគឺជារឿងមួយដែលពិបាកទ្រាំខ្លាំងណាស់។ ប៉ុន្តែប្រសិនបើខ្ញុំស្រែក គេប្រាកដជានឹងយកខ្ញុំទៅសម្លាប់ចោលមិនខាន"*។ នៅពេលដែលគេបានសាកសួរគាត់ថា ហេតុអ្វីបានជាគាត់មកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គាត់បានថ្លែងឱ្យដឹងថា *"ខ្ញុំនិយាយជំនួសឱ្យស្ត្រីគ្រប់រូបដែលបានស្លាប់បាត់បង់ជីវិត ហើយខ្ញុំសូមឱ្យព្រលឹងរបស់ពួកគេបានទៅដល់ឋានសុគតិភព"*។

**លោកស្រី ជុំ លី** (អាយុ ៥៨ឆ្នាំ) បម្រើការងារនៅក្នុងអង្គភាពឱសថមួយនៅរបបខ្មែរក្រហម។ គាត់ត្រូវបានគេបង្ខំឱ្យធ្វើការងារជាគិលានុបដ្ឋាយិកា បើទោះបីជាគាត់មិនធ្លាប់ទទួលបានការបណ្ដុះបណ្ដាលផ្លូវការ និងមិនចេះអក្សរក៏ដោយ។ គាត់ទទួលបន្ទុកចាក់ថ្នាំឱ្យអ្នកជម្ងឺ ហើយប្រធានអង្គភាពរមែងតែងមកជួបគាត់ជាញឹកញាប់សម្រាប់គោលបំណងនេះ។ ប្រធានអង្គភាពបានចងគាត់ និងវាយធ្វើបាបគាត់ចំនួន៣ដង ហើយប្រាប់គាត់ថា គាត់បានជ្រៀតជ្រែកចំពោះទំនាក់ទំនងរបស់គាត់ជាមួយស្ត្រីម្នាក់ដែលរស់នៅឯត្រើយម្ខាងទៀតនៃទន្លេ។ ដោយសារតែប្រធានអង្គភាពមានប្រពន្ធកូនរួចហើយ គាត់ក៏បានគំរាមសម្លាប់លោកស្រី ប្រសិនបើលោកស្រីប្រាប់អ្នកដទៃអំពីទំនាក់ទំនងរបស់គាត់។

ក្នុងឆ្នាំ១៩៧៧ លោកស្រីត្រូវបានគេស្នើសុំចំនួន៣ដង ឱ្យរៀបការជាមួយបុរសម្នាក់ដែលរស់នៅក្នុងភូមិជាមួយគ្នា។ គាត់បានបដិសេធ ហើយក៏ត្រូវបានគេគំរាមអាយុជីវិត ដូច្នេះគាត់ក៏បានរៀបការជាមួយបុរសម្នាក់នោះជាក្រុម។ គាត់ និងស្វាមីរបស់គាត់មានកូនម្នាក់ជាមួយគ្នា ហើយគាត់មានបំណងចង់ទៅលេងឪពុកម្តាយរបស់គាត់ នៅពេលដែលកូនរបស់គាត់មានអាយុ៤ខែ។ នៅពេលធ្វើដំណើរតាមផ្លូវទៅកាន់ភូមិដែលឪពុកម្តាយរបស់គាត់រស់នៅ គេបានចាប់គាត់ឃុំខ្លួននៅឯច្រកត្រួតពិនិត្យមួយ។ គេបានបញ្ជាឱ្យគាត់ដោះសម្លៀកបំពាក់ចេញ។ នៅពេលដែលគាត់បដិសេធ គេបានបង្ខំដោះសម្លៀកបំពាក់របស់គាត់ និងចាប់រំលោភគាត់ជាច្រើនលើកច្រើនសារ ដោយជនល្មើសជាច្រើននាក់រហូតដល់ពេលទៀបភ្លឺ។ ជនល្មើសបានគំរាមសម្លាប់គាត់ ប្រសិនបើគាត់ប្រាប់អ្នកដទៃ ហើយជាក់ស្តែងគាត់មិនដែលចែករំលែកអំពីរឿងរ៉ាវនេះជាមួយនរណាឡើយ មុនពេលត្រៀមលក្ខណៈសម្រាប់ វេទិកានេះ។

**លោកស្រី សុខ សាមិត** (អាយុ៥២ឆ្នាំ) បានជួបប្រទះការបង្ខំឱ្យធ្វើពលកម្មនៅក្នុងកងចល័តស្ត្រីមួយនាសម័យរបបខ្មែរក្រហម។ ក្នុងឆ្នាំ១៩៧៦ លោកស្រីមានអាយុ១៥ឆ្នាំ ហើយគាត់បានឃើញការបង្ខំឱ្យរួមភេទដែលពាក់ព័ន្ធទៅនឹងស្ត្រីជនជាតិវៀតណាមម្នាក់ ឈ្មោះ អ៊ុក អាយុ ២៧ឆ្នាំ។ ស្វាមីរបស់អ៊ុក បម្រើការងារជាទាហានខ្មែរក្រហម ហើយបានធ្វើដំណើរចេញទៅឆ្ងាយមួយរយៈ។ អ៊ុក បានព្យាយាមស្វែងរកព័ត៌មានអំពីស្វាមីរបស់ខ្លួន ដូច្នេះគាត់ក៏បានទៅរកមន្ត្រីស្រុករបស់ខ្មែរក្រហមដែលជាគ្រូទាយម្នាក់។ បុរសអាយុ៥០ឆ្នាំ ដែលមានប្រពន្ធព្រមទាំងមានកូនម្នាក់នេះ បានប្រាប់អ៊ុកថា ត្រូវរួមភេទជាមួយគាត់ដើម្បីទទួលបានព័ត៌មានអំពីប្តី។ ស្ថានភាពបែបនេះបានកើតឡើងជាច្រើនលើកច្រើនសារ ហើយទីបំផុតគាត់ក៏មានផ្ទៃពោះ។ បើទោះបីជាគាត់បានព្យាយាមលាក់បាំងអំពីការដែលគាត់មានផ្ទៃពោះដោយខ្លាចគេដាក់ទោសចំពោះ "អំពើខុសសីលធម៌" យ៉ាងណាក៏ដោយក៏គេនៅតែដឹង អំពីបញ្ហានេះ ហើយគាត់ត្រូវបានគេបញ្ជូនទៅកាន់ពន្ធនាគារ និងធ្វើទារុណកម្ម។ គាត់ត្រូវបានគេបង្ខំឱ្យធ្វើការងារនៅឯស្រែដោយជាប់ខ្នោះជើង និងបានសម្រាលកូននៅក្នុងពន្ធនាគារ។ គេបានដោះលែងអ៊ុក នៅក្នុងឆ្នាំ១៩៧៧ ប៉ុន្តែគាត់ត្រូវបានគេសម្លាប់ដោយសារតែក្រោយមករបបនោះស្វែងរកគោលដៅជាជនជាតិវៀតណាម។

លោកស្រី សាមិត ក៏បានឃើញទិដ្ឋភាពបង្ខំឱ្យរៀបការចំពោះបងស្រីរបស់គាត់ផងដែរ។ បងស្រីរបស់គាត់មានអាយុ ២៤ឆ្នាំ នៅពេលដែលស្វាមីរបស់គាត់បានស្លាប់អស់រយៈពេល ៧ខែ ហើយគាត់ត្រូវបានបង្ខំឱ្យរៀបការជាមួយបុរសម្នាក់ដែលមានអាយុ៦០ឆ្នាំ បើពុំនោះសោតទេ គេបានប្រាប់គាត់ថា "គ្រួសារទាំងមូលនឹងមានបញ្ហា"។ ជាលទ្ធផលនៃការរៀបការ (ជាមួយអ្នកផ្គត់ផ្គង់ភស្តុភានៅក្នុងស្រុក) គ្រួសាររបស់គាត់មានផ្ទះមួយដ៏ល្អសម្រាប់រស់នៅ និងមានអាហារហូបចុក។ នៅពេលដែលបងស្រីរបស់គាត់មានផ្ទៃពោះ គាត់មិនអាចទ្រាំមានកូនបានឡើយ ហើយគាត់បានព្យាយាមរំលូតកូនដោយការវាយពោះរបស់គាត់ និងរមៀលខ្លួនចុះពីលើកូនភ្នំ។ ទីបំផុតបងស្រីគាត់ក៏រលូតកូន។

ក្នុងឆ្នាំ១៩៧៨ លោកស្រី សាមិត ត្រូវបានគេផ្លាស់អោយទៅកងចល័តមួយទៀត។ គាត់មានតែសម្លៀកបំពាក់ចាស់មួយសម្រាប់ប៉ុណ្ណោះ ហើយនៅពេលដែលគាត់បោកសម្លៀកបំពាក់របស់គាត់ គាត់បានឃើញចៃចេញពីក្បាល និងស្បែករបស់គាត់។ គាត់មានការអៀនខ្មាសជាខ្លាំង ដោយសារតែខោគាត់រហែកចេញកេរ្តិ៍ភេទដាក់គេ គាត់ចង់តែ

សម្លាប់ខ្លួនឯងឱ្យស្លាប់ ព្រោះគាត់មានអារម្មណ៍ខ្មាសអៀនខ្លាំងពេក។ នៅក្នុងរបបនោះលោកស្រី សាមិត បានធ្វើការសរុបសេចក្តីជារួមថា ប្រជាជនមិនអាចស្រឡាញ់គ្នាបានឡើយ ហើយប្រសិនបើពួកគេហ៊ានស្រឡាញ់គ្នា ពួកគេនឹងត្រូវគេយកទៅសម្លាប់ចោលមិនខាន។

## ២. ប្រទេសបង់ក្លាដេស

*លោកស្រី ម៉ូណូវ៉ារ៉ា ប៊ីហ្គាំ បម្រើការងារជាមន្ត្រីស៊ើបអង្កេតនៅឯសវនាការឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងប្រទេសបង់ក្លាដេស ហើយលោកស្រី បានបង្ហាញអំពីសាវតារបស់ប្រទេសបង់ក្លាដេស ក្នុងនាមជា CSR។*

*ជម្លោះរបស់បង់ក្លាដេស មានប្រភពចេញពីព្រំប្រទល់ឆ្នាំ១៩៤៧ រវាងប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថានជាមួយនឹងជនជាតិបង់ហ្គាលីកាន់កាប់ "ប៉ាគីស្ថានភាគខាងកើត" រហូតដល់ពេលប្រកាសឯករាជ្យថាជាប្រទេសបង់ក្លាដេស នៅឆ្នាំ១៩៧១។ ឆ្លើយតបចំពោះបញ្ហានេះដែរ ប្រទេសប៉ាគីស្ថានបានដាក់ឱ្យដំណើរការនូវ "ប្រតិបត្តិការផែកឆេរ" ដែលជាលទ្ធផលបណ្តាលឱ្យមាននូវអំពើហិង្សា បំផ្លិចបំផ្លាញរយៈពេល៩ខែ។ អំពើហិង្សាយេនឌ័រត្រូវបានគេប្រើប្រាស់ជាឧបករណ៍សង្គ្រាមមួយដើម្បីរំខានដល់សុច្ចរិតភាពជាតិសាសន៍របស់ជនជាតិបង់ក្លាដេស។ គេប៉ាន់ប្រមាណថាមានស្ត្រី និងកុមារីបង់ហ្គាលីប្រមាណ ២០០.០០០នាក់ ទៅ ៤០០.០០០នាក់ រងគ្រោះ ពីទម្រង់មួយចំនួននៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ (ក្នុងអំឡុងពេលនៃជម្លោះ) រាប់ចាប់ពីការចាប់ពង្រត់ និងការឃុំខ្លួននៅក្នុងជំរុំដើម្បីរំលោភរហូតដល់ការបង្ខំឱ្យមានផ្ទៃពោះ ការរំលូតកូន និងការបញ្ឈប់កំណើត។ ប្រទេសនេះបានប៉ុនប៉ងរៀបចំឱ្យមាននូវដំណើរការយុត្តិធម៌បណ្តោះអាសន្នមួយចំនួន ដែលរួមមានដូចជា ការដែលរដ្ឋាភិបាលបានណែនាំពាក្យ "បីរ៉ង់ហ្គោណា" ដើម្បីកំណត់ ហៅជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ថាជាវីរជនសង្គ្រាម។ ក្នុងឆ្នាំ២០០៩ សវនាការមួយត្រូវបានបង្កើតឡើង ដើម្បីផ្តន្ទាទោសទៅលើឧក្រិដ្ឋជនសង្គ្រាម ប៉ុន្តែគេនៅមានមន្ទិលសង្ស័យមួយចំនួនចំពោះភាពអនុលោមនៃសវនាការនេះ ទៅនឹងបទដ្ឋានកាត់ទោសប្រកបដោយភាពយុត្តិធម៌អន្តរជាតិ ហើយស្ត្រីដែលបានផ្តល់សក្ខីកម្មនៅចំពោះអង្គសវនាការអំពីបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ បានប្រឈមទៅនឹងប្រតិកម្ម និងការសងសឹកនៅឯផ្ទះ និងសហគមន៍របស់ពួកគេ។*

*បើទោះបីជាបទល្មើសផ្លូវភេទបានកើតឡើងជាង៤០ឆ្នាំ កន្លងមកហើយក៏ដោយ ជនរងគ្រោះនៅតែបន្តទទួលរងការឈឺចាប់ពីការម៉ាក់ងាយនៅក្នុងសង្គម ការបាត់បង់សិទ្ធិ ការរស់នៅក្នុងភាពក្រីក្រ និងភាពឯកោ និងកាត់ផ្តាច់ពីសហគមន៍ និងបណ្តាញគាំទ្រនានា។ ផលប៉ះពាល់ជាច្រើនបានកើតឡើងជាពិសេសទៅលើកុមារ ដែលជាមូលហេតុបណ្តាលមកពីការរំលោភសេពសន្ថវៈ។ បើទោះបីជា រដ្ឋាភិបាលបានបង្កើតបទប្បញ្ញត្តិមួយចំនួនស្តីពីសុំកូន? ការរំលូតកូន និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនរងគ្រោះក៏ដោយ បទប្បញ្ញត្តិទាំងនេះបានបញ្ចប់ក្នុងឆ្នាំ ១៩៧៥ ហើយអស់រយៈពេលជាច្រើនឆ្នាំ គឺមានតែភាពស្ងៀមស្ងាត់ប៉ុណ្ណោះ និងគ្មានការ គាំទ្រអ្វីឡើយ។ CSR បានថ្លែងថា "នេះគឺជារឿងរ៉ាវក្រៀមក្រំដ៏វែងឆ្ងាយរបស់ប្រទេសយើង ដែលជនរងគ្រោះត្រូវបានគេបដិសេធសិទ្ធិ របស់ពួកគេអស់រ*

*យៈពេលជាច្រើនឆ្នាំ"។ សវនាការបច្ចុប្បន្ន កំពុងបង្កើនការយល់ដឹងអំពីបញ្ហានេះ ប៉ុន្តែវាមានសារៈសំខាន់ដែលគេមិនត្រូវដោះស្រាយចំពោះតែ "អ្វី" ដែលគួរធ្វើដើម្បីគាំទ្រដល់ជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែ គេក៏គួរគូសបញ្ជាក់អំពី "របៀបធ្វើ" ផងដែរ ដើម្បីឱ្យស្ត្រីមិនទទួលរងការមាក់ងាយ និងបាក់ស្បាតជាថ្មីម្តងទៀត។ ខណៈពេលដែលមានប្រព័ន្ធមួយដើម្បីផ្តល់ កិត្តិយសដល់អ្នកដែល ធ្វើការប្រយុទ្ធប្រឆាំងដើម្បីសេរីភាពរាប់បញ្ចូលទាំង "ប៊ីរ៉ង់ហ្គោណា" និងផ្តល់សំណងនៅក្នុងករណីជាក់លាក់មួយចំនួន CSR បានសួរថា "តើយើងផ្តល់សំណងយ៉ាងដូចម្តេចដល់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទដោយរបៀបណា ?"*

ខ្សែភាពយន្តខ្លីមួយ បានបង្ហាញអំពីអ្នកផ្តល់សក្ខីកម្មនៅក្នុងបរិបទនៃផ្ទះរបស់ពួកគេ ខណៈពេលដែលពួកគេរៀបចំខ្លួនដើម្បីមកប្រទេសកម្ពុជាដើម្បីផ្តល់សក្ខីកម្ម ជាមួយនឹងចំរៀងគាំទ្រពីកូនស្រីដែលមានឈ្មោះ សាឡេហា បេហ្គាំ។



**សាឡេហា បេហ្គាំ** (អាយុ៥៥ឆ្នាំ) មានអាយុ១៤ឆ្នាំ ក្នុងអំឡុងពេលមានជម្លោះ។ លោកស្រី បេហ្គាំ បានពន្យល់ទាំងអារម្មណ៍ក្តុកក្តួលក្នុងចិត្តថា ជីវិតរបស់លោកស្រីពោរពេញទៅដោយការឈឺចាប់។ ទាហានប៉ាគីស្ថានបានជម្លៀសគ្រួសាររបស់គាត់ និងវាយធ្វើបាបគាត់ដោយបន្សល់នូវស្លាកស្នាមពេញរាងកាយរបស់គាត់។ គាត់បានថ្លែងថា ពួកទាហានបានប្រព្រឹត្តសកម្មភាពផ្លូវភេទគ្រប់ប្រភេទមកលើពួកយើង រាប់បញ្ចូលទាំងការរួមភេទតាមរន្ធគូទ ហើយគាត់ក៏បានឃើញនូវទិដ្ឋភាពធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងការសម្លាប់កុមារីជាច្រើននាក់ ក្នុងអំឡុងពេលនៃជម្លោះ។ លោកស្រីបានរត់គេចផុតពីវាលពិឃាតដោយនឹកស្មានមិនដល់ ដោយសារតែលោកស្រីត្រូវបានគេយកទៅជំរុំកងទ័ពមួយ។ នៅក្នុងរយៈពេល២ខែក្រោយមក លោកស្រីត្រូវបានគេរំលោភម្តងហើយម្តងទៀតយ៉ាងសាហាវនៅចំពោះមុខបងប្អូនស្រីគាត់ និងកុមារីដទៃទៀត ដែលនាំឱ្យមានការធ្លាក់ឈាមយ៉ាងធ្ងន់ធ្ងរតាមទ្វារមាស និងមានស្លាកស្នាមអចិន្ត្រៃយ៍។ លោកស្រីបានមានផ្ទៃពោះ និងបានផ្តល់កំណើតក្រោយពេលរំដោះរយៈពេល៤ខែ។ ជាលទ្ធផលគាត់ត្រូវបានសហគមន៍ និងគ្រួសារបោះបង់ចោល។

នៅពេលដែលនិយាយដល់ចំណុចនេះ លោកស្រី បេហ្គាំ មានការរំជួលចិត្តជាខ្លាំង ហើយក៏បានបញ្ចប់សក្ខីកម្មរបស់គាត់។ គាត់បានចាកចេញពីបន្ទប់វេទិកាស្តាប់សម្លេងស្ត្រី ដោយមានអ្នកគាំទ្រផ្នែកចិត្តសាស្ត្រម្នាក់អមដំណើរទៅជាមួយ។

ក្រុមគណៈវិនិច្ឆ័យបានទទួលស្គាល់អំពីផលប៉ះពាល់ដែលបន្តដក់នៅក្នុងជីវិតរបស់លោកស្រី បេហ្គាំ ដែលបណ្តាលមកពីបទពិសោធន៍ដែលគាត់បានជួបប្រទះ។ CSR បានជូនដំណឹងដល់ក្រុមគណៈវិនិច្ឆ័យថា ក្រោយពេលរំដោះ លោកស្រី បេហ្គាំ បានបម្រើការងារជាអ្នកបម្រើតាមផ្ទះ។ ប៉ុន្មានឆ្នាំ ក្រោយមក លោកស្រីក៏បានរៀបអាពាហ៍ពិពាហ៍។

នៅពេលដែលស្វាមីរបស់គាត់បានឃើញស្លាកស្នាមនៅលើរាងកាយរបស់គាត់ គាត់ក៏បានប្រាប់ស្វាមីរបស់គាត់ថា គាត់គឺជាជនរងគ្រោះមួយរូបដែលគេបានរំលោភនាឆ្នាំ១៩៧១។ ស្វាមីរបស់គាត់មានបំណងចង់លែងលះគាត់ ប៉ុន្តែមិនអាចធ្វើទៅបានដោយសារតែគាត់មានផ្ទៃពោះ។ គាត់បានផ្តល់កំណើតឱ្យកូនស្រីម្នាក់។ សាច់ថ្លៃរបស់គាត់បានបោះបង់គាត់ចោល និងបដិសេធមិនព្រមទទួលស្គាល់កូនស្រីរបស់គាត់ ហើយកូនស្រីរបស់គាត់មិនបានជួបជីដូនជីតាខាងឪពុករបស់គាត់រហូតដល់ពេលដែលនាងមានអាយុ១៤ឆ្នាំ។ កូនស្រីរបស់គាត់មានមោទនភាពចំពោះម្តាយរបស់នាងខ្លាំងណាស់ដែលបាននិយាយអំពីបញ្ហានេះ។



**ម៉ូសាម៉ា រ៉ាជា ខាទុន ភាំឡា** (អាយុ៥៥ឆ្នាំ) មានអាយុ១៣ឆ្នាំនៅពេលដែលគាត់ត្រូវបានឪពុកម្តាយរៀបចំឱ្យរៀបអាពាហ៍ពិពាហ៍ ដើម្បីការពារគាត់ពីទាហាន ប៉ាគីស្ថាន និងបានបញ្ជូនគាត់ឱ្យទៅរស់នៅជាមួយសាច់ថ្លៃរបស់គាត់។ នៅពេលដែលទាហានប៉ាគីស្ថានបានធ្វើការវាយប្រហារនៅក្នុងភូមិគាត់ គាត់ និងម្តាយក្មេករបស់គាត់បានរត់គេចទៅក្នុងព្រៃដោយភ័យរន្ធត់ សក់របស់គាត់បានជាប់ទាក់ទៅនឹងដើមឈើ។ នៅថ្ងៃបន្ទាប់ គាត់បានដឹងថា ឪពុករបស់គាត់ និងសាច់ញាតិជាច្រើនដទៃទៀត ត្រូវបានគេសម្លាប់។ នៅក្នុងព្រៃគាត់បានបែកគ្នាពីម្តាយក្មេករបស់គាត់ ហើយរ៉ាហ្សាកាម្នាក់ (ជនជាតិបង់ក្លាដេស ដែលយកការណ៍ឱ្យទាហានប៉ាគីស្ថាន) បានបោកបញ្ឆោតគាត់ឱ្យធ្វើដំណើរទៅកាន់ជំរុំទាហានមួយ។ នៅទីនោះ គាត់ត្រូវបានគេបង្ខំឱ្យដោះសម្លៀកបំពាក់ និងចងជាប់នឹងសសរមួយ។ គាត់ត្រូវបានទាហានចំនួន៦នាក់ រំលោភម្តងម្នាក់ៗ បន្ទាប់មកគេក៏ទុកគាត់ចោលឱ្យជាប់ចំណងនៅនឹងសសរនោះពេញមួយយប់ ហើយទ្វារមាសរបស់គាត់បានហូរឈាម និងមានរបួសជាអចិន្ត្រៃយ៍ដោយសារតែសកម្មភាពផ្លូវភេទ ដ៏កាចសាហាវ។ គាត់ត្រូវបានគេឃុំខ្លួននៅជំរុំអស់រយៈពេល១៥ថ្ងៃ ហើយត្រូវបានគេរំលោភម្តងហើយម្តងទៀត។ នៅពេលដែលជនទាំងនោះមិនអាចរំលោភគាត់តាមទ្វារមាសទៀតបាន ដោយសារតែទ្វារមាសរបស់គាត់មានសភាពហើមខ្លាំងពេក ពួកវាបានរំលោភគាត់តាមរន្ធគូទ និងតាមមាត់ ហើយបញ្ចេញទឹកកាមពេញលើផ្ទៃមុខរបស់គាត់។ នៅពេលដែលគាត់នៅឯជំរុំយោធា គាត់បានឃើញសកម្មភាពរំលោភសេពសន្ថវៈ ការធ្វើទារុណកម្ម និងការកាប់សម្លាប់ជាច្រើនទៀត។

ក្រោយរយៈពេល១៥ថ្ងៃ គេបានបញ្ជាគាត់ឱ្យបោកសំអាតឯកសណ្ឋានកងទ័ពប៉ាគីស្ថាន បើទោះបីជាគាត់ដើរសឹងតែពុំរួច ដោយសារតែការហើម និងរបួសនៅត្រង់រន្ធគូទ និងទ្វារមាសរបស់គាត់ក៏ដោយ។ គាត់បានលាក់ខ្លួននៅក្នុងស្រះមួយលាយឡំនឹងរុក្ខជាតិមានបន្លាមួយចំនួន ហើយនៅពេលដែលទាហានមិនអាចរកគាត់ឃើញ ពួកគេក៏បាញ់កាំភ្លើងទៅក្នុងស្រះ។ គាត់បានហែលទៅជ្រុងម្ខាងទៀតនៃស្រះទាំងគ្មានសម្លៀកបំពាក់ដោយប្រើប្រាស់ឬស្សីមួយដើម។ នៅទីនោះ គាត់បានឃើញផ្ទះរបស់ស្ត្រីចំណាស់ម្នាក់ ហើយអ្នកទាំងពីរក៏បានលាក់ខ្លួនជាមួយគ្នា។ ស្ត្រីចំណាស់ម្នាក់

នោះបានឱ្យផ្លែចេក និងសម្លៀកបំពាក់មួយចំនួនទៅឱ្យគាត់ និងបានប្រាប់គាត់ឱ្យធ្វើដំណើរទៅប្រទេសឥណ្ឌាដើម្បីធ្វើជាជនភៀសខ្លួន។ នៅពេលធ្វើដំណើរតាមផ្លូវជាមួយអ្នកដទៃទៀតទៅប្រទេសឥណ្ឌា គាត់បានឃើញអំពើហិង្សាគួរឱ្យរន្ធត់ជាច្រើនរាប់បញ្ចូលទាំងការរំលោភសេពសន្ថវៈ និងការកាប់សម្លាប់។ ទីបំផុត គាត់ក៏បានជួបអ្នកប្រយុទ្ធដើម្បីសេរីភាពមួយចំនួននៅតាមផ្លូវ។ ពួកគេបានយកគាត់ទៅកាន់កន្លែងមានសុវត្ថិភាពមួយ និងធ្វើការព្យាបាលគាត់។ នៅពេលដែលយុវជននោះបាននាំគាត់ទៅរស់នៅជាមួយគាត់ ស្ត្រីម្នាក់ដែលនៅទីនោះមិនបានអនុញ្ញាតឱ្យគាត់ចូលទៅក្នុងផ្ទះឡើយ។ គាត់បានសម្រាន្តនៅក្នុងក្រោលគោមួយ ដោយពុំមានអាហារទទួលទាន និងបន្តលាក់ខ្លួនដើម្បីជីវិតរស់នៅ។ លោកស្រីបានបន្តទៀតថា *"ក្រោយពេលរំដោះ ខ្ញុំមិនអាចរកការងារធ្វើបានឡើយ ពីព្រោះតាមរយៈស្លាកស្នាមនៅលើខ្លួនរបស់ខ្ញុំ គេដឹងថា ខ្ញុំគឺជាជនរងគ្រោះម្នាក់នៃអំពើរំលោភសេពសន្ថវៈ ហើយគ្មាននរណាផ្តល់អាហារ ឬទីជម្រកដល់ខ្ញុំឡើយ"*។ លោកស្រី មានជីវិតរស់រានដោយការសុំទាន។

ថ្ងៃមួយមានបុរសម្នាក់បានបោកបញ្ឆោតគាត់ឱ្យទៅផ្ទះបនមួយ ដោយនិយាយថា វាគឺជាកន្លែងសម្រាប់ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈដើម្បីទទួលបានជំនួយ។ នៅពេលដំបូងម្ចាស់ផ្ទះបន ដែលមានឈ្មោះថា ស៊ូស៊ីម៉ា គឺជាមនុស្សដែលមានចិត្តល្អយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងអ្នកដទៃទៀតដែលគាត់ធ្លាប់បានសុំឱ្យជួយអាស្រ័យដោយគេបានផ្តល់អាហារ និងទីជម្រកដល់គាត់ ព្រមទាំងអនុញ្ញាតឱ្យគាត់ងូតទឹកថែមទៀតផង។ គេបានផ្តល់ការព្យាបាលរបួសទ្វារមាសរបស់គាត់។ គាត់បានថ្លែងឱ្យដឹងថា *"បន្ទាប់មកទើបខ្ញុំដឹងថាគាត់ព្យាបាលខ្ញុំដើម្បីឱ្យគាត់អាចប្រើប្រាស់ខ្ញុំឱ្យធ្វើជាស្រីបនម្នាក់។"* នៅពេលដែលគាត់បដិសេធមិនព្រមរួមភេទជាមួយភ្ញៀវដំបូងរបស់គាត់ គេបានវាយធ្វើបាបគាត់យ៉ាងសាហាវ។ គេបានបោកបញ្ឆោតគាត់ ហើយគាត់បានបន្តនៅទីនោះរយៈពេល៣ឆ្នាំ ក្រោយមកទើបគាត់បានជួបស្វាមីរបស់គាត់ដែលជាភ្ញៀវម្នាក់។ ក្រោយពេលដែលបានទិញគាត់ពីម្ចាស់ផ្ទះបនរួចមក ស្វាមីរបស់គាត់បានយកគាត់ទៅរស់នៅជាមួយ នៅពេលនោះគាត់បានដឹងថា ស្វាមីរបស់គាត់មានប្រពន្ធម្នាក់ និងកូន ៣នាក់រួចទៅហើយ។ គ្រួសារស្វាមីរបស់គាត់បានបដិសេធមិនព្រមទទួលយកគាត់។ ប៉ុន្តែបើទោះជាដូច្នេះក្តី គាត់បានបន្តរស់នៅ និងផ្តល់កំណើតឱ្យកូនប្រុសចំនួន២នាក់។ ស្វាមីរបស់គាត់បានស្លាប់នៅពេលដែលកូនប្រុសរបស់គាត់នៅមានវ័យក្មេងនៅឡើយក្នុងនោះមានម្នាក់ជាទារក និងម្នាក់ទៀតអាយុ៥ឆ្នាំ។ គាត់ និងកូនរបស់គាត់ ត្រូវបានសាច់ថ្លៃរបស់គាត់បណ្តេញចេញពីផ្ទះ។ ដោយពុំមានកន្លែងទៅ និងមានកូនពីរនាក់ត្រូវចិញ្ចឹម គាត់ក៏បានវិលត្រឡប់ទៅផ្ទះបនវិញ។ គាត់បានថ្លែងឱ្យដឹងថា *"ខ្ញុំនៅតែចងចាំថ្ងៃទាំងនោះ បើទោះបីជារយៈពេល៤០ឆ្នាំ បានកន្លងផុតទៅហើយក៏ដោយ ហើយខ្ញុំនៅតែមិនទាន់ទទួលបានយុត្តិធម៌"*។ ឥឡូវនេះ កូនរបស់គាត់បានធំដឹងក្តីហើយ ប៉ុន្តែពួកគេប្រឈមទៅនឹងការមាក់ងាយនៅក្នុងជីវិតរបស់ពួកគេ ដោយសារតែម្តាយរបស់ពួកគេត្រូវបានគេរំលោភក្នុងអំឡុងពេលនៃចលនារំដោះ។ លោកស្រីបានធ្វើការសរុបសេចក្តីថា *"ខ្ញុំមកទីនេះដើម្បីធ្វើការចែក រំលែកអំពីរឿងរ៉ាវរបស់ខ្ញុំ ប៉ុន្តែ វាពុំមែនត្រឹមតែរឿងរ៉ាវរបស់ខ្ញុំប៉ុណ្ណោះទេ គឺរឿងរ៉ាវរបស់មនុស្សរាប់លាននាក់ ដែលត្រូវបានសម្លាប់ ធ្វើទារុណកម្ម និងរំលោភសេពសន្ថវៈ ក្នុងឆ្នាំ១៩៧១"*។

## ៣. ប្រទេសទីម័រខាងកើត

*ម៉ារ៉ាយ៉ា មែនញ៉ូអែលឡា លឿង ព័រវ៉េរ៉ា ក្នុងនាមជា CSR បានបង្ហាញអំពីសាវតាររបស់ទីម័រខាងកើត។ គាត់កំពុងបម្រើការងារជាមួយ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌បណ្តោះអាសន្ន។*

*យោធារបស់ឥណ្ឌូនេស៊ីបានកាន់កាប់ទីម័រខាងកើត អស់រយៈពេល២៤ឆ្នាំ ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៩៩ ដោយបន្តអំពើហិង្សារហូតដល់ឆ្នាំ២០០២។ ក្នុងអំឡុងពេលនៃការកាន់កាប់ និងជម្លោះទៅលើភាពឯករាជ្យ ការរំលោភបំពានសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ បានកើតឡើងយ៉ាងធ្ងន់ធ្ងរ ក្នុងនោះរួមមានដូចជា ហិង្សាយេនឌ័រដែលបានកើតឡើងយ៉ាងទូលំទូលាយ ដែលមានស្ត្រីជាច្រើនត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងរំលោភសេពសន្ថវៈ។ ជនល្មើសភាគច្រើនគឺជាសមាជិកនៃកងកម្លាំងសន្តិសុខឥណ្ឌូនេស៊ី ហើយជនរងគ្រោះភាគច្រើនគឺជាជនស៊ីវិលដែលពុំមានទំនាក់ទំនងច្បាស់លាស់ទៅនឹងការប្រឆាំងនេះ។ តុលាការសិទ្ធិមនុស្សមួយត្រូវបានបង្កើតឡើងដោយប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ២០០០ ដើម្បីកាត់ទោសទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ក្នុង ឆ្នាំ១៩៩៩ ហើយរាល់ការផ្តន្ទាទោសទាំង៦ នៃករណីចោទប្រកាន់ទាំង១៨ ត្រូវបានសម្រេចឱ្យរួចទោសនៅពេលប្តឹងឧទ្ធរណ៍។*

*គណៈកម្មការទទួលបណ្តឹង ស្វែងរកការពិត និងសម្រុះសម្រួល (CAVR, 2002-2005) ត្រូវបានបង្កើតឡើងដើម្បី ធ្វើការស្រាវជ្រាវ និងចងក្រងឯកសារអំពីករណីរំលោភបំពានពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៩៩។ គណៈកម្មការនេះ បានចងក្រងឯកសារចំនួន៨៥៣ករណីនៃអំពើហិង្សាផ្លូវភេទ ដែលក្នុងនោះរួមមាន ៣៩៣ ជាករណីរំលោភសេពសន្ថវៈ , ២២៩ ជាករណីទាសភាពផ្លូវភេទ និង ២៣១ករណី ទៀត ជាទម្រង់ដទៃនៃអំពើហិង្សាផ្លូវភេទ ដូចជាការបង្ខំឱ្យពន្យាកំណើត ការធ្វើទារុណកម្មទៅលើស្ត្រីមានផ្ទៃពោះដែលបណ្តាលឱ្យរលូតកូន និងការបង្ខំឱ្យរំលូតកូន។ CARV ដែលជាយន្តការក្រៅប្រព័ន្ធតុលាការមួយ បានខិតខំពង្រីកគោលដៅរបស់ខ្លួនដើម្បីគ្របដណ្តប់ទៅលើជនរងគ្រោះជាស្ត្រីព្រមទាំងបានរៀបចំវេទិកាស្តីពីការស្តាប់សម្លេងស្ត្រីរងគ្រោះ និងសាក្សី ដើម្បីចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេ។ វាក៏បានបញ្ចូលជំពូកមួយស្តីពីហិង្សាផ្លូវភេទទៅក្នុងរបាយការណ៍ផ្លូវការរបស់ខ្លួនអំពីបញ្ហាជម្លោះដែលរបាយ-ការណ៍នេះ ត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ២០០៥។ បន្ថែមពីនេះទៀត គណៈវិនិច្ឆ័យពិសេសមួយសម្រាប់ឧក្រិដ្ឋកម្មកម្រិតធ្ងន់ (UNTAET) ដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ ក្នុងឆ្នាំ២០០០ មានអាណត្តិការងារដើម្បីធ្វើការស៊ើបអង្កេតសំដៅគាំទ្រដល់ការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងរហូតត្រឹមឆ្នាំ១៩៩៩ប៉ុណ្ណោះ។ បើទោះបីជាបទល្មើសផ្លូវភេទបានទទួលការយកចិត្តទុកដាក់ពិសេស នៅក្នុងការស៊ើបអង្កេតក៏ដោយ UNTAET នៅខ្វះយុទ្ធសាស្ត្រយេនឌ័រច្បាស់លាស់មួយ ជំនាញឯកទេសផ្នែកយេនឌ័រ និងទំនាក់ទំនងសហការជាមួយក្រុមស្ត្រីសង្គមស៊ីវិល។ ក្នុងចំណោមដីកាចោទប្រកាន់ចំនួន៩៥ មានតែ៨ប៉ុណ្ណោះដែលបានបញ្ចូលបទល្មើសយេនឌ័រ។ សរុបមកមានតែជនត្រូវចោទមួយរូបប៉ុណ្ណោះ ដែលត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ និងជនត្រូវចោទម្នាក់ទៀតដែលត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ក្នុងលក្ខណៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ពុំមានជនជាប់ចោទណាម្នាក់ ត្រូវបានចោទប្រកាន់ពីប្រភេទដទៃទៀតនៃហិង្សាយេនឌ័រឡើយ ដូចជាទាសសភាពផ្លូវភេទ។ លោកស្រី*

*លឿង ព័ររ៉ោ បានសង្កត់ធ្ងន់ថា **យុត្តិធម៌ពុំមែនត្រឹមតែជាតែដាក់ទណ្ឌកម្មប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវរាប់បញ្ចូលសេចក្តីត្រូវការជាបន្ទាន់ដើម្បីធ្វើការផ្តល់សំណង និងកម្មវិធីរបស់រដ្ឋាភិបាលសម្រាប់ជនរងគ្រោះ ដើម្បីគាំទ្រឱ្យមាននូវជីវិតរស់នៅមួយប្រកបដោយភាពថ្លៃថ្នូរ។***



*អ្នកផ្តល់សក្ខីកម្មមកពីទីម័រខាងកើត៖ អ៊ុលហ្គា ឌីស៊ីលវ៉ា អាម៉ារ៉ាល់ ( ទីពីររាប់ពីខាងស្តាំ )*
*និងម៉ារ៉ាយ៉ា ហ្វាទីម៉ា ( ខាងស្តាំចុងគេបំផុត )*



**ម៉ារ៉ាយ៉ា ហ្វាទីម៉ា** (អាយុ៥៧ឆ្នាំ) គឺជាជនរងគ្រោះមួយរូបនៃជម្លោះឆ្នាំ១៩៧៥។ នៅពេលនោះគាត់គឺជាសមាជិកមួយរូបរបស់អង្គការស្រ្តីមួយដែលផ្តល់ការគាំទ្រជូនដល់ក្រុមប្រឆាំង ហើយបងប្អូនប្រុសរបស់គាត់ទាំងពីរនាក់បានចូលរួមនៅក្នុងកងកម្លាំងប្រឆាំង ក្នុងនោះមានម្នាក់ជាមេបញ្ជាការ។ ក្រោយការទន្ទ្រានពីកងកម្លាំងឥណ្ឌូនេស៊ីគាត់ត្រូវបានគេចាប់ខ្លួន និងសួរចម្លើយម្តងហើយម្តងទៀត ហើយត្រូវបានគេវាយធ្វើបាបជាញឹកញាប់។ ក្នុងឆ្នាំ ១៩៧៦ គាត់ត្រូវបានគេចាប់ខ្លួនដើម្បីសួរចម្លើយជាថ្មីម្តងទៀត ហើយក្រោយមកក៏ត្រូវគេរំលោភ។ ២ថ្ងៃក្រោយមក កងកម្លាំងសន្តិសុខបាននាំខ្លួនគាត់ទៅកាន់សណ្ឋាគារមួយ។ នៅពេលដែលលោកស្រីទៅដល់មានស្រ្តីម្នាក់ទៀតនៅទីនោះរួចទៅហើយ បន្ទាប់មកស្រ្តីទាំងពីរនាក់ត្រូវបានគេធ្វើទារុណកម្ម និងរំលោភម្តងហើយម្តងទៀត នៅក្នុងបន្ទប់តែមួយ ហើយពួកគេត្រូវបានមេបញ្ជាការបង្ខំឱ្យធ្វើសកម្មភាពផ្លូវភេទដទៃទៀតជាមួយទាហានផ្សេងទៀត។ គាត់និងស្រ្តីទាំងនេះ ក៏ត្រូវបានគេបង្ខំឱ្យរួមភេទជាមួយទាហានទីម័រ ដែលចេញពីធ្វើការប្រយុទ្ធនៅក្នុងព្រៃ ហើយខណៈពេលដែលការប្រយុទ្ធកាន់តែមានភាពធ្ងន់ធ្ងរ ហិង្សាផ្លូវភេទក៏កាន់តែមានភាពធ្ងន់ធ្ងរដូចគ្នាផងដែរ។ លោកស្រី ហ្វាទីម៉ា បានថ្លែងអំពីទំនាក់ទំនងរបស់គាត់ជាមួយស្រ្តីដទៃទៀតដែលត្រូវបានគេប្រើប្រាស់ជាទាសករ ដូចគ្នាផងដែរ *"យើងបានឱបគ្នាទៅវិញទៅមក ហើយយើងបានទ្រហោយំ។ យើងមិនដឹងថា ត្រូវធ្វើអ្វីឡើយ។ យើងគ្មានគ្រួសារគ្មានបងប្អូនប្រុស គ្មានស្វាមី*

*ដូច្នេះយើងមានតែត្រូវទទួលយក។ ប្រសិនបើយើងមិនព្រមទទួលយកទេនោះគេនឹងសម្លាប់យើង"* ។ ទីបំផុត គាត់ត្រូវបានគេដោះលែង ហើយធ្លាក់ខ្លួនមានផ្ទៃពោះ ប៉ុន្តែគាត់បានចងចាំនូវបទពិសោធន៍មួយនេះ។ ក្នុងឆ្នាំ១៩៨៣ មេបញ្ជាការឥណ្ឌូនេស៊ីម្នាក់បានអំពាវនាវរកគាត់ និងបានសួរគាត់ជាថ្មីម្តងទៀត ថាតើគាត់គាំទ្រដល់កងកម្លាំងប្រឆាំងដែរឬទេ និងបានចោទប្រកាន់គាត់ថានិយាយកុហក។ បើទោះបីជាគាត់មានផ្ទៃពោះក៏ដោយ គាត់នៅតែត្រូវបានគេធ្វើទារុកណកម្ម និងរំលោភ។

ដើម្បីសង្គ្រោះខ្លួនឯង និងកូនរបស់គាត់ដែលមានអាយុ៦ខែ គាត់បានយល់ព្រមរៀបការជាមួយមេបញ្ជាការជនជាតិឥណ្ឌូនេស៊ីម្នាក់ ប៉ុន្តែជាក់ស្តែងគាត់ត្រូវបានគេបង្ខំឱ្យធ្លាក់ខ្លួនទៅក្នុងទាសភាពផ្លូវភេទទៅវិញ។ ចាប់ពីឆ្នាំ១៩៨៣ រហូតដល់ឆ្នាំ១៩៨៧ គាត់ត្រូវបានគេចាប់ខ្លួនជារៀងរាល់យប់ និងដោះលែងមកវិញនៅរៀងរាល់ពេលថ្ងៃ។ ទីបំផុតគាត់បានផ្តល់កំណើតដល់កូនចំនួន៤នាក់ ដែលកូននីមួយៗសុទ្ធសឹងតែមានឪពុកខុសគ្នាៗ។ បច្ចុប្បន្ន ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរចំពោះបទពិសោធន៍ដែលគាត់បានជួបប្រទះនៅតែបន្តមាន និងបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់ទៅលើកូនរបស់គាត់។ គាត់បានថ្លែងឱ្យដឹងថា *"នៅពេលដែលកូនរបស់ខ្ញុំសួរថា តើឪពុករបស់យើងជានរណា ខ្ញុំបាននិយាយកុហក និងរក្សាអាថ៌កំបាំងនេះ ដោយប្រាប់ពួកគេថា ឪពុករបស់ឯងគឺជាទាហានម្នាក់ ហើយគាត់បានស្លាប់បាត់ទៅហើយ"* ។ ដោយសារតែគាត់មិនស្គាល់ត្រកូលរបស់ឪពុកនៃកូនរបស់គាត់ ទើបគាត់ទើបតែបានទទួលសំបុត្រកំណើតកូនរបស់គាត់មុនមកប្រទេសកម្ពុជាតែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីគាត់បានខិតខំព្យាយាមអស់រយៈពេលជាច្រើនឆ្នាំកន្លងមក។ នៅពេលមួយ គាត់ត្រូវបានគេចុះចាប់ដល់ផ្ទះដោយត្រូវបានគេចោទប្រកាន់ថា ជាស្ត្រីពេស្យាសម្រាប់កងកម្លាំងឥណ្ឌូនេស៊ី ហើយគេបានដកហូតយកដីធ្លីរបស់គាត់អស់។ កូនប្រុសរបស់គាត់មិនអាចរកការងារធ្វើបានឡើយ ហើយគាត់បន្តការរស់រានរបស់គាត់ដោយការលក់នំ ដើម្បីបង់ថ្លៃសាលារៀនរបស់ពួកគេ។

**អ៊ីលហ្គា ឌីស៊ីលវ៉ា អាម៉ារ៉ាល់** (អាយុ ៤៧ឆ្នាំ) គឺជាកុមារី ដែលមានអាយុ ១០ឆ្នាំ នៅសម័យសង្គ្រាមដើម្បីឯករាជ្យ ឆ្នាំ១៩៧៥ ហើយគាត់បានរស់នៅជាមួយឪពុកម្តាយរបស់គាត់នៅក្នុងព្រៃ។ ក្នុងឆ្នាំ១៩៧៨ គ្រួសាររបស់គាត់ ត្រូវបានកងកម្លាំងឥណ្ឌូនេស៊ីចាប់ខ្លួនដោយចោទប្រកាន់ពីបទគាំទ្រដល់ចលនាប្រឆាំង ហើយពួកគេក៏បានបែកគ្នា។ គាត់បានធ្វើការងារជាអ្នកបម្រើក្នុងផ្ទះសម្រាប់មេបញ្ជាការជនជាតិឥណ្ឌូនេស៊ីម្នាក់ រហូតដល់ឆ្នាំ១៩៧៩ ដែលនៅពេលនោះ ឪពុករបស់គាត់បានរកឃើញគាត់ និងបញ្ជូនគាត់ទៅសាលារៀន។ ក្នុងឆ្នាំ១៩៨០ គាត់បានឈប់រៀន រៀបអាពាហ៍ពិពាហ៍ និងចាប់ផ្តើមគ្រួសារមួយ។ មួយឆ្នាំកន្លងមក គាត់បានបង្កើតក្រុមស្ត្រីមួយនៅក្នុងភូមិដើម្បីគាំទ្រដល់ចលនាប្រឆាំង។ ក្នុងឆ្នាំ១៩៨២ អ្នកយកការណ៍របស់ទីម័រមួយរូប បានជូនដំណឹងដល់កងកម្លាំងឥណ្ឌូនេស៊ី អំពីសកម្មភាពនៅក្នុងភូមិ។ ក្រុមបុរសត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយឡែក ក្រុមស្ត្រីត្រូវបានបញ្ជូនទៅប៉ុស្តិ៍បញ្ជាការរងយោធា។ ក្រុមស្ត្រីត្រូវបានឃុំខ្លួននៅឯសាលារៀនមួយ ហើយពួកគេត្រូវបានសួរចម្លើយ ធ្វើទារុណកម្ម និងរំលោភម្តងហើយម្តងទៀត។ ស្ត្រីមួយចំនួនគឺជាស្ត្រីមានផ្ទៃពោះស្ត្រីមួយចំនួនគឺជាស្ត្រីមានកូន និងអ្នកមួយចំនួនទៀតគឺជាក្មេងស្រី។

ទីបំផុតគាត់បានរត់គេចខ្លួនរួច ហើយដោយមានជំនួយពីអាចារ្យមួយរូបគាត់ក៏បានវិលត្រឡប់ទៅសាលារៀនវិញ។

នៅពេលរសៀលមួយ គាត់ត្រូវបានកងកម្លាំងយោធា ចំនួន៤នាក់ចាប់ខ្លួនបញ្ជូនទៅមជ្ឈមណ្ឌលបញ្ជាការដ្ឋានយោធា ដែលនៅទីនោះគាត់ត្រូវបានគេវាយធ្វើបាប សួរចម្លើយ និងរំលោភជារឿងរាល់យប់រាប់បញ្ចូលទាំងការឆក់ខ្សែភ្លើងផងដែរ។ គាត់តែងត្រូវបានគេវាយធ្វើបាប និងរំលោភរហូតដល់សន្លប់។ គាត់ពុំមែនត្រូវបានគេឃុំខ្លួនតែម្នាក់ឯងនោះទេ ប៉ុន្តែគាត់ត្រូវបានគេឃុំខ្លួនជាមួយមិត្តភក្តិរបស់គាត់ជាស្ត្រីជាច្រើនដទៃទៀត ហើយសូម្បីតែបងប្រុសរបស់គាត់ ក៏ត្រូវបានគេឃុំនៅឯមណ្ឌលឃុំឃាំងតែមួយដែរ ដោយបងប្រុសរបស់គាត់ក៏ត្រូវបានគេសួរចម្លើយ វាយធ្វើបាប និងចុងក្រោយត្រូវបានគេយកទៅសម្លាប់។ គាត់បានថ្លែងនៅពេលនោះថា *"ខ្ញុំមិនអាចគេចខ្លួនបានឡើយ ដូច្នេះខ្ញុំត្រូវតែទទួលយកអ្វីៗគ្រប់យ៉ាងដែលគេធ្វើមកលើខ្ញុំ"*។ សកម្មភាពបែបនេះ បានបន្តអស់រយៈពេល៣ខែ។ ក្រោយមក គាត់ត្រូវបានគេដោះលែង ប៉ុន្តែគាត់នៅតែបន្តរស់នៅក្បែរជំរុំមូលដ្ឋានយោធាដោយមិនអាចទៅកន្លែងណាទៀតបាន។ នៅពេលថ្ងៃគេយកគាត់ទៅសាលារៀន ប៉ុន្តែនៅពេលយប់គាត់ត្រូវបានគេបង្ខំឱ្យនៅជាមួយទាហានឥណ្ឌូនេស៊ី។ ការធ្វើទារុណកម្មនៅពេលសួរចម្លើយ រួមមានដូចជា ការយកបារីអុជ ការឆក់ខ្សែភ្លើង ការរំលោភម្តងហើយ ម្តងទៀត និងការបង្ខំឱ្យស្បថដោយការផឹកឈាមថានឹងមិនទម្លាយការសម្ងាត់អំពីអ្វីដែលបានកើតឡើងចំពោះគាត់។ គាត់ក៏ត្រូវបានគេបង្ខំឱ្យកាន់ក្បាលឪពុកក្មេករបស់គាត់ដែលគេបានកាត់ផងដែរ។ នៅពេលនោះ គាត់បានទទួលរងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលគាត់មិនអាចទ្រាំបាន។



ក្នុងឆ្នាំ១៩៨៣ គាត់ត្រូវបានគេដោះលែងឱ្យត្រលប់ទៅផ្ទះវិញ។ ឪពុកម្តាយរបស់គាត់ចំណាំគាត់មិនបានឡើយដោយសារតែគាត់មានរបួសនៅលើខ្លួនច្រើនពេក។ លោកស្រី អាម៉ារ៉ាល់ បានថ្លែងឱ្យដឹងថា "ឪពុករបស់ខ្ញុំបានសួរថាហេតុអ្វីបានជារូបរាងឯងក្លាយទៅជាបែបនេះ?" ខ្ញុំបានឆ្លើយតបទៅវិញថា "ពុក...នេះហើយគឺជាសង្គ្រាម"។ គាត់បានធូរស្បើយបន្តិចម្តងៗជាមួយនឹងការព្យាបាលដោយឱសថបុរាណ ហើយក៏បានវិលត្រឡប់ទៅសាលារៀនវិញ។ ស្វាមីរបស់គាត់ត្រូវបានឃុំខ្លួន ហើយសាច់ថ្លៃរបស់គាត់មិនព្រមទទួលយកគាត់ឡើយ ដោយសារតែគាត់ត្រូវបានគេចាត់ទុកថាជាប្រពន្ធរបស់ទាហានឥណ្ឌូនេស៊ី។ នៅពេលដែលស្វាមីរបស់គាត់ត្រូវបានដោះលែង ក្នុងឆ្នាំ១៩៨៥ ពួកគេបានពិភាក្សាជាមួយអាចារ្យម្នាក់អំពីអ្វីដែលបានកើតឡើងចំពោះពួកគេម្នាក់ៗ ហើយគាត់បានប្រាប់ស្វាមីរបស់គាត់អំពីរឿងរ៉ាវគ្រប់យ៉ាង។ លោកអាចារ្យបានសួរថាតើស្វាមីរបស់គាត់នៅតែព្រមទទួលយកគាត់ជាភរិយាដែរឬទេ ហើយស្វាមីរបស់គាត់បាននិយាយថា "ព្រម"។ គូស្វាមីភរិយានេះ បានខិតខំអស់រយៈពេល១០ឆ្នាំ ដើម្បីមានកូន ក្រោយមកទើបពួកគេបានទៅជួបវេជ្ជបណ្ឌិត ដោយវេជ្ជបណ្ឌិតបាននិយាយថាអវយវៈបន្តពូជរបស់គាត់អាចទទួលរងការខូចខាតពីការធ្វើទារុណកម្ម និងការរំលោភ។ ទីបំផុត ជាមួយនឹងការព្យាបាលដោយឱសថបុរាណ គាត់បានមានកូន៤នាក់ (កូនមួយចំនួនធ្វើឱ្យគាត់មានការពិបាកក្នុងការកើតជាខ្លាំង) ហើយគាត់ និងស្វាមីរបស់គាត់បន្តគាំទ្រគ្នាទៅវិញទៅមក បើទោះបីជាពួកគេបានទទួលរងទម្រង់ផ្សេងៗគ្នានៃអំពើហិង្សានៅពេលមានសង្គ្រាមក៏ដោយ។

## ៤. ប្រទេសនេប៉ាល់

***លោកស្រី មែនឌីរ៉ា សាម៉ា*** *ប្រធានវេទិកាតស៊ូមតិនៃប្រទេសនេប៉ាល់ បានថ្លែងអំពីសាវតានៃជម្លោះ និងបរិបទនៅក្នុងប្រទេសនេប៉ាល់។*

*ចាប់ពីឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ២០០៦ គណបក្សកុម្មុយនិស្តនៃប្រទេសនេប៉ាល់ បានរៀបចំឱ្យមាននូវចលនាលទ្ធិម៉ៅ ដ៏ទូលំទូលាយមួយ ដែលបណ្តាលឱ្យមានជម្លោះមួយនៅក្នុងប្រទេសនេប៉ាល់ ដោយជម្លោះនេះត្រូវបានគេស្គាល់ថា ជាសង្គ្រាមស៊ីវិល។ ស្ត្រីប្រមាណ ២០%ដែលបានចូលរួមធ្វើការប្រយុទ្ធនៅក្នុងសង្គ្រាមនេះ។ កងកម្លាំងលទ្ធិម៉ៅ និងកងកម្លាំងនេប៉ាល់បានបណ្តាលឱ្យមានការរំលោភបំពានយ៉ាងទូលំទូលាយ ក្នុងនោះរួមមានដូចជាហិង្សាយេនឌ័រក្នុងទម្រង់ជាការរំលោភសេពសន្ថវៈ ការបង្ខំឱ្យរំលូតកូន ការរំលោភ បំពានផ្លូវភេទ ការធ្វើទារុណកម្ម ព្រមទាំងការរំលោភបំពានដទៃទៀត។ បច្ចុប្បន្ន ជនរងគ្រោះជាច្រើនទាំងអស់នេះ បន្តរស់នៅជាមួយ ការមាក់ងាយក្នុងសង្គមដោយភាពស្ងៀមស្ងាត់ និងមិនចែករំលែកបទពិសោធន៍របស់ពួកគេ សូម្បីតែជាមួយសមាជិកគ្រួសាររបស់ពួកគេដែលជិតស្និទ្ធបំផុត។ អាស្រ័យដោយ ៧០% នៃឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយតួអង្គរដ្ឋ និង៣០% ទៀត ប្រព្រឹត្តដោយកងកម្លាំងលទ្ធិម៉ៅ បណ្តាលឱ្យជនរងគ្រោះមានការលំបាក ជាពិសេសក្នុងការទាមទារដំណោះស្រាយចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកងកម្លាំងលទ្ធិម៉ៅ។ យ៉ាងណាមិញ ជាលទ្ធផលនៃបទពិសោធន៍របស់ពួកគេប្រជាជនគ្រប់រូបសុទ្ធសឹងតែបានជួបប្រទះឧបសគ្គធ្ងន់ធ្ងរផ្នែកនយោបាយសង្គម និងច្បាប់។ កិច្ចព្រមព្រៀងសន្តិភាពគ្រប់ជ្រុងជ្រោយមួយ (CPA) ក្នុងឆ្នាំ២០០៦ បានបញ្ចប់ជម្លោះនេះ និងសន្យាថានឹងបង្កើតគណៈកម្មការស្វែងរកការពិត និងសម្រុះសម្រួលជាន់ខ្ពស់មួយ (TRC) គណៈកម្មការស្វែងរកជនដែលបានបាត់ខ្លួន និងគណៈកម្មការសន្តិភាព និងស្តារនីតិសម្បទាជាតិ។ សេចក្តីព្រាងច្បាប់បានគូសបញ្ជាក់ឱ្យដឹងថា អំពើរំលោភសេពសន្ថវៈ និងហិង្សាផ្លូវភេទនឹងត្រូវបានរាប់បញ្ចូល ហើយពុំមានជនជាប់ចោទណាម្នាក់អាចរួចខ្លួនបានឡើយ ប្រសិនបើពួកគេគឺជាអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មកម្រិតធ្ងន់ រាប់បញ្ចូលទាំងអំពើរំលោភសេពសន្ថវៈផងដែរ។ បើទោះជាដូច្នេះក្តី រដ្ឋាភិបាលពុំបានបញ្ចូលគម្រោងផ្តល់សំណងសម្រាប់ជនរងគ្រោះហិង្សាផ្លូវភេទទៅក្នុងកម្មវិធីផ្តល់ជំនួយសង្គ្រោះរបស់ខ្លួនឡើយ ហើយស្ត្រីដែលមានកូនបណ្តាលមកពីអំពើរំលោភសេពសន្ថវៈបានទទួលរងការមាក់ងាយ ជាពិសេសបណ្តាលមកពីឥរិយាបថវប្បធម៌ជុំវិញបញ្ហាការមានផ្ទៃពោះក្រៅអាពាហ៍ពិពាហ៍។ កុមារជាច្រើនមិនអាចទទួលបានអត្តសញ្ញាណប័ណ្ណឡើយ ដែលចំណុចនេះ មានអត្ថន័យស្មើគ្នាទៅនឹង "ការស្លាប់របស់ជនស៊ីវិល"។ ផ្ទុយទៅវិញ ពុំមានជនល្មើសណាម្នាក់ត្រូវបានផ្តន្ទាទោសឡើយ។*



**ស្វានទី ហាម៉ាល់** (អាយុ៤២ឆ្នាំ) ត្រូវបានកងទ័ពនេប៉ាល់រំលោភ និងបៀតបៀន។ ថ្ងៃមួយនៅពេលដែលគាត់កំពុងនៅផ្ទះជាមួយម្តាយរបស់គាត់ ពួកទាហានបានគំរាមកំហែង និងវាយដំមកលើគាត់ និងម្តាយរបស់គាត់។ គេបានយកក្រណាត់រុំភ្នែកគាត់ និងភ្ជង់កាំភ្លើងដោយអោយគាត់ដើរអស់រយៈពេល២ម៉ោងទៅកាន់បន្ទាយកងទ័ព។ នៅទីនោះ គាត់ត្រូវបានគេចាក់សោទុកនៅក្នុងបន្ទប់មួយ ពួកទាហានបានរំលោភគាត់ម្តងហើយម្តងទៀតយ៉ាងសាហាវឃោឃៅរហូតដល់គាត់ហូរឈាមពីទ្វារមាសឥតឈប់។ ទីបំផុត នៅពេលដែលគេដោះលែងគាត់គេបានបោះ

គាត់ចោលនៅតាមផ្លូវហើយគាត់ត្រូវបានជនល្មើសជាច្រើននាក់ទៀតរំលោភរហូតដល់សន្លប់។ គាត់មានអារម្មណ៍ថា ក្រោយពេលដែលបានឆ្លងកាត់នូវបទពិសោធន៍ទាំងអស់នេះ គាត់មិនអាចប្រឈមមុខជាមួយអ្នកភូមិរបស់គាត់បានទៀតឡើយ។ ការធ្វើសក្ខីកម្មនៅថ្ងៃនេះ គាត់បានថ្លែងឱ្យដឹងថា *"ខ្ញុំគិតថា ខ្ញុំគឺជាមនុស្សម្នាក់គត់ដែលបានជួបប្រទះនូវរឿងហេតុទាំងអស់នេះ ប៉ុន្តែនៅពេលដែលខ្ញុំមកទីនេះ ខ្ញុំបានឃើញមនុស្សជាច្រើននៅទីនេះដែលបានជួបប្រទះរឿងរ៉ាវដូចខ្ញុំដែរ។ ខ្ញុំមានកូនស្រីតូចម្នាក់។ តើពួកយើងនឹងរស់ដោយរបៀបណា? តើកូនស្រីរបស់ខ្ញុំនឹងរស់ដោយរបៀបណា? ជួនកាលខ្ញុំគិតថា ប្រសិនបើគេសម្លាប់ខ្ញុំប្រហែលជាល្អជាង"*។ រហូតមកទល់នឹងសព្វថ្ងៃនេះ គាត់នៅតែកំពុងខិតខំរកប្រាក់ដើម្បីបង់ថ្លៃព្យាបាលវេជ្ជសាស្ត្រសម្រាប់របួសសរីរាង្គបន្តពូជរបស់គាត់ ហើយគាត់ត្រូវបង្ខំលក់ដីរបស់គាត់ក្នុងឆ្នាំ ២០០៥ ដើម្បីបង់ថ្លៃវះកាត់ក្នុងការយកស្បូនរបស់គាត់ចេញ។

*គាត់បញ្ចប់សក្ខីកម្មរបស់គាត់ជាមួយនឹងអារម្មណ៍ក្តុកក្តួល ហើយគាត់បានទទួលការគាំទ្រពីបុគ្គលិកផ្នែកចិត្តសាស្ត្រ។*



**ហ្វុល ចាណាគី រ៉ាណា** (អាយុ២៣ឆ្នាំ) ត្រូវបានគេរំលោភក្នុងឆ្នាំ២០០៦ នៅពេលដែលគាត់មានអាយុ ១៦ឆ្នាំ។ នៅក្នុងភូមិរបស់គាត់មានក្រុមទាហានបះបោរលទ្ធិម៉ៅជាច្រើនម្តងៗមានប្រមាណពី ៤០ ទៅ ៥០ក្រុម ដែលបានមកធ្វើការកាន់កាប់ទៅលើផ្ទះអ្នកភូមិ។ ថ្ងៃមួយនៅពេលដែលគាត់កំពុងនៅឯផ្ទះពូរបស់គាត់ ពួកទាហានលទ្ធិម៉ៅបានចាប់យកគាត់ទៅកាន់ទីវាលមួយ និងរំលោភគាត់អស់រយៈពេលប្រមាណ២-៣ម៉ោង។ នៅពេលដែលគាត់ខិតខំរើបំរាស់កាន់តែខ្លាំង គាត់ត្រូវបានគេវាយធ្វើបាបកាន់តែខ្លាំង។ ទីបំផុត នៅពេលដែលគាត់រត់គេចខ្លួនបាន គាត់បានវិលត្រឡប់មកជួបឪពុកម្តាយរបស់គាត់វិញ និងប្រាប់ឪពុកម្តាយរបស់គាត់អំពីអ្វីដែលបានកើតឡើង។ ជនល្មើសត្រូវបានចាប់ខ្លួនសារភាពអំពីទោសកំហុសរបស់ពួកគេ និងត្រូវបានគេវាយដំ។ ពួកទាហានទាំងនោះបានចាកចេញពីគណបក្សលទ្ធិម៉ៅ និងសន្យាថាឈប់ធ្វើបែបនេះទៀត។ គាត់បានឃើញថា អំពើរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ បានកើតឡើងចំពោះក្មេងស្រីជាច្រើននៅក្នុងភូមិរបស់គាត់។ បច្ចុប្បន្ន គាត់ត្រូវបានចាត់ទុកថាជាមនុស្សដែល "មិនអាចរៀបការបាន" និងពុំមានប្រាក់សម្រាប់ការព្យាបាលវេជ្ជសាស្ត្រ។ រ៉ាណា បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ដោយថ្លែងថា គាត់បានទទួលការលើកទឹកចិត្តយ៉ាងខ្លាំងពីស្ត្រីដទៃទៀតដែលកំពុងចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេនៅឯវេទិកានេះ។

*ដោយមានការស្នើសុំពីក្រុមគណៈវិនិច្ឆ័យ CSR បានផ្តល់នូវសារតាបន្ថែមទៀត អំពីស្ថានភាពរបស់អ្នកផ្តល់សក្ខីកម្មទាំងពីរនាពេលបច្ចុប្បន្ននេះ។ សម្រាប់លោកស្រី ហាម៉ាល់ អ្វីដែលគាត់បានជួបប្រទះ បានបង្កឱ្យមាននូវផលប៉ះពាល់ចំពោះជីវិតរបស់គាត់ទាំងមូល ជាពិសេសគឺចំពោះការអប់រំ និងជីវភាពរស់នៅរបស់គាត់។ រ៉ាណា ក៏បានទទួលរងផលប៉ះពាល់យ៉ាងជ្រាលជ្រៅផងដែរ ហើយគាត់បានចាកចេញឆ្ងាយពីភូមិកំណើតរបស់គាត់ ដើម្បីគេចពីការមាក់*

ងាយ ហើយបច្ចុប្បន្ននេះគាត់កំពុងព្យាយាមចងក្រងជនរងគ្រោះជាស្ត្រី និងក្មេងស្រីដទៃទៀត ដើម្បីចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេ។ គេបានសុំគាត់រៀបការប៉ុន្មានដងដែរ ប៉ុន្តែនៅពេលដែលគេបានដឹងអំពីប្រវត្តិរបស់គាត់ មង្គលការនោះក៏ត្រូវបានលុបចោលវិញ។ លោកស្រី ហាម៉ាល់ បានប៉ុនប៉ងស្វែងរកយុត្តិធម៌ក្នុងប្រព័ន្ធជាផ្លូវការចំនួន ២ដង ហើយករណីរបស់គាត់គឺជាករណីមួយក្នុងចំណោមករណីដំបូងគេបង្អស់ដែលត្រូវបញ្ជូនទៅឱ្យនគរបាល។ នគរបាលបានបដិសេធក្នុងការធ្វើពាក្យបណ្តឹង ដោយបានលើកឡើងនូវអំណះអំណាងថា អាជ្ញាយុកាលដែលមានរយៈពេល ៣៥ថ្ងៃ បានកន្លងផុតទៅហើយ។ ច្បាប់ត្រូវបានគេលើកឡើងទៅតុលាការកំពូល ហើយរដ្ឋាភិបាលត្រូវបានបង្គាប់ឱ្យលុបចោល ឬធ្វើវិសោធនកម្មចំពោះច្បាប់នេះ អាស្រ័យដោយវារិតបន្តឹងចំពោះលទ្ធភាពរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ ប៉ុន្តែដីកាបង្គាប់នេះមិនទាន់ត្រូវបានគេយកមកអនុវត្តនៅឡើយទេ។ ស្ថិតក្រោមកម្មវិធីស្តារនីតិសម្បទាជនរងគ្រោះបច្ចុប្បន្ន ជនរងគ្រោះនៃបទល្មើសផ្លូវភេទមិនត្រូវបានកំណត់និយមន័យថាជា "ជនរងគ្រោះ" ឡើយ ដូច្នេះ ពួកគេពុំមានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទា និងជំនួយសង្គ្រោះនោះទេ។ នេះគឺជាលើកទីមួយហើយ ដែលអ្នកផ្តល់សក្ខីកម្មចំនួន២រូប បាននិយាយអំពីបទពិសោធន៍របស់ពួកគេជាសាធារណៈ អាស្រ័យដោយគេមិនអាចធ្វើបែបនេះបានឡើយនៅក្នុងប្រទេសនេប៉ាល់។

# សម្លេងពីអ្នកចូលរួម

ខណៈពេលដែលក្រុមគណៈវិនិច្ឆ័យបានធ្វើសេចក្ដីថ្លែងចុងក្រោយរបស់ខ្លួនរួចរាល់ អ្នកចូលរួម អ្នកជំនាញ និង អ្នកផ្ដល់សក្ខីកម្ម បានចូលរួមនៅក្នុងវគ្គសំនួរចម្លើយបើកចំហមួយ។ សំនួរដែលបានសាកសួររួមមានចាប់ពីអភិក្រមបច្ចេកទេសផ្នែកច្បាប់នៅក្នុងបរិបទនៃការប្រៀបធៀបអំពីយុត្តិធម៌អន្តរកាល រហូតដល់សេចក្ដីត្រូវការក្នុងការផ្ដល់សេវាកម្មដែលមានវិសាលភាពពេញលេញមួយ ដើម្បីដោះស្រាយផលប៉ះពាល់ពិសេសនៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះ។ អ្វីដែលបានកត់ត្រាខាងក្រោមនេះ គឺជាសម្រង់នៃកិច្ចសន្ទនាដែលបានធ្វើឡើងតាមរយៈសម្លេងរបស់ពួកគេ។

*"ក្នុងរយៈពេល៣ថ្ងៃចុងក្រោយនេះ ខ្ញុំបានប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះ។ ពួកគេមានអារម្មណ៍ខ្មាសអៀន និងឯកោ។ ភាពខ្មាសអៀន គឺដោយសារតែជនល្មើស និងសហគមន៍ដែលបានបង្កឱ្យមាននូវការមាក់ងាយទៅលើជនរងគ្រោះ។ យើងបានទះដៃអបអរ សាទរចំពោះភាពក្លាហានរបស់ស្ត្រី ដែលបានមកផ្ដល់សក្ខីកម្មនៅក្នុងវេទិកានេះ។ អ្នកពុំមែននៅឯកោតែម្នាក់ឯងឡើយ។ ចូរយើងទម្លាយ ភាពស្ងៀមស្ងាត់ អាស្រ័យដោយការរស់នៅពុំមានអ្វីគួរឱ្យខ្មាសអៀនឡើយ។"*

*"ខ្ញុំគឺជាជនរងគ្រោះម្នាក់ពី ស២១ (ដែលជាពន្ធនាគារមួយដ៏ល្បីល្បាញក្នុងជំនាន់ខ្មែរក្រហម)។ ខ្ញុំមិនអាចរៀបរាប់ឱ្យអស់អំពីការឈឺចាប់របស់ខ្ញុំបានឡើយ ដោយសារតែវាមានទំហំធំខ្លាំងពេក។ ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយ និងមានមោទនភាពចំពោះខ្លួនឯងដែលមានឱកាសក្នុងការស្ដាប់ឮនូវរឿងរ៉ាវរបស់ស្ត្រីមកពីប្រទេសផ្សេងៗគ្នា ដែលអំពើហិង្សាផ្លូវភេទពុំមានភាពខុសគ្នាពីប្រទេសកម្ពុជាប៉ុន្មានឡើយ។ បើទោះជាដូច្នេះក្ដី ដោយសារតែបទពិសោធន៍ដែលខ្ញុំបានជួបប្រទះ ខ្ញុំនៅតែសម្រាន្តមិនលក់ ហើយត្រូវលេបថ្នាំ។ តុលាការខ្មែរក្រហមនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះហើយ ហើយយើងមានអារម្មណ៍ខកចិត្តប្រៀបបីដូចជាចកអណ្ដែតទឹក ហើយរដ្ឋាភិបាលមិនទាន់បានយកចិត្តទុកដាក់ឱ្យបានម៉ឺងម៉ាត់ចំពោះសេចក្ដីត្រូវការឱ្យមាននូវយុត្តិធម៌សម្រាប់បទល្មើសផ្លូវភេទនៅឡើយ"។*

*"យោងទៅតាមវេទិកានេះ ខ្ញុំមានសំណើរមួយចំនួន។ យើងមានរូបភាពអំពីអំពើហិង្សានៅពេលមានជម្លោះ ហើយយើងយល់ថា ទាំងនោះគឺជាយុទ្ធសាស្ត្រសង្គ្រាម។ នៅត្រង់នេះ គេក៏បានបន្ទោសទៅលើភាពក្រីក្រផងដែរ។ កាលពីមុនខ្ញុំគិតថា មានតែរបបខ្មែរក្រហមប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះ ខ្ញុំឃើញថាប្រទេសដទៃទៀតក៏មានបញ្ហាដូចគ្នាដែរ។ ខ្ញុំសូមសំណូមពរឱ្យអង្គការសហប្រជាជាតិស្វែងរកយុត្តិធម៌សម្រាប់ស្ត្រី"។*

*"ចម្លើយដ៏ស្មោះត្រង់ គឺត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីគាំទ្រដល់ជនរងគ្រោះ.... មានចន្លោះប្រហោងមួយយ៉ាងធ្ងន់ធ្ងរចំពោះសេវាស្ដារសេដ្ឋកិច្ចឡើងវិញសម្រាប់ជនរងគ្រោះ។ មានជម្រើសរស់នៅតិចតួចប៉ុណ្ណោះសម្រាប់ជនរងគ្រោះក្រោយពេលជម្លោះ"។*

*"ជាបឋម ខ្ញុំសូមគោរពភ្ញៀវទាំងអស់ដែលបានចូលរួមនៅក្នុងវេទិកានេះ។ ខ្ញុំគឺជាមេធាវីម្នាក់ ហើយខ្ញុំចង់សួរសំនួរមួយដែលទាក់ទងទៅនឹងទីម័រខាងកើត។ ក្នុងអំឡុងជម្លោះឆ្នាំ១៩៧៥ មានជនជាប់ចោទពីបទរំលោភសេពសន្ថវៈចំនួន៤០៣នាក់។ តុលាការត្រូវបានរៀបចំឡើងរយៈពេលត្រឹមតែ១០ខែប៉ុណ្ណោះ ដូច្នេះ តើយើងអាចស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះបានដែរឬទេ អាស្រ័យដោយមានជនរងគ្រោះច្រើន ប៉ុន្តែការកាត់ក្ដីមានរយៈពេលខ្លីប៉ុណ្ណោះ?"។*

*"តុលាការគ្រាន់តែផ្តោតយកចិត្តទុកដាក់ទៅលើមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះ។ ប្រសិនបើពួកគេមិនបញ្ចូលករណីរំលោភសេពសន្ថវៈទេនោះ តើយើងចាំបាច់រៀបចំឱ្យមាននូវវេទិកានេះធ្វើអ្វី? តើទង្វើបែបនេះ គឺដើម្បីផ្តល់ការលើកទឹកចិត្តដល់ខ្ញុំ ឬផ្តល់ភាពក្រៀមក្រំបន្ថែមទៀតដល់ខ្ញុំ? ប្រសិនបើពុំមានលទ្ធផលប្រកបដោយផ្លែផ្កាទេនោះ តើគេរៀបចំវេទិកានេះឡើងដើម្បីអ្វី? កាលពីយប់មិញខ្ញុំសម្រាន្តមិនលក់ឡើយ។ ខ្ញុំត្រូវបានគេរំលោភនៅពេលដែលខ្ញុំមានអាយុ ១៤ឆ្នាំ ប្រសិនបើករណីបែបនេះមិនត្រូវបាន អ.វ.ត.ក យកមកពិចារណាទេនោះ តើយើងចាំបាច់រៀបចំវេទិកានេះធ្វើអ្វី?"*

*"ខ្ញុំចង់សួរថា ប្រសិនបើជនល្មើសដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនៅតែកំពុងរស់នៅក្នុងភូមិជាមួយគ្នា ឬរស់នៅក្នុងភូមិផ្សេងគ្នា តើយើងអាចប្តឹងជនល្មើសម្នាក់នោះបានដែរឬទេ?"*



អ្នកចិត្តសាស្ត្ររបស់ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងសមាជិកអ្នកចូលរួម

*"ដំណើរការយុត្តិធម៌នៅក្នុងប្រទេសជាច្រើន គឺជាដំណើរការមួយដែលមានរយៈពេលវែង។ ថ្នាក់ដឹកនាំរបស់យើង ជួនកាលពុំបានផ្តល់ការគាំទ្រចំពោះដំណើរការនេះឡើយ។ ថ្នាក់ដឹកនាំរបស់យើងភាគច្រើនចង់បំភ្លេចអតីតកាលចោល។ ពុំមានការពិភាក្សាអ្វីឡើយ ដូច្នេះអ្នកអាចស្រម៉ៃមើលថា តើជនរងគ្រោះមានអារម្មណ៍តានតឹងដល់កម្រិតណា។ ក្រោយពេលការប្រយុទ្ធ និងការឈឺចាប់ថ្នាក់ដឹកនាំបានបំភ្លេចការឈឺចាប់របស់ពួកគេ។ ជនរងគ្រោះកំពុងរស់នៅក្នុងស្ថានភាពដ៏លំបាក បើទោះបីជារហូតមកដល់ពេលនេះ និងក្រោយពេលទទួលបានឯករាជ្យភាពក៏ដោយ។ យើងបន្តខិតខំ ហើយយើងក៏ត្រូវការសាមគ្គីភាពពីប្រទេសដទៃទៀតជុំវិញពិភពលោកផងដែរ។"*

# សេចក្តីថ្លែងរបស់ក្រុមគណៈវិនិច្ឆ័យ



*សមាជិកក្រុមគណៈវិនិច្ឆ័យ (ពីស្តាំទៅឆ្វេង) ដោយអាណា អូតូ , វ៉ាហ៊ីដា ណៃណា , អូរ៉ូរ៉ា ឌីឌីអូស*



ផ្អែកលើខ្លឹមសារជារួមនៃសក្ខីកម្មដែលផ្តល់ជូនដោយសាក្សី-ជនរងគ្រោះ អ្នកជំនាញការ ព្រមទាំងភ្ញៀវកិត្តិយស ក្រុមគណៈវិនិច្ឆ័យ បានផ្តល់អនុសាសន៍ជូនដល់រដ្ឋាភិបាលនៃប្រទេសនីមួយៗក្នុងចំណោមប្រទេសទាំង៤ ស្ថាប័នយុត្តិធម៌ជាតិ និងអន្តរជាតិដែលមាននៅក្នុងប្រទេសទាំងនោះ សហគមន៍អន្តរជាតិ រាប់បញ្ចូលអង្គការសហប្រជាជាតិ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

នៅក្នុងគំហើញរបស់ពួកគេ ក្រុមគណៈវិនិច្ឆ័យបានធ្វើការគូសបញ្ជាក់អំពីទម្រង់ទូទៅនៃហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ ដែលបានកើតឡើងនៅពេលមានជម្លោះក្នុងប្រទេសផ្សេងៗគ្នា ដែលមានអ្នកតំណាងចូលរួមនាឱកាសនេះ។ ក្រុមគណៈវិនិច្ឆ័យបានធ្វើការទាញសេចក្តីសន្និដ្ឋានថា បើទោះបីជាប្រទេសទាំង៤ បានជួបប្រទះបទពិសោធន៍ជម្លោះដែលមានប្រភេទផ្សេងៗគ្នាគួរឱ្យកត់សម្គាល់ក៏ដោយ គេបានឃើញយ៉ាងច្បាស់លាស់ថា មានការប្រើប្រាស់យ៉ាងទូលំទូលាយនូវហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ ក្នុងចំណោមប្រទេសទាំងអស់នោះ។ ពួកគេក៏បានធ្វើការកត់សម្គាល់ផងដែរថា ហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ ដែលបានពិពណ៌នានៅក្នុងពេលផ្តល់សក្ខីកម្ម ត្រូវបានប្រព្រឹត្តដោយគ្រប់តួអង្គទាំងអស់ដែលពាក់ព័ន្ធនៅក្នុងជម្លោះ និងក្នុងស្ថានភាពដែលបានកើតឡើងទៅតាមការរៀបចំ និងគ្រោងទុកនៅគ្រានោះដោយរដ្ឋដែលមានកាតព្វកិច្ចផ្តល់ការការពារ និងទប់ស្កាត់ពីការរំលោភបំពានបែបនេះ។

បើទោះជាដូច្នេះក្តី ពុំមានជនល្មើសណាម្នាក់ត្រូវបានគេធ្វើឱ្យទទួលខុសត្រូវចំពោះបទល្មើសដែលពួកគេបានប្រព្រឹត្តឡើយ ដែលកត្តានេះបានរាំងស្ទះចំពោះសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានភាពយុត្តិធម៌។ អ្វីដែលធ្ងន់ធ្ងរបំផុតនោះគឺផលប៉ះពាល់អវិជ្ជមានទៅលើជនរងគ្រោះ បានបន្តកើតមាននៅក្នុងជីវិតរស់នៅរបស់ពួកគេ ដែលបង្កឱ្យ

មាននូវបញ្ហាសិទ្ធិមនុស្សចម្បងៗជាច្រើននៅពេលបច្ចុប្បន្ន ហើយរដ្ឋមានកាតព្វកិច្ចអន្តរជាតិតាមផ្លូវច្បាប់ក្នុងការដោះស្រាយបញ្ហាទាំងអស់នោះ។ ក្រុមគណៈវិនិច្ឆ័យបានថ្លែងឱ្យដឹងថា បើទោះបីជាអំពើរំលោភសេពសន្ថវៈ គឺជាប្រភេទនៃអំពើហិង្សាទៅលើស្ត្រី និងកុមារី ដែលគេប្រើប្រាស់ទូលំទូលាយបំផុតនៅពេលមានជម្លោះប្រដាប់អាវុធក៏ដោយ ប៉ុន្តែបញ្ហានេះនៅតែបន្តជាឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានគេថ្កោលទោសតិចតួចបំផុត ដោយសារតែវប្បធម៌នៃការរក្សាភាពស្ងៀមស្ងាត់ដែលមានលក្ខណៈជាសកល និងការមាក់ងាយជុំវិញបញ្ហាហិង្សាផ្លូវភេទ។ លទ្ធផលបានស្ដីបន្ទោសទៅលើជនរងគ្រោះ និងផ្ដល់កិច្ចការពារសុវត្ថិភាពចំពោះនិទណ្ឌភាពសម្រាប់ជនល្មើស។ នៅក្នុងការទម្លាយភាពស្ងៀមស្ងាត់នៅឯវេទិកាក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ស្ត្រីមកពីប្រទេសកម្ពុជា បង់ក្លាដេស ទីម័រខាងកើត និងនេប៉ាល់បានបង្ហាញឱ្យឃើញនូវសេចក្តីក្លាហានគួរឱ្យកត់សម្គាល់ និងការប្ដេជ្ញាចិត្តយ៉ាងជ្រាលជ្រៅមួយ ដើម្បីទទួលបានភាពយុត្តិធម៌។

*សេចក្តីថ្លែងទាំងស្រុងរបស់ក្រុមគណៈវិនិច្ឆ័យ អាចរកមើលនៅក្នុង "ឧបសម្ព័ន្ធ គ"។*

# មេរៀនបទពិសោធន៍

## កិច្ចគាំទ្រផ្លូវចិត្ត

កិច្ចគាំទ្រផ្លូវចិត្ត ត្រូវបានផ្តល់ជូនដល់អ្នកផ្តល់សក្ខីកម្ម និងអ្នកចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ ដោយអ្នកចិត្តសាស្រ្តមួយក្រុមទាំងស្រី/ប្រុស ដែលមានសមាជិក៧រូប។ ក្រុមអ្នកចិត្តសាស្រ្តនេះ មានប្រសិទ្ធភាពខ្ពស់យ៉ាងខ្លាំងក្នុងការដោះស្រាយចំពោះអារម្មណ៍ក្តុកក្តួល និងប្រតិកម្មពីអ្នកផ្តល់សក្ខីកម្ម និងអ្នកចូលរួម (ភាគច្រើន ពួកគេគឺជាជនរងគ្រោះពីសម័យខ្មែរក្រហម)។ បន្ថែមពីនេះទៀត សមាជិកក្រុមនីមួយៗត្រូវបានចាត់តាំងឱ្យនៅជាមួយអ្នកផ្តល់សក្ខីកម្មមួយរូប ដើម្បីផ្តល់កិច្ចគាំទ្រជាលក្ខណៈបុគ្គល និងត្រួតពិនិត្យទៅលើសុខុមាលភាពទូទៅនៅក្នុងព្រឹត្តិការណ៍នេះទាំងមូល។ ការដែលមានបុគ្គលិកច្រើនរួមផ្សំជាមួយនឹងការទទួលខុសត្រូវរបស់អ្នកចិត្តសាស្រ្តនីមួយៗ បានធានាឱ្យមាននូវគម្រោងគាំទ្រគ្រប់ជ្រុងជ្រោយមួយដែលទម្រង់បែបនេះ នឹងត្រូវបានយកមកប្រើប្រាស់ជាថ្មីម្តងទៀតសម្រាប់ព្រឹត្តិការណ៍នាពេលអនាគត។

ការផ្តល់កិច្ចគាំទ្រផ្លូវចិត្ត ត្រូវបានគេដកស្រង់ប្រកបដោយសង្គតភាពនៅក្នុងការវាយតម្លៃថាជាធាតុផ្សំមួយដ៏សំខាន់នៃវេទិកានេះ។ ដូច្នេះ វិធីសាស្រ្ត និងមេរៀនបទពិសោធន៍សំខាន់ៗ ត្រូវបានបញ្ជាក់លម្អិតដូចខាងក្រោម៖

### ១. ការរៀបចំមុនពេលវេទិកាស្តាប់សម្លេងស្រ្តី

កិច្ចប្រជុំត្រៀមលក្ខណៈមួយត្រូវបានរៀបចំក្នុងប្រទេសកម្ពុជា រយៈពេល១ថ្ងៃ មុនពេលវេទិកាស្តាប់សម្លេងស្រ្តីជាមួយអ្នកផ្តល់សក្ខីកម្ម CSR សមាជិកក្រុមគណៈវិនិច្ឆ័យ អ្នកសម្របសម្រួល និងបុគ្គលិកគម្រោងរាប់បញ្ចូលទាំងបុគ្គលិកគាំទ្រផ្នែកចិត្តសាស្រ្ត។ កិច្ចប្រជុំនេះ បានធ្វើឱ្យអ្នកផ្តល់សក្ខីកម្មមានភាពស៊ាំទៅនឹងទីកន្លែង និងដំណើរការនៃវេទិកា ព្រមទាំងបានណែនាំពួកគេឱ្យស្គាល់អ្នកពាក់ព័ន្ធទាំងអស់។ អ្វីដែលសំខាន់បំផុតនោះ គឺក្រុមអ្នកចិត្តសាស្រ្តបានផ្តល់ការណែនាំដោយសង្ខេបមួយចំនួនអំពីប្រតិកម្ម និងផលវិបាកដែលអាចកើតឡើងចំពោះអ្នកផ្តល់សក្ខីកម្មក្រោយមកពីការចូលរួមរបស់ពួកគេ។ អ្នកផ្តល់សក្ខីកម្មត្រូវបានអនុញ្ញាតឱ្យធ្វើការគ្រប់គ្រងទាំងស្រុងទៅលើសក្ខីកម្មរបស់ពួកគេ ហើយជាថ្មីម្តងទៀតពួកគេត្រូវបានប្រាប់ថា ពួកគេមានសេរីភាពក្នុងការចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេច្រើន ឬតិចទៅតាមអារម្មណ៍ដែលពួកគេគិតថាមានភាពងាយស្រួលក្នុងអំឡុងពេល ដែលពួកគេផ្តល់សក្ខីកម្មជាសាធារណៈ ហើយពួកគេអាចបញ្ចប់ការផ្តល់សក្ខីកម្មរបស់ពួកគេនៅពេលណាមួយក៏បាន បើទោះជាដូច្នេះក្តី កិច្ចប្រជុំត្រៀមលក្ខណៈរយៈពេល១ថ្ងៃនេះ ពុំមានភាពគ្រប់គ្រាន់ទាំងស្រុងឡើយ ដើម្បីធ្វើការត្រៀមលក្ខណៈសម្បត្តិសម្រាប់អ្នកផ្តល់សក្ខីកម្ម។ សម្រាប់ព្រឹត្តិការណ៍ដែលនឹងត្រូវរៀបចំធ្វើឡើងនៅពេលអនាគត គេបានផ្តល់អនុសាសន៍យ៉ាងខ្ពង់ខ្ពស់ថា គួរមានកម្រងនៃកិច្ចប្រជុំត្រៀមលក្ខណៈមួយចំនួនជាមួយអ្នកផ្តល់សក្ខីកម្ម ដើម្បីឱ្យពួកគេមានឱកាសអនុវត្តការផ្តល់សក្ខីកម្មរបស់ពួកគេ ក្រោមការណែនាំពីបុគ្គលិកគាំទ្រផ្លូវចិត្ត។

## ២. កិច្ចគាំទ្រចិត្តសង្គមក្នុងអំឡុងពេលវេទិកាស្តាប់សម្លេងស្ត្រី

ក្រុមអ្នកចិត្តសាស្ត្រដែលមានបុរស និងស្ត្រី ត្រូវបានគេណែនាំឱ្យអ្នកចូលរួមស្គាល់នៅពេលដំបូងនៃថ្ងៃទី១ នៃវេទិកានេះ ហើយពួកគេមានវត្តមានក្នុងរយៈពេល២ថ្ងៃពេញ។ ក្នុងអំឡុងពេលនៃការណែនាំនេះ អ្នកចិត្តសាស្ត្របានជម្រាបជូនអ្នកចូលរួមទាំងអស់អំពីសញ្ញាផ្លូវចិត្តមួយចំនួនដែលពួកគេអាចជួបប្រទះពីការធ្វើជាកស្សិណសាក្សីចំពោះសក្ខីកម្ម ហើយពួកគេត្រូវបានលើកទឹកចិត្តឱ្យទៅរកអ្នកចិត្តសាស្ត្រដើម្បីសុំការគាំទ្រទៅតាមភាពចាំបាច់។

មានបន្ទប់ដាច់ដោយឡែកមួយសម្រាប់ផ្តល់កិច្ចគាំទ្រជាក្រុម និងកិច្ចគាំទ្រជាលក្ខណៈបុគ្គល ដែលការរៀបចំបែបនេះ មានប្រសិទ្ធភាពយ៉ាងខ្លាំងក្នុងការផ្តល់ភាពឯកជន និងទីកន្លែងសុវត្ថិភាព ដើម្បីបញ្ចេញប្រតិកម្មផ្នែកអារម្មណ៍។ បើទោះជាដូច្នេះក្តី គេបានធ្វើការកត់សម្គាល់ថា បន្ទប់ពុំមានភាពឯកជនគ្រប់គ្រាន់ ហើយគេអាចធ្វើឱ្យវាមានភាពប្រសើរឡើងជាងនេះ តាមរយៈការរៀបចំបន្ទប់នោះឱ្យស្ថិតនៅកន្លែងមួយដែលដាច់ឆ្ងាយពីសាលវេទិកា និង/ឬ បុគ្គលិកមានសមត្ថកិច្ចត្រូវសុំការអនុញ្ញាតជាមុនចំពោះជនគ្រប់រូបដែលចូលទៅក្នុងបន្ទប់។ ការមានប្រអប់ឱសថសង្គ្រោះបន្ទាន់អាចជួយព្យាបាលប្រតិកម្មផ្លូវកាយភ្លាមៗមួយចំនួន ដូចជា ឈឺក្បាល ឬវិលមុខផងដែរ។

ការសាកសួរសំនួរជាក្រុមចំពោះអ្នកផ្តល់សក្ខីកម្ម ត្រូវបានធ្វើឡើងជាច្រើនដងក្នុងមួយថ្ងៃ នៅក្នុងរយៈពេលនៃព្រឹត្តិការណ៍នេះ។ កិច្ចប្រជុំក្រុមតូចៗទាំងនេះ បានបញ្ជាក់ថា បានផ្តល់ភាពអង់អាចយ៉ាងខ្លាំងចំពោះអ្នកផ្តល់សក្ខីកម្ម អាស្រ័យដោយពួកគេអាចមានលទ្ធភាពក្នុងការផ្តល់កិច្ចគាំទ្រ និងទទួលបានកិច្ចគាំទ្រពីជនរងគ្រោះដទៃទៀតនៃហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ។ យ៉ាងណាមិញ អាស្រ័យដោយរបៀបវារៈនៃវេទិកានេះមានភាពមមាញឹក ការសាកសួរសំនួរជាក្រុមត្រូវបានធ្វើឡើងនៅពេលសម្រាក ដែលទង្វើបែបនេះ នាំឱ្យរយៈពេលសម្រាកកាន់តែខ្លី។ គេបានផ្តល់អនុសាសន៍ថា ព្រឹត្តិការណ៍នៅពេលអនាគតគួរបែងចែកពេលវេលាជាក់លាក់មួយចំនួនសម្រាប់ធ្វើការសាកសួរសំនួរជាក្រុមនៅក្នុងរបៀបវារៈប្រចាំថ្ងៃ។



## ៣.ការបន្តផ្តល់កិច្ចគាំទ្រ

សម្រាប់អ្នកផ្តល់សក្ខីកម្មជាជនជាតិកម្ពុជា គេបានរៀបចំឱ្យមាននូវកិច្ចប្រជុំមួយនៅថ្ងៃបន្ទាប់ក្រោយពេលវេទិកាស្តាប់សម្លេងស្ត្រីបានបញ្ចប់ ដើម្បីផ្តល់ឱកាសឱ្យពួកគេបញ្ចេញភាពតានតឹងចែករំលែកអារម្មណ៍ និងផ្តល់មតិយោបល់របស់ពួកគេ។ កិច្ចប្រជុំតាមដានមួយទៀត ត្រូវបានធ្វើឡើងរយៈពេល២សប្តាហ៍បន្ទាប់ ហើយគេបានប្រើប្រាស់ការតាមដានតាមរយៈទូរស័ព្ទ ដើម្បីពិនិត្យទៅលើការវិវឌ្ឍន៍របស់ពួកគេនៅចន្លោះពេលនោះ។ កម្រងនៃកិច្ចគាំទ្រតាមដានបែបនេះ បានទទួលការស្វាគមន៍យ៉ាងខ្លាំងពីអ្នកផ្តល់សក្ខីកម្ម ហើយស្របពេលជាមួយគ្នានោះដែរ វាគឺជាឧបករណ៍ត្រួតពិនិត្យមួយដ៏មានសារៈប្រយោជន៍ដើម្បីវាស់ស្ទង់អំពីផលប៉ះពាល់នៃការចូលរួមរបស់ពួកគេ។ បើទោះជាដូច្នេះក្តី អាស្រ័យដោយធនធានមានកម្រិតការតាមដានក្នុងលក្ខណៈដូចគ្នានេះ មិនអាចផ្តល់ជូនចំពោះអ្នកផ្តល់សក្ខីកម្មអន្តរជាតិបានឡើយ។ គេបានផ្តល់អនុសាសន៍យ៉ាងខ្ពង់ខ្ពស់ថា សកម្មភាពនៅពេលអនាគតគួរបញ្ចូលខ្ទង់ចំណាយសម្រាប់កិច្ចគាំទ្រតាមដានទៅក្នុងការរៀបចំផែនការថវិកា។

# ការវាយតម្លៃព្រឹត្តិការណ៍ និងអនុសាសន៍ទូទៅ

បន្ទាប់ពីវេទិកាស្តាប់សម្លេងស្ត្រីបានបញ្ចប់ គេបានប្រមូលមតិយោបល់ពីប្រភពផ្សេងៗគ្នា ក្នុងនោះរួមមានដូចជាការអង្កេតមួយដែលត្រូវបានធ្វើឡើងក្នុងចំណោមអ្នកចូលរួម គណៈកម្មាធិការប្រឹក្សាយោបល់ ដៃគូរៀបចំ និងអ្នកផ្តល់សក្ខីកម្ម។ ផ្អែកលើលទ្ធផលអនុសាសន៍ខាងក្រោម ត្រូវបានផ្តល់ជូនសម្រាប់ការរៀបចំព្រឹត្តិការណ៍នៅពេលអនាគត។

១. ការពង្រីកវិសាលភាពនៃវេទិកាស្តាប់សម្លេងស្ត្រីឱ្យក្លាយទៅជាព្រឹត្តិការណ៍ថ្នាក់តំបន់មួយ (ធៀបទៅនឹងឆ្នាំ២០១១ នៅពេលដែលវេទិកានេះផ្តោតយកចិត្តទុកដាក់ចំពោះប្រទេសកម្ពុជាតែមួយគត់) ត្រូវបានគេយល់ឃើញជាទូទៅថា ជាការអភិវឌ្ឍន៍មួយប្រកបដោយភាពវិជ្ជមាន។ ការប្រមូលជនរងគ្រោះពីប្រទេសជិតខាងដែលមានពាក់ព័ន្ធទៅនឹងជម្លោះស្រដៀងគ្នានេះ គឺជាឱកាសមួយសម្រាប់ការសិក្សាប្រៀបធៀប ព្រមទាំងជាឱកាសសម្រាប់ជនរងគ្រោះមកពីប្រទេសផ្សេងៗគ្នាដើម្បីទម្លាយអំពីភាពឯកោរបស់ពួកគេ និងសម្តែងអំពីការយល់អារម្មណ៍គ្នាទៅវិញទៅមក។

២. បើទោះជាដូច្នេះក្តី បញ្ហាកង្វល់មួយដ៏ចម្បង គឺជាការកម្រិតពេលវេលាទៅលើអ្នកផ្តល់សក្ខីកម្ម ដោយសារតែរបៀបវារៈមានភាពចង្អៀត និងការចូលរួមពីប្រទេសទាំង៤។ ការបង្កើនចំនួនអ្នកផ្តល់សក្ខីកម្ម (ពី៤នាក់ ក្នុងឆ្នាំ២០១១ រហូតដល់៨នាក់ ក្នុងឆ្នាំ២០១២) បានផ្តល់ពេលវេលាតិចជាងមុនសម្រាប់អ្នកផ្តល់សក្ខីកម្មនីមួយៗ និងត្រូវបានគេយល់ឃើញថាជាការធ្លាក់ចុះចំពោះគុណភាពទូទៅនៃសក្ខីកម្ម។ គេបានផ្តល់មតិយោបល់ឱ្យកាត់បន្ថយចំនួនអ្នកផ្តល់សក្ខីកម្ម ឬចំនួនប្រទេសចូលរួម ឬបន្ថែមរយៈពេលនៃវេទិកានេះ ពី២ថ្ងៃ ទៅ៣ថ្ងៃ ដើម្បីផ្តល់ពេលវេលាបន្ថែមសម្រាប់អ្នកផ្តល់សក្ខីកម្ម នីមួយៗ។

៣. ចំពោះទម្រង់នៃវេទិកាស្តាប់សម្លេងស្ត្រីវិញ គេបានឯកភាពជាទូទៅថា បទបង្ហាញរបស់អ្នកជំនាញការគួរមានអាទិភាពទាបជាងការផ្តល់សក្ខីកម្ម និងសាវតារបស់ប្រទេស។ គេបានផ្តល់អនុសាសន៍ឱ្យកម្រិតទៅលើចំនួនជំនាញការជាគណៈវិនិច្ឆ័យ ដែលអាចផ្តល់ក្របខ័ណ្ឌដែលមានទំនាក់ទំនងជាក់លាក់ទៅនឹងសក្ខីកម្មដែលគេនឹងធ្វើការបង្ហាញ។ អ្នកផ្តល់សក្ខីកម្ម និងអ្នកចូលរួមដែលភាគច្រើនពុំមានការអប់រំពិតជាបានយល់អំពីបទបង្ហាញរបស់អ្នកជំនាញការ។ ដូច្នេះ ប្រសិនបើសុន្ទរកថាមានលក្ខណៈខ្លីជាងនេះ និងមានភាពពាក់ព័ន្ធដោយផ្ទាល់ជាងនេះចំពោះសក្ខីកម្ម គឺរឹតតែប្រសើរ។

៤. ក្រុមគណៈវិនិច្ឆ័យបានចូលរួមដោយស្ម័គ្រចិត្ត។ ក្រុមគណៈវិនិច្ឆ័យដើរតួនាទីមួយដ៏សំខាន់ស្ថិតក្រោមស្ថានភាពដែលមានការលំបាកជាខ្លាំង ដោយបានធ្វើការវិភាគកែច្នៃភ្លាមៗចំពោះព័ត៌មានដែលផ្តល់ជូនដោយអ្នកផ្តល់សក្ខីកម្មក្នុងបរិបទសកល ដោយផ្អែកលើសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌ។ គេបានរៀបចំឯកសារជាមុនជូនដល់ក្រុមគណៈវិនិច្ឆ័យក្នុងលក្ខណៈជាកញ្ចប់មួយ ក្នុងនោះរាប់បញ្ចូលទាំងទម្រង់ សេចក្តីថ្លែងរបស់ក្រុមគណៈវិនិច្ឆ័យ។ បន្ថែមពីនេះទៀត ផ្នែកមួយនៃកិច្ចប្រជុំត្រៀមលក្ខណៈសម្រាប់វេទិកានេះ រួមមានកិច្ចប្រជុំរៀបចំដោយឡែកមួយចំនួន ដើម្បីធ្វើការត្រួតពិនិត្យកែសម្រួលឡើង

វិញទៅលើឯកសារ ពិភាក្សាអំពីគោលបំណងត្រៀមលក្ខណៈសម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកផ្តល់សក្ខីកម្ម និងរៀបចំសេចក្តីព្រាងអំពីបញ្ហានានាដែលមាន។ អ្នកធ្វើរបាយការណ៍ និងអ្នកកត់ត្រាមួយរូប ត្រូវបានចាត់តាំងដើម្បីជួយសម្របសម្រួលក្នុងការរៀបចំសេចក្តីថ្លែង ខណៈពេលដែលវេទិកានេះកំពុងបន្តប្រព្រឹត្តទៅព្រមទាំងបញ្ចូលការកែសម្រួល និងមតិយោបល់នានា ដែលទទួលបានជាបន្តបន្ទាប់ពីក្រុមគណៈវិនិច្ឆ័យ។ អ្នកជំនាញបានផ្តល់កិច្ចគាំទ្របច្ចេកទេសក្នុងអំឡុងពេលរៀបចំសេចក្តីព្រាងនូវសេចក្តីថ្លែង។ បើទោះជាដូច្នេះក្តី កិច្ចគាំទ្រ និងការរៀបចំនេះ ត្រូវបានយល់ឃើញថា ពុំទាន់គ្រប់គ្រាន់នៅឡើយ។ សម្រាប់ព្រឹត្តិការណ៍នៅពេលអនាគត គេគួរធ្វើការប្រាស្រ័យទាក់ទងឱ្យបានច្បាស់លាស់ជាងនេះ ចំពោះការរំពឹងទុកអំពីគោលបំណង និងវិធីរៀបចំសេចក្តីថ្លែងរបស់ក្រុមគណៈវិនិច្ឆ័យ ព្រមទាំងការប្តេជ្ញាចិត្តចាំបាច់នានារបស់ក្រុមគណៈវិនិច្ឆ័យ ជាពិសេសទាក់ទងទៅនឹងចំនួន និងប្រភេទនៃព័ត៌មានដែលត្រូវយកមកធ្វើការវិភាគកែច្នៃ។

៥. ការអានសេចក្តីថ្លែងរបស់ក្រុមគណៈវិនិច្ឆ័យ ផ្តល់នូវសុក្រឹត្យភាពចំពោះអ្នកផ្តល់សក្ខីកម្ម ប៉ុន្តែ គេបានយល់ឃើញថា វាមានភាពលម្អិត និងបច្ចេកទេសខ្លាំងពេក ជាពិសេសចំពោះអ្នកផ្តល់សក្ខីកម្ម និងភាគីស៊ីវិលដែលបានចូលរួម។ សម្រាប់ព្រឹត្តិការណ៍នៅពេលអនាគត គេបានផ្តល់អនុសាសន៍ឱ្យផ្តល់សារដែលមានលក្ខណៈច្បាស់លាស់ និងរឹងមាំជាសាធារណៈក្រោមវត្តមានរបស់អ្នកផ្តល់សក្ខីកម្ម និងអ្នកចូលរួមដែលផ្តោតជាក់លាក់ទៅលើអ្នកផ្តល់សក្ខីកម្មដោយផ្ទាល់។ គេអាចធ្វើការបោះពុម្ពដោយឡែកសម្រាប់ទម្រង់ដែលមានភាពលម្អិតជាងនេះជាលាយលក្ខណ៍អក្សរ។

៦. ទម្រង់នៃសក្ខីកម្ម រួមមានសំនួរទូទៅមួយចំនួនពីសមាជិកក្រុមគណៈវិនិច្ឆ័យមួយរូបរហូតដល់អ្នកផ្តល់សក្ខីកម្មនីមួយៗ។ បើទោះជាដូច្នេះក្តី គេបានគិតថាសំនួរដែលមានលក្ខណៈជាក់លាក់ជាងនេះ គួរត្រូវបានរៀបចំឡើងដើម្បីជួយផ្តល់ការណែនាំដល់អ្នកផ្តល់សក្ខីកម្ម តាមរយៈសក្ខីកម្មរបស់ពួកគេ។ ទង្វើបែបនេះ អាចកាត់បន្ថយឱកាសក្នុងការដែលអ្នកផ្តល់សក្ខីកម្មអាចមានអារម្មណ៍ក្តុកក្តួល ព្រមទាំងផ្តល់នូវរូបភាពមួយអំពីបទពិសោធន៍របស់ពួកគេ ដែលកាន់តែមានភាពគ្រប់ជ្រុងជ្រោយ។ គេបានផ្តល់អនុសាសន៍គួរផ្តល់ពេលវេលាសម្រាប់សមាជិកក្រុមគណៈវិនិច្ឆ័យនីមួយៗ ដើម្បីហាត់អនុវត្តសំនួរទាំងនេះ ជាមួយអ្នកផ្តល់សក្ខីកម្មនីមួយៗនៅក្នុងកិច្ចប្រជុំត្រៀមលក្ខណៈសម្រាប់វេទិកាស្តាប់សម្លេងស្ត្រី។

៧. អ្នកចូលរួមរួមមានភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៣០នាក់ របស់ អវតក ដែលភាគច្រើនពួកគេគឺជាជនរងគ្រោះនៃការបង្ខំឱ្យរៀបការនៅរបបខ្មែរក្រហម។ សម្រាប់ក្រុមនេះ ការស្តាប់បទពិសោធន៍របស់អ្នកផ្តល់សក្ខីកម្មពេលមានជម្លោះដទៃទៀត គឺជាជ្រុងមួយដ៏សំខាន់នៃវេទិកាស្តាប់សម្លេងស្ត្រីដែលរួមចំណែកនាំឱ្យមាននូវការយល់ដឹងកាន់តែប្រសើរ ព្រមទាំងការយល់អំពីអារម្មណ៍របស់ជនរងគ្រោះនៃហិង្សាផ្លូវភេទ និងហិង្សាយេនឌ័រ។

៨. អ្នកផ្តល់សក្ខីកម្មបានចែករំលែកឱ្យដឹងថា បើទោះបីជាការចែករំលែកជាសាធារណៈអំពីរឿងរ៉ាវរបស់ពួកគេ

នាំឱ្យពួកគេមានការលំបាកផ្នែកអារម្មណ៍យ៉ាងណាក៏ដោយ ប៉ុន្តែពួកគេមានអារម្មណ៍ថា ពួកគេមានភាពក្លាហាន និងមានភាពធូរស្រាលដោយសារតែបានចូលរួមនៅក្នុងវេទិកានេះ។ យ៉ាងណាមិញ អ្នកផ្តល់សក្ខីកម្មបានធ្វើការចង្អុលបង្ហាញថា គួរមានការពន្យល់បន្ថែមទៀតអំពីគោលបំណងនៃសក្ខីកម្មរបស់ពួកគេព្រមទាំងលទ្ធផលនៃវេទិកានេះ ដើម្បីធ្វើការតម្រឹមឱ្យស្របទៅនឹងសេចក្តីរំពឹងទុក។

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា អង្គការអន្តរវប្បធម៌ចិត្តសង្គម និងអង្គភាពគាំទ្រជនរងគ្រោះ សូមថ្លែងអំណរគុណចំពោះបុគ្គល និងអង្គការជាច្រើនដែលបានជួយដល់វេទិកាការស្តាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាយេនឌ័រ ពេលមានជម្លោះទទួលបានជោគជ័យ។




ជាដំបូង និងខ្ពង់ខ្ពស់បំផុត យើងសូមថ្លែងអំណរគុណចំពោះអ្នកផ្តល់សក្ខីកម្មគ្រប់រូប និងតំណាងសង្គមស៊ីវិលដែលបានអមដំណើរពួកគេមកកាន់ប្រទេសកម្ពុជា ៖

***ប្រទេសកម្ពុជា៖***

ដួង សាវន, ហុង សារ៉ាត, ជុំ លី, សុខ សាមិត, គឹម ខែម

***ប្រទេសទីម័រខាងកើត៖***

ណាតាលៀ ឌីជេសួស សេសាលទីណូ , ចាស៊ីនតូ ដូសែនតូស , ម៉ារីយ៉ា មែនញ៉ូអែលឡា លឿង ព័រេរ៉ា

***ប្រទេសនេប៉ាល់៖***

កូពីឡា អាដហ៊ីការី , សារីកា មីស្រា , មែនឌីរ៉ា សាម៉ា

***ប្រទេសបង់ក្លាដេស៖***

ម៉ូណូវ៉ារ៉ា ប៊ីហ្គាំ , មៀ ម៉ូហ្វីឌុល ហូក , អ៊ូម៉េ វ៉ារ៉ា

បន្ថែមពីនេះទៀត តំណាងសង្គមស៊ីវិលបានផ្តល់ជំនួយពីចម្ងាយ ក្នុងនោះជាពិសេសរួមមាន ៖

កាម៉ាល់ ប៉ាថាក់ មកពីនេប៉ាល់ , ហ្គាលូ វ៉ាន់ឌីតា មកពីឥណ្ឌូនេស៊ី

យើងក៏សូមថ្លែងអំណរគុណចំពោះសមាជិកក្រុមគណៈវិនិច្ឆ័យ អ្នកជំនាញ អ្នកសម្របសម្រួល អ្នកបកប្រែភាសា និង អ្នកធ្វើរបាយការណ៍សម្រាប់វិភាគទានរួមចំណែករបស់ពួកគេចំពោះព្រឹត្តិការណ៍នេះ។ បន្ថែមពីនេះទៀត យើងសូម

កោតសរសើរចំពោះកិច្ចគាំទ្ររបស់បុគ្គលដូចខាងក្រោម ៖

***គណៈកម្មាធិការប្រឹក្សាយោបល់៖***

ឃ្លែរ ឌុហ្វី , អាយ៉ាកូ ឡូរ៉ូយ , ថេរ៉េសា ឌីឡាងហ្គីស , កាស៊ូមី ណាកាហ្គាវ៉ា , ខេតលីន រ៉េហ្គ័រ , មីសែល ស្តេក , ស៊ីល ស្វូដហ្វ៊ីនស្តី

***បុគ្គលិកគម្រោង៖***

អាលីសុន បាក្លេ , ឆាយ ម៉ារីដែត , ជ សុណារី , ហង្ស ចរិយា , ហេង គឹមហ៊ុច , ហួយ វឌ្ឍនា , អ៊ឹម សុភា , គឹម ធីតា , លាង ចរិយា , វេជ្ជបណ្ឌិត មុន្នី សុត្ថារ៉ា , ពៅ ម៉ាលីន , ដួង សាវន , តាំង សៀងហ៊ុន , ស្រ៊ា រដ្ឋា , ជូ ឌីតស្ត្រាស័រ , ប៉េនី យ៉េ , យួន សារ៉ាត់

***អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការងារ៖***

អែតវ៉ត ហ្គូក , ជេនីហ្វ័រ ហូលីហ្គាន់ , ម៉ារីយ៉ាំ ចរដាន់ , កាទ្រីណា ណាតាលី , ការី ភីលផ័រ , ផាន់ រដ្ឋា , ស៊ូហ្សាន ព្រីតឆែត , ខែធី រ៉ូប៊ីតសុន , តារីន ស្ទីលីង , ហ្សូ ស្វាបត , ទីន ត្រែក , យឹម សុធារី

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់ជំនួយថវិកាពី ៖

មូលនិធិត្រាស់ហ្វាន់នៃអង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី អង្គការ GIZ ,ZIVIK , ifa, UN Women និងវិទ្យាស្ថានបើកទូលាយ



យើងសូមថ្លែងអំណរគុណចំពោះកិច្ចគាំទ្ររបស់អង្គការដូចខាងក្រោម ៖

អង្គការ GIZ ការិយាល័យប្រចាំប្រទេសបង់ក្លាដេស

អង្គការ GIZ ការិយាល័យប្រចាំប្រទេសនេប៉ាល់

អង្គការ GIZ ការិយាល័យប្រចាំប្រទេសទីម័រខាងកើត

មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល

ការិយាល័យតំបន់អង្គការ UN Women ប្រចាំទីក្រុងបាងកក

ការិយាល័យអង្គការ UN Women ប្រចាំប្រទេសកម្ពុជា

ការិយាល័យអង្គការ UN Women ប្រចាំប្រទេសទីម័រខាងកើត

ការិយាល័យតំណាងពិសេសនៃអគ្គលេខាធិការ ទទួលបន្ទុកហិង្សាផ្លូវភេទពេលមានជម្លោះ

កិច្ចប្រជុំស្ត្រីអាស៊ាន

លេខាធិការដ្ឋានអាស៊ាន

សកលវិទ្យាល័យ Wyoming មហាវិទ្យាល័យច្បាប់

ក្រសួងកិច្ចការនារីនៃប្រទេសម៉ាឡេស៊ី

Nobel Women's Initiative

# អ្នករៀបចំកម្មវិធី

ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា (CDP) ជាអង្គការសង្គមស៊ីវិលដ៏ចំណាស់មួយ ក្នុងចំណោមអង្គការផ្សេងៗទៀតនៅប្រទេសកម្ពុជា ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា បង្កើតឡើងក្នុងបំណងដើម្បីផ្តល់នូវអ្នកតំណាងជំនួយច្បាប់ទៅដល់ជនទីទ័លក្រនិងជនងាយរងគ្រោះដោយមិនយកកម្រៃ ព្រមទាំងពង្រឹងនីតិរដ្ឋ ការអភិវឌ្ឍន៍ប្រព័ន្ធតុលាការ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ សិទ្ធស្ត្រី ជាពិសេសការស្វែងរកយុត្តិធម៌ជូនអ្នកទាំងនេះ គឺជាគោលការណ៏ចំបងរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា។ នៅឆ្នាំ២០០៦ ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជាបានបង្កើតនូវការសិក្សាស្រាវជ្រាវដំបូងគេបង្អស់ស្តីពីហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម។ នៅឆ្នាំ២០០៩ ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជាបានបង្កើតគំរោងហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីផ្តល់ការយល់ដឹងពីការកើតឡើងនៃហិង្សាយេនឌ័រនៅរបបខ្មែរក្រហមកាន់អំណាច និងជម្រុញដំណើរការក្នុងការទទួលបានយុត្តិធម៌ និងផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីហិង្សាយេនឌ័រនាសម័យនោះ។ គំរោងហិង្សាយេនឌ័រ ដំណើរការតាមរយៈការតស៊ូមតិជាច្រើនសណ្ឋានដូចជា ការផ្សព្វផ្សាយ និងការផ្តួចផ្តើមអោយមានជំនួយផ្ទាល់នានា។

អង្គការអន្តរវប្បធម៌ចិត្តសង្គម (TPO) បង្កើតនៅកម្ពុជាក្នុងខែ កុម្ភៈ ឆ្នាំ១៩៩៥ ដែលជាសាខាមួយរបស់អង្គការក្រៅរដ្ឋាភិបាលហូឡង់ "អង្គការអន្តរវប្បធម៌ចិត្តសង្គមអន្តរជាតិ"។ បន្ទាប់ពីបានចុះជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យក្នុងស្រុកនៅឆ្នាំ២០០០ អង្គការអន្តរវប្បធម៌ចិត្តសង្គម គឺជាអង្គការក្រៅរដ្ឋាភិបាលឈានមុខគេនៅកម្ពុជា ក្នុងជំនាញសុខភាពផ្លូវចិត្ត និងសុខភាពសង្គម។ នៅក្នុងសង្គមមួយ ដែលមានប្រជាជនកម្ពុជាជាច្រើនកំពុងបន្តដំណើរតស៊ូជាមួយលទ្ធផលនៃអំពើហិង្សាជាប្រវត្តិសាស្រ្តរបស់ពួកគេដោយប្រឈមមុខនឹងអតីតកាលចំនុចសំខាន់គឺ ក្នុងការសះជាពីអតតីតកាលដ៏សែនឃោរឃៅនេះ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានផ្តល់ឱកាសតែមួយគត់សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីស្វែងរកការពិតនិងយុត្តិធម៌។ ចំពោះជនរងគ្រោះជាច្រើននាសម័យខ្មែរក្រហម យន្តការដើមបណ្តឹងរដ្ឋប្បវេណីថ្មីបានផ្តល់ជាការជំរុញឱកាសក្នុងការផ្សះផ្សាជីវិត និងផ្តល់អោយអ្នករស់រានមានជីវិតទាំងនេះទទួលនូវឱកាសក្នុងការនិយាយរឿងដែលបានកើតឡើងកន្លងមក និងការទទួលស្គាល់ពីការរំលោភបំពានទៅលើពួកគេក្នុងអតីតកាល។ អង្គការអន្តរវប្បធម៌ចិត្តសង្គម មានជំនឿថា ការចូលរួមយ៉ាងសកម្មក្នុងតុលាការនេះ និងធ្វើឲ្យមានលទ្ធផលយ៉ាងខ្ពស់ពីអ្នករស់រានមានជីវិតពីរបបដ៏សែនឃោរឃៅនេះ។ ប៉ុន្តែការចូលរួមរបស់ពួកគេនៅក្នុងដំណើរការព្រហ្មទណ្ឌនេះ អាចធ្វើឲ្យមានការប៉ះទង្គិចផ្នែកផ្លូវចិត្តពួកគេ។ អង្គការអន្តរវប្បធម៌ចិត្តសង្គមជឿថា ការធ្វើអោយប្រសើរខាងផ្លូវចិត្ត និងការផ្សះផ្សារគឺជាដំណើរការយូរអង្វែង ដែលត្រូវការច្រើនជាងយុត្តិធម៌សមបំណង ហើយគួរតែអនុវត្តអោយបានសមស្របទៅនឹងជំនួយសេវាកម្មផ្លូវចិត្ត និងលទ្ធភាពស្តាបនាសង្គមឡើងវិញ។ ដូចនេះអង្គការអន្តរវប្បធម៌ចិត្តសង្គម បានបង្កើតកម្មវិធីយល់ដឹងពីផ្លូវចិត្តដើម្បីជួយដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាពង្រីកការយល់ដឹងផ្នែកសុខភាពផ្លូវចិត្ត ជាមួយចំនួនប្រជាជនទូទៅ។ ដោយធ្វើការយ៉ាងជិតស្និតជាមួយអង្គភាពគាំពារជំនាញ និងសាក្សី និងអង្គភាពគាំទ្រជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គការអន្តរវប្បធម៌ចិត្តសង្គម បានផ្តល់ជាសេវាកម្មផ្លូវចិត្តជាច្រើនសណ្ឋានតាមរយៈអ្នកជំនាញជនជាតិខ្មែរនានាជាច្រើន។ ទាំងនេះរាប់ចាប់តាំងពីការផ្តល់ការគាំទ្រផ្នែកស្មារតីនៅនឹងកន្លែង ក្នុងអំឡុងពេលនិងបន្ទាប់ពីដំណើរ

ការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារហូត ដល់ការផ្តល់ការព្យាបាលផ្នែកផ្លូវចិត្តម្នាក់ៗ និងជាលក្ខណៈក្រុមអ្នកដែលជួយខ្លួនឯងតាមសហគមន៍។

អង្គភាពគាំទ្រជនរងគ្រោះ (VSS) ត្រូវបានបង្កើតឡើងដើម្បីគាំទ្រ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយជួយជនរងគ្រោះ ដែលចង់ចូលរួមក្នុងដំណើរការសវនាការនេះ។ អង្គភាពគាំទ្រជនរងគ្រោះ គឺជាមឈ្ឍមណ្ឌលទំនាក់ទំនងរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាមួយជនរងគ្រោះឬអ្នកតំណាងរបស់ពួកគេ។ អង្គភាពគាំទ្រជនរងគ្រោះ មានគោលដៅសម្របសម្រួលការចូលរួមដោយមានប្រសិទ្ធិភាពរបស់ជនរងគ្រោះក្នុងដំណើរការសវនាការនេះ។ វាមានដូចជា ការដាក់ពាក្យបណ្តឹង និងការសុំទម្រង់បែបបទនានារបស់ជនរងគ្រោះ ដែលចង់ប្រើប្រាស់សិទ្ធិរបស់គេដើម្បីចូលរួមសវនាការនេះ។ អង្គភាពគាំទ្រជនរងគ្រោះ ក៍មើលផងដែរថាជនរងគ្រោះនឹងមានតំណាងច្បាប់ប្រកបដោយគុណភាព។ លើសពីនេះទៅទៀតអង្គភាពគាំទ្រជនរងគ្រោះក៍ផ្តល់ការគាំទ្រផ្នែកច្បាប់ និងរដ្ឋបាលដល់មេធាវី និងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ អង្គភាពគាំទ្រជនរងគ្រោះ ក៍បំរើជាទីតាំងជួបជុំរបស់អ្នកដែលពាក់ព័ន្ធក្នុងដំណើរការនេះផងដែរ ដែលមានដូចជា ជនរងគ្រោះ បុគ្គលិកតុលាការ មេធាវី និងអង្គការអន្តរៈការីនានា ដែលអាចបញ្ចេញមតិយោបល់ចូលរូមដើម្បីជាតំណាងដ៏មានប្រសិទ្ធិភាព គោលដៅបម្រើប្រយោជន៍ជនរងគ្រោះ។ អង្គភាពគាំទ្រជនរងគ្រោះជម្រាបជូនជនរងគ្រោះអំពីសិទ្ធិដែលពួកគេមានក្នុងការចូលរួម និងបំណងផ្សេងៗ និងអាចអោយគាត់ដាក់ពាក្យបណ្តឹង និងជាដើមបណ្តឹងរដ្ឋប្បវេណីទៅដល់អង្គជំនុំជម្រះ វិសាមញ្ញតុលាការកម្ពុជា ប្រសិនបើពួកគេមានបំណងដូចនេះ (ព័ត៌មានលំអិតសូមមើលការណែនាំអនុវត្តអំពីការចូលរួមរបស់ជនរងគ្រោះ)។ ល័ក្ខខ័ណ្ឌតម្រូវក្នុងនោះក៏មានការនិយាយពីវិធាននៃជំនួយដែលអាចទទួលបានដូចជា ការប្រឹក្សាច្បាប់ ឬទទួលបានមេធាវីជំនួយការតំណាងផ្លូវច្បាប់ និងសម្របសម្រួលការបែងចែកជាក្រុម និងសំណងជាមូលភាពរបស់ជនរងគ្រោះ។ អង្គភាពគាំទ្រជនរងគ្រោះ គាំទ្រទៅលើការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតដោយជួយជំរុញដំណើរការពាក្យបណ្តឹង និងការស្នើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីព្រមទាំងរៀបចំរបាយការណ៍សម្រាប់ការិយាល័យទាំងនេះ។ អង្គភាពនេះក៏រក្សាទំនាក់ទំនងជាមួយជនរងគ្រោះ និងមេធាវីរបស់ពួកគេដែលទាក់ទង និងស្ថានភាពបណ្តឹង និងពាក្យសុំរបស់ពួកគេ ហើយជម្រាបជូនមកវិញជាព័ត៌មានជុំវិញការវិវត្តន៍រឿងក្តីរបស់បុគ្គលម្នាក់ៗទៀតផង។ អង្គភាពគាំទ្រជនរងគ្រោះបានធ្វើការប្រាកដប្រជាថា តួនាទីនៃផ្នែកនេះជាមួយ និងសិទ្ធិជនរងគ្រោះ ត្រូវបានពន្យល់បកស្រាយតាមរយៈកម្មវិធីផ្សព្វផ្សាយ ដែលប្រព្រឹត្តទៅនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ជាចុងក្រោយ អង្គភាពគាំទ្រជនរងគ្រោះធ្វើអោយប្រាកដនូវសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះដែលចូលរួមក្នុងសវនាការនេះ ត្រូវបានរក្សាការពារ។ នេះក៏ទាក់ទងទៅនឹងការផ្តល់ការយល់ច្បាស់លាស់ និងត្រឹមត្រូវអំពីផលប៉ះពាល់ដែលអាចកើតឡើងពីការចូលរួមនេះ ក៏ដូចជាការផ្តល់នូវវិធានការការពារ និងទំនុកបម្រុងផ្សេងទៀតដូចជាការគាំទ្រផ្លូវចិត្តជាដើម។

# ឧបសម្ព័ន្ធ ក៖ របៀបវារៈកម្មវិធីការស្តាប់សម្លេងស្រ្តី

## ការស្តាប់សម្លេងស្រ្តីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះ ថ្ងៃទី ១០-១១ ខែតុលា ឆ្នាំ២០១២

| | |
|---|---|
| ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២ | |
| ៧.៣០ ដល់ ៨.០០ ព្រឹក | ចុះឈ្មោះអ្នកចូលរួម |
| ៨.០០ ដល់ ៨.១០ | ការសំដែងការស្វាគមន៍ និងនិតិវិធីកម្មវិធី |
| ៨.១០ ដល់ ៨.២៥ | បើកកម្មវិធី<br>ដោយ ឯកឧត្តម ហោ ម៉ាលីន អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី |
| ៨.២៥ ដល់ ៨.៤៥ | សារវីដេអូដោយគណៈវិនិច្ឆ័យសំខាន់<br>លោកស្រី ហ្សែណាប់ បានហ្គូរ៉ា អ្នកតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកស្តីពីហិង្សាផ្លូវភេទពេលមានជម្លោះ |
| ៨.៤៥ ដល់ ៩.០០ | កែណែនាំរបស់គណៈវិនិច្ឆ័យ |
| ៩.០០ ដល់ ៩.៣០ | អ្នកជំនាញសក្ខីកម្ម ជម្លោះទាក់ទងនឹងហិង្សាយេនឌ័រប្រឆាំងនឹងស្រ្តី និងក្មេងស្រី<br>អ្នកស្រី ស៊ីល ស្ទូដហ្វ៊ីនស្តី អ្នកប្រឹក្សាអន្តរជាតិដើម្បីដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមេធាវីនៅក្រុងប៊ើលីនប្រទេស អាល្លឺម៉ង់ |
| ៩.៣០ ដល់ ១០.០០ | សម្រាក |
| ១០.០០ ដល់ ១១.៤៥ ថ្ងៃត្រង់ | សក្ខីកម្មពីប្រទេសនេប៉ាល់ |
| ១១.៤៥ ដល់ ១.១៥ | អាហារថ្ងៃត្រង់ |
| ១.១៥ ដល់ ១.៤៥ | អ្នកជំនាញសក្ខីកម្ម ដំណើរការក្នុងនិងក្រៅប្រព័ន្ធតុលាការដើម្បីយុត្តិធម៌យេនឌ័រ<br>អ្នកស្រី ស៊ូសាណា ស៊ីគូតូ ប្រធានការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម និងគ្រូជំនាញសាកលវិទ្យាល័យអាមេរិក ទីក្រុងវ៉ាស៊ីនតោន នៃមហាវិទ្យាល័យ ច្បាប់ |
| ១.៤៥ ដល់ ៣.៣០ | សក្ខីកម្មពីប្រទេសបង់ក្លាដេស |
| ៣.៣០ ដល់ ៤.០០ | សម្រាក |
| ៤.០០ ដល់ ៤.១៥ | ការត្រៀមលក្ខណៈផ្លូវចិត្តនៅក្រោយហេតុការណ៍ |
| ៤.១៥ ដល់ ៤.៣០ ល្ងាច | បិទបញ្ចប់ |
| ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១២ | |
| ៧.៣០ ដល់ ៨.០០ ព្រឹក | ចុះឈ្មោះ |
| ៨.០០ ដល់ ៨.៣០ | ការស្វាគមន៍ និងនិតិវិធី |

| | |
|---|---|
| ៨.៣០ ដល់ ៩.០០ | សវនាការមនសិការ – ករណីសិក្សាពីប្រទេសហ្គោតាមេឡា<br>អ្នកស្រី ម៉ូនីកា ពិណហ្សូន អ្នកជំនាញចិត្តសាស្ត្រសង្គម សិក្សាសហគមន៍ និងសកម្មភាពចិត្តសាស្ត្រ (ECAP) |
| ៩.០០ ដល់ ៩.៣០ | សម្រាក |
| ៩.៣០ ដល់ ១១.១៥ ថ្ងៃត្រង់ | សក្ខីកម្មពីប្រទេស ទីម័រ |
| ១១.១៥ ដល់ ១២.៤៥ | អាហារថ្ងៃត្រង់ |
| ១២.៤៥ ដល់ ២.៤៥ | សក្ខីកម្មពីប្រទេសកម្ពុជា |
| ២.៤៥ ដល់ ៣.១៥ | សម្រាក |
| ៣.១៥ ដល់ ៣.៤៥ | អ្នកជំនាញសក្ខីកម្ម ស្ត្រី សន្តិភាព និងសន្តិភាព<br>អ្នកស្រី អេនី ម៉ារី ហ្គោអេឌស៏ ប្រធានប្រឹក្សានៃការគ្រប់គ្រង សន្តិភាព និងសន្តិភាព នៃអង្គការសហប្រជាជាតិ |
| ៣.៤៥ ដល់ ៤.៣០ | បើកការពិភាក្សា |
| ៤.៣០ ដល់ ៥.០០ | ការថ្លែងរបស់គណៈវិនិច្ឆ័យ |
| ៥.០០ ដល់ ៥.១៥ | ការត្រៀមលក្ខណៈផ្លូវចិត្តនៅក្រោយហេតុការណ៍ |
| ៥.១៥ ដល់ ៥.៣០ ល្ងាច | បិទបញ្ចប់កម្មវិធី<br>លោក សុក សំអឿន នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា |

# ឧបសម្ព័ន្ធ ខ: សំនៅរសក្ខីកម្មរបស់អ្នករស់រាន មានជីវិត និងសាក្សី

## ការស្តាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះ
## ថ្ងៃទី១០, ១១ ខែតុលា ឆ្នាំ២០១២
## ការសង្ខេបពីសក្ខីកម្ម

### ប្រទេសបង់ក្លាដេស

***អ្នកស្រី ម៉ូសាម៉ាត់ រ៉ាជា ខាត់តុន កាម់ឡា*** *មានអាយុ៥៥ឆ្នាំ ដែលនាពេលមានជម្លោះ អ្នកស្រីបានត្រូវគេចាប់រំលោភសេពសន្ថវៈ ធ្វើជាទាសករផ្លូវភេទ ឃុំឃាំងដោយខុសច្បាប់ និងធ្វើទារុណកម្ម។*

កាលពីឆ្នាំ១៩៧១ អ្នកស្រី កាម់ឡា មានអាយុ១៤ឆ្នាំ។ អ្នកស្រីបានរៀបអាពាហ៍ពិពាហ៍៣ខែមុនសង្គ្រាមកើតឡើង។ ប៉ុន្តែដោយសារតែអ្នកស្រីមានវ័យក្មេងនៅឡើយ អ្នកស្រីមិនបានរួមរស់ជាមួយស្វាមីរបស់អ្នកស្រីឡើយ តែអ្នកស្រីបានទៅរស់នៅជាមួយឪពុកម្តាយរបស់អ្នកស្រី។ ដោយសារតែការបារម្ភផ្នែកសុវត្ថិភាព អ្នកស្រីបានផ្លាស់ទីលំនៅទៅរស់នៅជាមួយសាច់ថ្លៃរបស់អ្នកស្រីវិញនៅពេលសង្គ្រាមផ្ទុះឡើង។ ផ្ទះរបស់ឪពុកម្តាយអ្នកស្រីត្រូវបានវាយប្រហារដោយទាហានប៉ាគីស្ថាននិងរ៉ាហ្សាកា ហើយឪពុកអ្នកស្រីត្រូវបានគេសម្លាប់។ បន្ទាប់មក ផ្ទះរបស់សាច់ថ្លៃរបស់អ្នកស្រីត្រូវបានវាយប្រហារ ហើយសាច់ញាតិរបស់អ្នកស្រី ក៏ត្រូវបានសម្លាប់ផងដែរ។ អ្នកស្រីបានភៀសខ្លួនជាមួយម្តាយក្មេក ពីកងទ័ពប៉ាគីស្ថាននិងរ៉ាហ្សាកា ប៉ុន្តែត្រូវវង្វេងនៅពាក់កណ្តាលផ្លូវ។

បន្ទាប់មកមានបុរសម្នាក់ (កងកម្លាំងរ៉ាហ្សាក់) បានប្រទះឃើញអ្នកស្រី ហើយបាននាំខ្លួនអ្នកស្រីទៅជំរំទ័ពទាំងមន្ទិលសង្ស័យ។ នៅទីនោះ អ្នកស្រីបានឃើញមនុស្សមួយចំនួនទៀតត្រូវបានគេបិទភ្នែក ហើយធ្វើទារុណកម្មដោយអ្នករួមដៃនៅទីនោះ។ អ្នកស្រីត្រូវបានគេសម្រាតខោអាវ ហើយចងភ្ជាប់ទៅនឹងសសរមួយដោយទាហាន ២ ឬ ៣នាក់។ អ្នកស្រីត្រូវបានទាហានប៉ាគីស្ថាន៣នាក់ចាប់រំលោភ ហើយត្រូវបានចងទុកចោលនៅជាប់សសរនៅយប់នោះ។ ពេញមួយយប់ អ្នកស្រីរងនូវការឈឺយ៉ាងខ្លាំងត្រង់ខាងក្រោមពោះ ផ្លូវភេទ ភ្លៅទាំងសងខាង ហើយ (សងខាងនៃផ្លូវភេទរបស់អ្នកស្រី) ត្រូវរងរបួសដោយសារតែការរំលោភសេពសន្ថវៈយ៉ាងឃោរឃៅនេះ។ បន្ទាប់មក គេបានផ្តល់អោយអ្នកស្រីក្រណាត់មួយដុំតូចសម្រាប់បិទបាំងរាងកាយ បន្ទាប់ពីអ្នកស្រីបានលាងឈាមដែលហូរមិនឈប់ឈរចេញពីផ្លូវភេទរបស់អ្នកស្រី។

អំឡុងពេល១៤ទៅ១៥ថ្ងៃដែលអ្នកស្រីត្រូវបានគេឃុំខ្លួន អ្នកស្រីបានជួបប្រទះនូវការសម្លាប់ជនជាតិបង់ក្លាដេស្សដែលគ្មានកំហុសជាច្រើនរយនាក់ ដែលដំបូងឡើយត្រូវបានគេចាប់ខ្លួនធ្វើទារុណកម្ម ហើយបាញ់សម្លាប់ដោយទាហានប៉ាគីស្ថាន និងអ្នកចូលដៃ។ អ្នកស្រីក៏បានឃើញការចាប់ខ្លួនក្មេងស្រីជាច្រើននាក់ ដែលគ្មានសម្លៀកបំពាក់ទាល់តែសោះ នៅពេលគេនាំខ្លួនមកជំរំ ហើយអ្នកស្រីក៏បានឃើញករណីរំលោភសេពសន្ថវៈជាច្រើនផងដែរ។ អស់រយៈពេលជាង១៥ថ្ងៃក្រោយមក អ្នកស្រីក៏បានភៀសខ្លួន ហើយជាសំណាងរបស់អ្នកស្រីដែរ ដែលបានមកជួបជាមួយអ្នក

ប្រយុទ្ធដើម្បីសេរីភាពបង់ក្លាដេសនៅតាមផ្លូវ ហើយពួកគេក៏បានជូនដំណើរអ្នកស្រី និងផ្ដល់ថ្នាំសង្កូវសម្រាប់ព្យាបាលរបួសផងដែរ។

ប៉ុន្តែជីវិតរបស់អ្នកស្រីជួបប្រទះការលំបាកនៅឡើយ បើទោះប្រទេសនេះទទួលបានឯករាជ្យក៏ដោយ ក៏អ្នកស្រីមិនទាន់មានជំរកនៅឡើយ។ មានបុរសម្នាក់បានបោកប្រាស់អ្នកស្រី ហើយអ្នកស្រីត្រូវបានបុរសម្នាក់នោះនាំទៅកាន់កាប់កន្លែងរកស៊ីផ្លូវភេទមួយដែលគ្រប់គ្រងដោយស្ត្រីម្នាក់ឈ្មោះ ហ្សូសូម៉ា។ អ្នកស្រីត្រូវបានគេបង្ខំអោយប្រឡូកក្នុងការងារនេះអស់រយៈពេលជាង៣ឆ្នាំ។ នៅទីនោះ អ្នកស្រីបានជួបបុរសឈ្មោះ ខុឌុ ដោយគាត់ជាអតិថិជនម្នាក់ ប៉ុន្តែអ្នកស្រីបានពន្យល់គាត់ដោយបានរៀបរាប់រឿងរ៉ាវរបស់អ្នកស្រី។ បន្ទាប់ពីហ្សូសូម៉ាបានស្លាប់ទៅ លោក ខុឌុ បាននាំអ្នកស្រីចេញពីទីនោះ ហើយក៏រៀបអាពាហ៍ពិពាហ៍ជាមួយអ្នកស្រី។ ប្ដីអ្នកស្រីបានទទួលអនិច្ចកម្មកាលពី២១ ឆ្នាំមុន។

ដោយសារភាពក្មេងខ្ចីរបស់អ្នកស្រីនាពេលនោះ និងដោយសារអ្នកស្រីបានជួបនូវហិង្សាផ្លូវភេទ អ្នកស្រីត្រូវប្រឈមមុខនឹងស្លាកស្នាមទុយ៌សដែលបានបន្សល់ទុកបន្ទាប់ពីឯករាជ្យរបស់ប្រទេសនេះ។ ស្លាកស្នាមនេះបានន័យថាអ្នកស្រីមិនត្រូវបានសង្គមទទួលស្គាល់ឡើយ។ ដូចនេះបន្ទាប់ពីសង្គ្រាមភ្លាម អ្នកស្រីបានផ្លាស់លំនៅដោយសារមនុស្សម្នាដឹងថា អ្នកស្រីត្រូវបានគេរំលោភសេពសន្ថវៈ។



ជីវិតរបស់អ្នកស្រីជួបការលំបាកដល់ថ្នាក់នេះ ដោយសារអ្នកស្រីត្រូវបានគេរំលោភ និងបង្ខំអោយរកស៊ីផ្លូវភេទ។ អ្នកស្រីនៅតែត្រូវបានគេរើសអើង ហើយត្រូវប្រឈមមុខនឹងស្លាកស្នាមទុយ៌សដែលនៅក្នុងសហគមន៍ថ្មី។ កូនប្រុសទាំងពីររបស់អ្នកស្រីមិនត្រូវបានគេទទួលស្គាល់ឡើយ ដោយសារពួកគេគឺជាកូនរបស់ស្ត្រីដែលត្រូវបានគេរំលោភកាលពីសង្គ្រាមរំដោះជាតិ និងដោយសារពួកគេគឺជាកូនរបស់ស្ត្រីរកស៊ីផ្លូវភេទ។

***អ្នកស្រី សាលេហា បេគហ្គាំ*** *មានអាយុ៥៥ឆ្នាំ។ អំឡុងពេលសង្គ្រាមរំដោះជាតិ អ្នកស្រីបានជួបប្រទះនឹងការបង្ខំអោយធ្វើទាសករផ្លូវភេទ អំពើរំលោភសេពសន្ថវៈ មានគភ៌ដោយបង្ខំ និងការឃុំឃាំងដោយខុសច្បាប់ និងការធ្វើទារុណកម្ម។*

នៅពេលការប៉ះទង្គិចផ្ទុះឡើង អ្នកស្រីមានអាយុ១៤ឆ្នាំ ហើយអ្នកស្រីរស់នៅជាមួយម្ដាយឪពុក ប្អូនស្រី៣នាក់ និងប្អូនប្រុសម្នាក់។ នៅពេលកងទ័ពប៉ាគីស្ថានវាយប្រហារភូមិរបស់អ្នកស្រី ឪពុកអ្នកស្រីបានជីករណ្ដៅមួយ ហើយលាក់អ្នកស្រី និងប្អូនស្រីអ្នកស្រី ដើម្បីកុំអោយទាហានប៉ាគីស្ថានមើលឃើញ។ ប៉ុន្តែរ៉ាហ្សាកាបានប្រាប់ទៅទ័ពអំពីបញ្ហានេះ ហើយនាព្រឹកមួយទាហានទាំងនេះបានមកចាប់ស្ត្រីក្មេងៗពីផ្ទះពួកគេយកទៅជំរំ។ អ្នកស្រី សាឡេហា ប្អូនស្រីអ្នកស្រី និងអ្នកជិតខាងក៏ត្រូវបានចាប់ខ្លួនផងដែរ។ នៅថ្ងៃដែលអ្នកស្រី ត្រូវបាននាំខ្លួនមកដល់ជំរំទ័ព អ្នកស្រីឃើញក្មេងស្រីជាច្រើនផ្សេងទៀត ត្រូវរងទារុណកម្ម និងសម្លាប់។ អ្នកស្រីត្រូវបានគេរំលោភនៅយប់ដំបូងពេលអ្នកស្រីត្រូវគេចាប់យកមក។ គេបានចងមាត់ និងដៃអ្នកស្រីឡើងលើសម្រាតខោអាវ ហើយរំលោភអ្នកស្រីនៅនឹងមុខប្អូនស្រីអ្នកស្រី និងក្មេងស្រីផ្សេងទៀត ដែលធ្វើអោយមានការរងរបួសយ៉ាងធ្ងន់ធ្ងរទៅលើផ្លូវភេទ មានហូរឈាម និងមានស្នាមជាអចិន្ត្រៃយ៍ទៀតផង។ អ្នកស្រីត្រូវបានគេរំលោភតាមរន្ធគូទ និងបំពានផ្លូវភេទដោយមានទាំងការរួមភេទតាមមាត់ជាដើម។ ពីខែក្រោយមកអ្នកស្រីត្រូវបានគេបញ្ជូនទៅជំរំខុលណា ហ្គូឡាម៉ារី អស់រយៈពេលពីរខែទៀត។ អ្នកស្រី

បានឃើញការសម្លាប់ជនរងគ្រោះ អំពើហិង្សាផ្លូវភេទ និងការចាប់ខ្លួនមនុស្សជារៀងរាល់ល្ងាចនៅស្ពានទន្លេមួយ។ ក្មេងស្រីដែលមានផ្ទៃពោះមានភាគរយច្រើនដែលត្រូវបានគេសម្លាប់។ អ្នកស្រី សាឡេហា និងក្មេងស្រី៦នាក់ផ្សេងទៀតក៏មានផ្ទៃពោះ ហើយត្រូវបានគេនាំទៅកាន់ស្ពានមួយដើម្បីសម្លាប់។ អ្នកស្រីត្រូវបានគេបាញ់ត្រូវជើង ប៉ុន្តែអ្នកស្រីនៅមានជីវិត។ ចំណែកឯអ្នកដ៏ទៃទៀតត្រូវស្លាប់ទាំងអស់ ក្នុងនោះក៏មានប្អូនស្រីរបស់អ្នកស្រីផងដែរ។

បន្ទាប់ពីអ្នកស្រីបានគេចខ្លួនរួចមក អ្នកស្រីបានមកប្រទេសឥណ្ឌា អ្នកស្រីត្រូវបានគេផ្តល់អោយតែការសង្គ្រោះបឋមប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់សម្រាប់ព្យាបាលរបួសអ្នកស្រីឡើយ។ អ្នកស្រីបានធ្វើមាតុភូមិនិវត្តន៍វិញ បន្ទាប់ពីប្រទេសបង់ក្លាដេស្សទទួលបានឯករាជ្យ។ អ្នកស្រីបានជួបម្តាយអ្នកស្រី ដែលក្រោយមកបាននាំអ្នកស្រីទៅរកគ្រូពេទ្យម្នាក់ដើម្បីយកកូនចេញប៉ុន្តែមិនអាចធ្វើបាន ដោយសារគភ៌មានអាយុ៧ខែទៅហើយ។ ម្តាយអ្នកស្រីបានបោះបង់អ្នកស្រីចោលភ្លាមៗ ដោយសារសំពាធពីសង្គម និងរឿងរ៉ាវដ៏ជូរចត់នេះ។ គ្មានជំរក និងកំពុងមានគភ៌ អ្នកស្រី សាឡេហា បានមកជ្រកកោនជាមួយគ្រួសារក្រីក្រមួយនៅតំបន់អានាធិបតេយ្យមួយ។ អ្នកស្រីបានផ្តល់កំណើតនូវកូនប្រុសមួយតែបានស្លាប់ទៅវិញ៤ថ្ងៃក្រោយមក ដោយសារទារកនេះមានជំងឺជាទម្ងន់ និងដោយសារអ្នកស្រីគ្មានធនធាន ឬក៏សមាជិកគ្រួសារដែលអាចជួយបាន។

បន្ទាប់មកអ្នកស្រីបានផ្លាស់មកនូវសង្កាត់ ដាកា ហើយបានធ្វើការជាអ្នកបំរើនៅគេហដ្ឋានកីឡាករបាល់ទាត់ម្នាក់អស់រយៈពេល ១០ ទៅ ១២ឆ្នាំ។ ក្រោយមក អ្នកស្រីបានរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីរបស់អ្នកស្រីឈ្មោះ ហ្គាស៊ីដែលក្រោយមក បានដឹងរឿងរ៉ាវរបស់អ្នកស្រីកាលនៅឆ្នាំ១៩៧១ ហើយចង់លែងលះអ្នកស្រី ប៉ុន្តែមិនអាចធ្វើបាន ដោយសារអ្នកស្រីមានផ្ទៃពោះទៅហើយនាពេលនោះ។ បច្ចុប្បន្ននេះ អ្នកស្រីរួមរស់ជាមួយស្វាមីអ្នកស្រី ដោយមានកូនស្រីម្នាក់អាយុ១៨ឆ្នាំ ហើយនាងក៏បានរៀននៅមហាវិទ្យាល័យផងដែរ។



## ប្រទេសកម្ពុជា

***អ្នកស្រី ហុង សាវ៉ាត*** *មានអាយុ៤៥ឆ្នាំ។ អ្នកស្រីរស់នៅក្នុងឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមាន មុខរបរជាមេផ្ទះ។ មុនរបបខ្មែរក្រហមអ្នកស្រីគឺជាសិស្សនៅក្រុងភ្នំពេញ។ អំឡុងរបបខ្មែរក្រហម អ្នកស្រីបានឃើញ អំពើបំពាន ឃាតកម្ម ការបង្ខំអោយរៀបការ ការភៀសខ្លួន អំពើជម្លៀស បង្ខំអោយធ្វើការ និងការរំលោភសេព សន្ថវៈ។ ក្នុងឆ្នាំ១៩៧៥ គ្រួសារអ្នកស្រី និងអ្នកស្រី ត្រូវបានគេធ្វើការភៀសខ្លួនដោយបង្ខំទៅភ្នំពេញ បន្ទាប់មកទៅខេត្តពោធិសាត់។*

នៅឆ្នាំ១៩៧៨ ម្តាយអ្នកស្រីមានជម្ងឺជាទម្ងន់ តែប្អូនប្រុសរបស់អ្នកស្រីបានមកសួរសុខទុក្ខ និងបានយកអាហារមកផងដែរ។ ប្អូនរបស់អ្នកស្រី ត្រូវបានគេចាប់ខ្លួន និងវាយដំដោយកងកម្លាំងខ្មែរក្រហមដែលគេស្គាល់ថាជាកងឈ្លប ហើយត្រូវបានគេចោទប្រកាន់ថាបានលួចអាហាររបស់អង្គការ។

បន្ទាប់មកប្អូនស្រីទាំងពីររបស់អ្នកស្រីត្រូវគេបង្ខំអោយរៀបការ។ អ្នកស្រី និងឪពុកម្តាយអ្នកស្រី ត្រូវបានគេអញ្ជើញចូលរួមក្នុងពីធីរៀបការនេះដែលមានទាំងអស់២០គូ។ នៅពេលប្អូនស្រីរបស់អ្នកស្រីម្នាក់ធ្វើការប្តេជ្ញា នាង

បានយំហើយរត់ទៅអោបម្ដាយឪពុករបស់នាង។ ភ្លាមៗនោះ កងឈ្លបបានចាប់បំបែកពួកគេ ហើយអូសប្អូនស្រីអ្នកស្រីចេញពីនោះប្រហែល២,៥ម៉ែត្រ ហើយបានចាក់ពីក្រោយខ្នង ដោយកាំបិត២, ៣ដងទៀតផង។ តែមុននោះបន្ទាប់មក អ្នកស្រី និងឪពុកម្ដាយអ្នកស្រីបានដើរចេញពីទីនោះ ដោយមិនបានដឹងរឿងអ្វីកើតឡើងលើប្អូនស្រីអ្នកស្រី និងអ្នកដ៏ទៃផ្សេងទៀតឡើយ។

២ ឬ ៣ខែ បន្ទាប់ពីការបាត់បង់ប្អូនប្រុសស្រីរបស់អ្នកស្រី ម្ដាយឪពុកអ្នកស្រីក៏បានធ្លាក់ខ្លួនឈឺជាទម្ងន់។ ជាញឹកញយអ្នកស្រីបានលួចអាហារជ្រូក និងក្ដួចមកអោយពួកគាត់។ ថ្ងៃមួយឪពុកអ្នកស្រីបានលួចមាន់យកមកធ្វើជាអាហារ។ កងឈ្លបក៏បានចាប់ទាំងឪពុក និងម្ដាយអ្នកស្រីយកទៅសម្លាប់។ នាពេលល្ងាចនោះ ដែលអ្នកស្រីបានមកពីធ្វើការងារ អ្នកស្រីមិនបានឃើញឪពុកម្ដាយអ្នកស្រីឡើយ។ តែអ្នកស្រីបានប្រទះឃើញអ្នកទាំងពីរ ត្រូវបានគេចងឈរនៅវាលពិឃាតមួយជាមួយសាកសពដ៏ទៃទៀត។ អ្នកស្រីបានរត់ទៅអោបម្ដាយអ្នកស្រី។ បន្ទាប់មកអ្នកស្រីបានឃើញឧក្រិដ្ឋជនបានវាយ និងចាក់ឪពុកអ្នកស្រីនឹងកាំបិតមុខស្រួច។ ហើយពួកវាបានមកបំបែកអ្នកស្រីចេញពីម្ដាយអ្នកស្រី ដែលពេលនោះមានមួយចំនួនបានអូសអ្នកស្រីចូលព្រៃខ្លះទៀតកំពុងសម្លាប់ម្ដាយអ្នកស្រី។

បន្ទាប់ពីអ្នកស្រីត្រូវបានគេអូសចេញទៅ ពួកវាបានដោះសម្លៀកបំពាក់អ្នកស្រី ហើយពួកវាបីនាក់បានរំលោភអ្នកស្រីរហូតបាត់បង់ស្មារតី។ នៅពេលអ្នកស្រីដឹងខ្លួនឡើងវិញ អ្នកស្រីដើរសំដៅទៅផ្ទះតែឧក្រិដ្ឋជនម្នាក់ក្នុងចំណោមទាំងបីនាក់នោះ ឈ្មោះ រិទ្ធ បានប្រាប់អ្នកស្រីអោយភៀសខ្លួន ទៅជំរំសហករណ៍ផ្សេងទៀត បើមិនដូច្នោះទេអ្នកស្រីនឹងត្រូវគេសម្លាប់មិនខាន។ អ្នកស្រីក៏ធ្វើតាម ពេលខ្លះរិទ្ធបានមកនៅជាមួយអ្នកស្រី។ បន្ទាប់មកអ្នកស្រីមានគភ៌ដោយសារការរំលោភនោះ ហើយបានផ្ដល់កំណើតអោយទារកម្នាក់មានអាយុជាង៤ខែ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។

***អ្នកស្រី សុខ សាមិត*** *មានអាយុ៥២ឆ្នាំ រស់នៅក្រុងភ្នំពេញ។ អ្នកស្រីមានមុខរបរជាអ្នកធ្វើការតាមផ្ទះអោយគ្រួសារ ជនជាតិអាមេរិកមួយ ហើយអ្នកស្រីក៏ជាអ្នកធ្វើការស្ម័គ្រចិត្តអោយ សមាគមសិទ្ធិមនុស្សកម្ពុជាអន្តរជាតិផងដែរ។ អ្នកស្រីបានរងការបង្ខំអោយធ្វើការនៅក្នុងកងចល័តនារី ហើយអ្នកស្រីក៏បានឃើញស្ត្រីជនជាតិវៀតណាមត្រូវគេចាប់រំលោភទៀតផង។*

នៅឆ្នាំ១៩៧៥ នៅពេលរបបខ្មែរក្រហមឡើងកាន់អំណាច អ្នកស្រីមានអាយុ១៥ឆ្នាំ និងជាសិស្សនៅក្រុងភ្នំពេញ។ ជីវិតក្រោមរបបនេះមានការលំបាកណាស់ ដោយសារអ្នកស្រីត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី ដែលជាពាក្យប្រើសម្រាប់អ្នកដែលត្រូវបានបង្ខំអោយភៀសខ្លួនពីទីក្រុងទៅជនបទ។ ដូចអ្នកដ៏ទៃផ្សេងទៀតដែរ អ្នកស្រីជួបប្រទះការអត់ឃ្លាន និងការបង្ខំអោយធ្វើការហួសកម្លាំង។

បងស្រីរបស់អ្នកស្រីមានអាយុ២៤ឆ្នាំ ដែលពេលនោះប្ដីរបស់បងស្រីអ្នកស្រី បានលាចាកលោកជាង៧ខែមកហើយ។ អ្នកស្រីបានឃើញនូវការចាប់បង្ខំអោយរៀបការរវាងបងស្រីអ្នកស្រីជាមួយបុរសអាយុ៦០ឆ្នាំម្នាក់ ដែលជាអ្នកកាន់ភស្តុភានៅស្រុកមួយរបស់ខ្មែរក្រហម។ ពួកគេបានគំរាមថា ប្រសិនបើបងស្រីអ្នកស្រីមិនរៀបការទេ គ្រួសារអ្នកស្រី និងមានបញ្ហាជាមិនខាន។ បងស្រីអ្នកស្រីបានរៀបការដោយសារចង់ការពារគ្រួសារ ហើយនាពេលរៀបការ

នោះដែរ បងស្រីរបស់អ្នកស្រីត្រូវគេរំលោភ។ បងអ្នកស្រីមានទម្ងន់តែគាត់មិនចង់បានកូននេះទេ ហើយគាត់ក៏បានយកកូននោះចេញ។

អ្នកស្រី សុខ សាមិត ក៏បានដឹងការរំលោភសេពសន្ថវៈលើស្ត្រីវៀតណាមឈ្មោះ អ៊ុកដែលមានអាយុ២៧ឆ្នាំ។ ប្តីរបស់អ្នកស្រីអ៊ុកធ្វើជាទាហានខ្មែរក្រហមចេញទៅច្បាំងបាត់យូរ។ អ្នកស្រីអ៊ុកព្យាយាមរកពត៌មានអំពីប្តីខ្លួន ដូចនេះអ្នកស្រីក៏បានទៅរកមេថ្នាក់ស្រុកខ្មែរក្រហមម្នាក់ដែលជាគ្រូទាយ។ បុរសនោះមានអាយុ៥០ឆ្នាំ តែរៀបការ និងមានកូនផង។ បុរសនេះបានប្រាប់អ្នកស្រី អ៊ុក ថាប្រសិនបើគាត់ចង់រកប្តីរបស់ខ្លួនគាត់ត្រូវរួមរក្សជាមួយខ្លួនសិន។ អ្នកស្រីអ៊ុក ក៏យល់ព្រម ហើយជាច្រើនដងទៀតផងរហូតដល់គាត់មានផ្ទៃពោះ។ អ្នកស្រីអ៊ុកបារម្ភថា ខ្លួនបានប្រព្រឹត្តអំពើល្មើសនឹងខុសសីលធម៌ដែលនឹងត្រូវទណ្ឌកម្មដោយខ្មែរក្រហម ដូចនេះគាត់មិនបានប្រាប់អ្នកណាឡើយ។ តែក្រោយមក អ្នកស្រីអ៊ុកត្រូវបានគេដាក់គុក និងធ្វើទារុណកម្ម។ បន្ទាប់មក អ្នកស្រីអ៊ុក ត្រូវគេបង្ខំអោយធ្វើការនៅវាលស្រែទាំងជើងជាប់ច្រវ៉ាក់ និងឆ្លងទន្លេនៅក្នុងពន្ធនាគារ។

***អ្នកស្រី ជុំ លី*** *មានអាយុ៥៨ឆ្នាំ រស់នៅស្រុកកោះធំ ខេត្តកណ្តាល។ អ្នកស្រីជាស្ត្រីមេម៉ាយ និងមានកូនប្រុសម្នាក់។ អ្នកស្រីមានបងប្អូនប្រុសស្រី ១០នាក់ ប៉ុន្តែមានតែ ៥នាក់ទេដែលនៅមានជីវិត។ អ្នកស្រីគឺជាដើមបណ្តឹងរដ្ឋប្បវេណី នៃករណីបង្ខំរៀបការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ មុនរបបខ្មែរបក្រហម អ្នកស្រីគឺជាកសិកររស់នៅស្រុកកោះធំខេត្តកណ្តាល។ អ្នកស្រីធ្លាប់ត្រូវគេវាយដំ ធ្វើទារុណកម្ម បង្ខំអោយរៀបការ រំលោភសេព-សន្ថវៈ និងបង្ខំអោយធ្វើជាគិលានុបដ្ឋាយិកា ទោះបីអ្នកស្រីគ្មានជំនាញក៏ដោយ។*

នៅការិយាល័យស្រុកមានបុរសម្នាក់ដែលជាមេកងខ្មែរក្រហម មានប្រពន្ធ និងកូនផង តែងតែមកសុំអ្នកស្រីអោយជួយចាក់ថ្នាំអោយគាត់។ ដល់លើកទី៣ អ្នកស្រីត្រូវបុរសនេះចង និងវាយដំ ហើយក្រចកដៃអ្នកស្រីត្រូវគៀប២ដងទៀតផង។ អ្នកស្រីមិនបានដឹងពីមូលហេតុអ្វីឡើយ ហើយអ្នកស្រីក៏ត្រូវបានគំរាមមិនអោយប្រាប់អ្នកដ៏ទៃទៀតដែរ។ អ្នកស្រីភ័យខ្លាចណាស់ ហើយក៏មិនចង់ជួបបុរសនេះទៀតដែរ តែបុរសនោះនៅតែទទូចអោយអ្នកស្រីចាក់ថ្នាំអោយខ្លួន។

នៅឆ្នាំ១៩៧៧ អ្នកស្រីត្រូវបានស្នើរបីដង អោយរៀបការជាមួយបុរសម្នាក់ផ្សេងទៀត ដែលរស់នៅក្នុងភូមិនោះ។ អ្នកស្រីមិនអាចបដិសេធបានឡើយ ហើយត្រូវតែរៀបការជាមួយបុរសនេះ ដែលមានជាក្រុម និងចំនួន៨គូរផ្សេងទៀត។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អ្នកស្រីបានរស់នៅជាមួយប្តីអ្នកស្រីរយៈពេល២ឆ្នាំ និងមានកូនប្រុសម្នាក់។ តែក្រោយមក ប្តីអ្នកស្រីបានចាកចោលអ្នកស្រីទៅរៀបការជាមួយនារីម្នាក់ទៀត។ បន្ទាប់ពីរៀបការនោះមកអ្នកស្រីក៏ទៅរស់នៅក្នុងសហករណ៍វិញ តែអ្នកស្រីត្រូវគេធ្វើបាបដោយបុរសដដែលជាមេកង។ អ្នកស្រីត្រូវបុរសនោះចោទថាចង់សម្លាប់គេ នៅពេលបុរសនោះរកឃើញកាំទេចកែវនៅក្នុងបាយ។ អ្នកស្រីក៏ដឹងខ្លួនដែរថាបុរសម្នាក់នេះចង់រំលោភអ្នកស្រីផងដែរដោយពាក្យសម្តីចម្លែករបស់បុរសនោះតែមិនបានសម្រេច។

នៅពេលថ្ងៃត្រង់មួយ អ្នកស្រីមានបំណងចង់ទៅជួបឪពុកម្តាយអ្នកស្រី ដែលពេលនោះ អ្នកស្រីទើបតែសំរាលកូនអាយុជាង៤ខែ។ នៅតាមផ្លូវនៅពេលអ្នកស្រីដើរចូលដល់តំបន់ពន្ធធនាគារដើម្បីឆ្លងទៅផ្ទះឪពុកម្តាយអ្នកស្រី ស្រាប់

តែអ្នកស្រីបានមកដល់ចំនុចត្រួតពិនិត្យមួយ។ អ្នកស្រីត្រូវបានអ្នកយាមពីរនាក់មកនាំអ្នកស្រីទៅក្នុងបន្ទប់ពួកគេ ហើយអោយអ្នកស្រីដោះសម្លៀកបំពាក់។ អ្នកស្រីប្រកែកតែពួកគេបានប្រើកម្លាំងបាយដើម្បីដោះសម្លៀកបំពាក់អ្នកស្រី ហើយរំលោភអ្នកស្រីម្តងម្នាក់រហូតដល់ម៉ោងបីរសៀល។ ពួកគេប្រាប់អ្នកស្រីអោយត្រលប់មកផ្ទះវិញហើយបានគំរាមអ្នកស្រីមិនអោយប្រាប់អ្នកណាឡើយ។ អ្នកស្រីក៏មិនដែលហ៊ាននិយាយរឿងនេះដែរ។

***លោកយាយ គឹម ខែម*** *មានអាយុ៨០ឆ្នាំ គាត់រស់នៅឃុំព្រៃសណ្តែក ស្រុកទ្រាំង ខេត្តតាកែវ។ លោកយាយគឺជាស្ត្រី មេម៉ាយរស់នៅជាមួយកូនៗ និងចៅៗរបស់លោកយាយ។ មុនរបបខ្មែរក្រហម លោកយាយជាកសិករហើយមានទីលំនៅក្នុងស្រុក និងខេត្តដូចសព្វថ្ងៃ។*

ក្នុងអំឡុងរបបខ្មែរក្រហម លោកយាយនិងកូនតូចរបស់លោកយាយ ត្រូវបានគេនាំទៅយកសម្លាប់ជាមួយមនុស្ស ១១នាក់ផ្សេងទៀត។ ប៉ុន្តែចុងក្រោយ លោកយាយ និងកូនត្រូវគេទុកជីវិត ហើយត្រូវគេនាំទៅជំរំពន្ធធនាគារមួយ។ នៅពេលលោកយាយទៅដល់ទីនោះ លោកយាយត្រូវគេចង និងប្រាប់ពីមូលហេតុនោះគឺដោយសារលោកយាយជារឿយៗយំសោកចំពោះការទទួលមរណៈភាពរបស់ប្តី និងម្តាយរបស់លោកយាយ។ នៅថ្ងៃទី៩ នៃរយៈពេលនៅក្នុងពន្ធធនាគារ លោកយាយត្រូវអ្នកទោសម្នាក់ជួយស្រាយចំណង។ ដោយសារតែការចងជាច្រើនថ្ងៃពេកធ្វើអោយមានស្នាមលើរាងកាយលោកយាយរហូតដល់សព្វថ្ងៃ។

ថ្ងៃមួយ កូនតូចលោកយាយស្រេកទឹកយ៉ាងខ្លាំង ហើយពេលនោះអ្នកទោសម្នាក់ឈ្មោះ ពេជ្រ បានហៅអ្នកយាមគុកអោយជួយយកទឹកមកអោយកូនលោកយាយ។ ភ្លាមនោះ មានអ្នកយាមគុកម្នាក់បានមកដល់តែគ្មានទឹកមកជាមួយទេ។ នៅពេលអ្នកយាមគុកនេះមកដល់វាបានជាន់លើទ្រូងកូនលោកយាយ ពេលនោះកូនតូចលោកយាយបានស្លាប់ភ្លាមៗ។

ក្នុងអំឡុងការឃុំខ្លួនរបស់លោកយាយ លោកយាយបានឃើញអ្នកយាមយកដែកក្តៅដាក់ចូលទៅក្នុងប្រដាប់ភេទរបស់ស្ត្រីម្នាក់ ហើយបានស្លាប់ភ្លាមៗ។ ជនរងគ្រោះមានអាយុប្រហែល៣០ឆ្នាំ ដែលត្រូវបានចោទពីបទលួចពោតរបស់អង្គការ។ លោកយាយក៏បានឃើញការបំបែកក្រុមរវាងស្ត្រីក្មេងៗ និងស្ត្រីចាស់ៗចេញពីគ្នា។ ជារឿយៗលោកយាយលឺគេហៅស្ត្រីក្មេងៗទាំងនោះចូលទៅប្រជុំអំពីការធ្វើការពេលថ្ងៃ។ ថ្ងៃមួយលោកយាយបានលឺសម្លេងនារីម្នាក់និយាយថា "សូមកុំធ្វើអំពើដូចនេះមកលើខ្ញុំ"។ តែលោកយាយមិនបានដឹងថា មានរឿងអ្វីកើតឡើងឡើយ។ លោកយាយបានរៀបរាប់ថា របបខ្មែរក្រហមធ្វើទុក្ខបុកម្នេញមកលើស្ត្រីជាខ្លាំង។ សូម្បីស្ត្រីមានផ្ទៃពោះ ក៏ត្រូវបង្ខំអោយធ្វើការយ៉ាងធ្ងន់ធ្ងររហូតដល់ថ្ងៃសំរាល។ បីថ្ងៃក្រោយមកពួកគេត្រូវមកធ្វើការវិញ។

## ប្រទេសនេប៉ាល់

***អ្នកស្រី ស្តាន់ទី ហាម៉ាល់*** *ដែលបានរៀបការ និងមានអាយុ៤២ឆ្នាំរូបនេះ មានទីលំនៅអចិន្ត្រៃនៅភូមិហាគុ សង្កាត់ គណៈកម្មការអភិវឌ្ឍ លេខ៣ សង្កាត់ ជុមឡា ប្រទេសនេប៉ាល់។ អ្នកស្រីត្រូវបានរំលោភ និងបំពានដោយទាហានសន្តិសុខ កងទ័ពរាជានិយមនេប៉ាល់ ហើយនៅតែបន្តមានការប៉ះពាល់ត្រូវជួបដោះស្រាយខាងបញ្ហា*

*ពេទ្យដោយសារការរំលោភរហូតដល់សព្វថ្ងៃ។*

កាលពីឆ្នាំ២០០៤ បន្ទាប់ពីប្តីអ្នកស្រីរៀបការស្រីថ្មីទៀត អ្នកស្រីត្រូវរស់នៅជាមួយកូនស្រីអាយុ១១ឆ្នាំ ហើយអ្នកស្រី ក៏បានបើកហាងតែមួយនៅជិតផ្ទះឪពុកម្តាយអ្នកស្រីនៅក្នុងភូមិនោះផងដែរ។ ពួក Maoists តែងតែមកក្នុងភូមិនេះ ដើម្បីដាក់គ្រាប់បែក។ RNA ក៏តែងតែមកភូមិនេះដែរដើម្បីសួរនាំពីពួក Maoists ដែរ។ ពួក Maoists ធ្លាប់បានដាក់គ្រាប់បែកនៅក្បែរផ្លូវទល់មុខហាងតែអ្នកស្រី។ មានជនស៊ីវិលជាច្រើនបានស្លាប់ និងរបួសពីហេតុការណ៍ផ្ទុះគ្រាប់បែកនេះ។

"កាលនោះដូចជាខែ កញ្ញា ឬតុលា ឆ្នាំ២០០៤ លោកអនុសេនីត្រី ជីវ៉េស ថាប៉ា បានមកហាងតែខ្ញុំ។ គាត់បានសួររកប្តីខ្ញុំ និងប្រាប់ខ្ញុំថាពួកគេទទួលព័ត៌មានមកថា ប្តីខ្ញុំគឺជាពួក Maoist។ ខ្ញុំបានប្រាប់ទៅវិញថា ឥលូវនេះគាត់កំពុងនៅជាមួយប្រពន្ធទីពីររបស់គាត់នៅសង្កាត់ ជុមឡា។ បន្ទាប់មក លោកអនុសេនីត្រី ជីវ៉េស ថាប៉ា និយាយថា "ហៅប្តីរបស់អ្នកឯងក្នុងរយៈពេល១ខែទៀត"។ លោកអនុសេនីត្រីបានមកផ្ទះខ្ញុំ២ដងទៀត ហើយប្រាប់ខ្ញុំអោយនាំប្តីខ្ញុំមកបន្ទាយកងទ័ព។ ខ្ញុំបានប្រាប់ប្តីខ្ញុំដែរតែគាត់មិនស្តាប់ខ្ញុំសោះ។ "

បន្ទាប់ពីការសួរចម្លើយនៅជំរំទ័ព បាវ៉ានី បក់ស៏ ដែលជាកន្លែង ដែលអ្នកស្រីពន្យល់ប្រាប់ថា អ្នកស្រីមិនដឹងរឿងអ្វីទេ អំពីប្តីអ្នកស្រី ហើយអ្នកស្រីមានទំនាក់ទំនងមិនសូវល្អដែរ ជាមួយប្តីអ្នកស្រី។ ក្រុមពួកទាហានទាំងនោះក៏ចាកចេញទៅតែអ្នកស្រីមានអារម្មណ៍ថាមានគេលបចូលបន្ទប់អ្នកស្រី។

"បុរសម្នាក់នោះគឺលោកអនុសេនីត្រី ជីវ៉េស ថាប៉ា ។ ខ្ញុំស្គាល់ដោយសារសម្លេងគាត់។ គាត់និយាយថាបើសិនប្តីរបស់នាងមិនមែនជាពួក Maoist ទេ ហេតុអីបានជាមិនហៅគេមក?" "បើហៅមក គាត់ប្រាកដជាវាយខ្ញុំទៀតមិនខាន។ គាត់ទាត់ធាក់ខ្នងភ្លៅ និងស្ទើរសព្វកន្លែងប្រហែល ១០ ទៅ ១២ដងទៅហើយ។ គាត់បានដោះសំលៀកបំពាក់ខ្ញុំដោយមានបំណងចង់រំលោភខ្ញុំ។ ខ្ញុំចង់ចេញពីទីនោះណាស់។ នៅពេលដែលខ្ញុំមិនអាចគេចចេញពីទីនោះ ខ្ញុំធ្វើជាស្រេកទឹកហើយសុំទឹកផឹក គាត់តបមកវិញថា ខ្ញុំគួរតែផឹកទឹកនោមគាត់ទៅ។ ខ្ញុំក៏មានប្រតិកម្មដែរនៅពេលគាត់រំលោភខ្ញុំ។ ខ្ញុំទាត់គាត់វិញ តែក្រោយមកគាត់អូសខ្ញុំចុះឡើងៗ។ បន្តរបៀបនេះ រហូតក្បាលខ្ញុំទង្គិច និងកំភាលឥដ្ឋឡើងហូរឈាម។ ក្រោយមកខ្ញុំអស់កម្លាំងពេក ក៏តបតលែងរួច។" "នៅពេលខ្ញុំតដៃលែងបានគាត់ចាប់ផ្តើមដោះសម្លៀកបំពាក់ ខ្ញុំហើយដាក់ខ្ញុំអោយដេកនៅនឹងដី។ បន្ទាប់មកគាត់រំលោភខ្ញុំ ដោយអោយខ្ញុំដេកផ្កាប់ ហើយលើកទីពីរគាត់រំលោភខ្ញុំដោយអោយខ្ញុំដេកផ្ងា។ គាត់ខាំថ្ពាល់ ច្រមុះ ស្មាខ្ញុំទៀត។ ច្រមុះខ្ញុំលាត់ស្បែក ហើយភ្លៅខ្ញុំជង្គង់ ខ្នង ជើង និងថ្ងាសសុទ្ធតែត្រូវរបួស។ ខ្ញុំក៏មានហូរឈាមចេញពីទ្វារមាសខ្ញុំទៀតផង។ ឥឡូវខ្ញុំមានស្នាមលើច្រមុះ ថ្ងាស និងចង្កាមកដល់សព្វថ្ងៃ។ "

"គាត់បានហៅបុគ្គលិកថ្នាក់ក្រោម ហើយអោយពួកគេយកខ្ញុំទៅបោះចោលនៅតាមមាត់ផ្លូវ។ ដោយសារតែរងទារុណកម្ម និងកំហឹងផងធ្វើអោយខ្ញុំមិនអាចឈរបានឡើយ។ នៅពេលដែលខ្ញុំកំពុងនៅដេកលើដី មានទាហាន ២ទៅ ៣ អ្នកដែលមិនស្គាល់អត្តសញ្ញាណបានមករំលោភខ្ញុំបន្តទៀត។ ខ្ញុំគ្រាន់តែដឹងថាមានពួកទាហាន៣នាក់ បានរំលោភខ្ញុំតែបានសន្លប់ទៅវិញ។ "

"មួយរយៈពេលក្រោយមកខ្ញុំដឹងខ្លួនឡើង ហើយស្រាប់តែកងទាហានម្នាក់នៅសង្កាត់ ហ្គោរ៉ាខា បាននាំខ្ញុំចេញពីជំរំ។ គេបានទុកខ្ញុំចោលនៅហាងលោក ឌីប៉ាក់ សាស៊ី ដែលនៅជិតរបងជំរំទ័ពនោះ។ ខ្ញុំបានអង្គុយយំក្បែរមាត់ផ្លូវទាំងមិនទាន់ដឹងខ្លួនស្រួលបួលផង។ លោក ឌីប៉ាក់ សាស៊ី ក៏បានមកសួរខ្ញុំថាហេតុអ្វីបានយំ ខ្ញុំក៏បានរ៉ាយរាប់ប្រាប់គាត់នូវរឿងទាំងអស់បន្ទាប់មកគាត់ក៏បានហៅឡានពេទ្យពីសង្កាត់ ដៃលេកខ៏ និងបញ្ជូនខ្ញុំទៅមន្ទីរពេទ្យ។"

"ដោយសារការរំលោភសេពសន្ថវៈបានធ្វើអោយស្បូនខ្ញុំហើម និងមានឈាមកកទៀតផង។ ខ្ញុំក៏ត្រូវគេបញ្ជូនមកមន្ទីរពេទ្យនៅសង្កាត់ ហ្សឺខេត ដែលជាកន្លែងដែលខ្ញុំត្រូវសម្រាកព្យាបាលអស់ជាង៧ថ្ងៃ តែមិនទាន់ជាសះស្បើយទេ ខ្ញុំក៏ត្រូវគេបញ្ជូនបន្តទៅមន្ទីរពេទ្យនៅប្រទេសឥណ្ឌា។ តែខ្ញុំគ្មានប្រាក់គ្រប់គ្រាន់នឹងទៅទេនាពេលនោះ។"

នៅខែតុលា ឆ្នាំ២០០៥ អ្នកស្រី ហាម៉ាល ត្រូវលក់ដីដើម្បីចំណាយទៅលើការព្យាបាល និងការវះកាត់យកស្បូនចេញ។ នៅពេលការវះកាត់បញ្ចប់ទៅអ្នកស្រីបានចេញពីមន្ទីរពេទ្យភ្លាម ដោយសារតែខ្វះលទ្ធភាពដើម្បីបង់ការព្យាបាលបន្តទៀត។ "ខ្ញុំបានទៅការិយាល័យរដ្ឋបាលស្រុកនៃសង្កាត់ ដាយលេកខ៏ បន្ទាបប់ពីលឺដំណឹងមកថារដ្ឋាភិបាលបានផ្តល់សំណងចំពោះជនរងគ្រោះ ដែលត្រូវបានរងទារុណកម្មដោយរដ្ឋ។ ខ្ញុំបានឃើញការប្រមូលផ្តុំគ្នានៅទីនោះ ហើយខ្ញុំក៏បានចូលរួមដែរ។ លោក ជីវ៉េស ថាប៉ា (អនុសេនីត្រី) ក៏នៅទីនោះដែរ។ ខ្ញុំបានប្រាប់លោក ទីឡាក់ នូផេន ប្រធានការិយាល័យថា លោក ជីវ៉េស ថាប៉ា បានធ្វើទារុណកម្មខ្ញុំ ដោយមិនប្រាប់ពីមូលហេតុ។ គាត់តបមកវិញថា លោកអនុសេនីត្រីជាមនុស្សល្អទេ។ ប្រធានការិយាល័យសួរលោក ជីវ៉េស ថាប៉ា ថាហេតុអ្វីបានគាត់ធ្វើទារុណកម្មខ្ញុំ។ លោកអនុសេនីត្រីនេះមិនបានឆ្លើយអ្វីទាំងអស់។ ការិយាល័យរដ្ឋាបាលបានផ្តល់ប្រាក់អោយខ្ញុំ ៥០០០រ៉ូបពីសម្រាប់ជាហិរញ្ញវត្ថុឧបត្ថម្ភដំបូង។"

"ខ្ញុំមកនៅសង្កាត់ ដាយលេកខ៏ អស់រយៈពេល៣ខែ។ ប៉ុន្តែពួក Maoists ធ្លាប់បានមកផ្ទះខ្ញុំ ហើយចោទខ្ញុំថាខ្ញុំបានផ្តល់ពត៌មានដល់កងទ័ព និងចោទថា ខ្ញុំធ្លាប់ដាក់គ្រាប់បែកជិតផ្ទះរបស់ខ្ញុំ។ ខ្ញុំក៏បានផ្លាស់មកនៅសង្កាត់ ហ្សឺខេត ហើយរស់នៅទាំងលំបាកជាមួយកូនស្រីរបស់ខ្ញុំ។ ខ្ញុំត្រូវមកពិនិត្យសុខភាព រាល់២ខែម្តង ហើយឥលូវខ្ញុំខ្សោយកម្លាំងទៀតផង។ ខ្ញុំត្រូវធ្វើការងារដោយប្រើកម្លាំងដើម្បីចិញ្ចឹមជីវិត។

***អ្នកស្រី ហ្វូល ចានាតី រ៉ាណា*** *មានអាយុ ២៣ឆ្នាំ បានរស់នៅភូមិ គណៈកម្មការអភិវឌ្ឍ ដេខាតាប៉ូលី ផ្នែកលេខ៣ ក្នុងសង្កាត់ កាន់ចាន់ភ័រ។ អ្នកស្រីត្រូវបានគេរំលោភសេពសន្ថវៈនៅខែ មិថុនា ឆ្នាំ២០០៦ ដោយសកម្មជន Maoist ម្នាក់ឈ្មោះ រ៉ាម គ្រីស្នាណា រ៉ាណា នៃទីតាំងខាងលើ នៅម៉ោងប្រហែល ១១យប់។*

"ក្នុងអំឡុងព្រឹត្តិការណ៍នោះ ខ្ញុំមានអាយុ១៦ឆ្នាំ។ ពេលនោះខ្ញុំនៅផ្ទះអ្នកជិតខាងខ្ញុំម្នាក់ឈ្មោះ អនទូ រ៉ាណា ដើម្បីមើលទូរទស្សន៍ នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៦។ ជនល្មើស រ៉ាម គ្រីស្នាណា រ៉ាណា បានមកប្រាប់ខ្ញុំថាមិត្តភក្តិខ្ញុំម្នាក់បានហៅខ្ញុំទៅសួនមួយនៅក្បែរនោះ។ បន្ទាប់មកខ្ញុំក៏ដើរទៅទីនោះ។ ប្អូនតូចរបស់ខ្ញុំក៏មកតាមខ្ញុំដែរ។ ពេលនោះម៉ោងប្រហែល១០យប់។"

"បន្ទាប់មក ភ្លាមៗនោះស្រាប់តែ រ៉ាម គ្រីស្នាណា រ៉ាណា បានមកចាប់ដៃខ្ញុំទាំងពីរ ហើយបានអូសខ្ញុំចេញឆ្ងាយពីចំការ និងទាញខ្ញុំយកមកដល់វាលមួយដែលមានចម្ងាយ២០០ម៉ែត្រពីសួននោះ។ បន្ទាប់មកក៏ផ្តួលខ្ញុំទៅដី

ហើយក៏ចាប់ផ្តើមរំលោភខ្ញុំ។ គេបានគំរាមសម្លាប់ខ្ញុំ បើខ្ញុំមិនអោយគេរំលោភទេ។ ខ្ញុំព្យាយាមការពារខ្លួនដែរ តែមិនអាចទៅរួច។ អាវខៀវខ្ញុំរហែកអស់នៅពេលគេចាប់រំលោភខ្ញុំ។" "នៅពេលនោះ ដោយសារឃើញស្ថានភាពមិនល្អរបស់ខ្ញុំប្អូនខ្ញុំក៏ចាប់ផ្តើមយំ។ ឪពុកខ្ញុំបានលឺសម្លេងប្អូនខ្ញុំយំក៏រត់មកជាមួយដំបងធំមួយ។ ឪពុកខ្ញុំបានវាយគេជាមួយដំបងនោះ ពេលគេចង់គេចខ្លួន។ តែគេនៅតែគេច ខ្លួនរួចដដែល។"

## ប្រទេសទីម័រខាងកើត

***អ្នកស្រី អលហ្គា ដា ស៊ីលវ៉ា អាម៉ារ៉ាល*** *បានរៀបការ និងរស់នៅក្នុងតំបន់ ម៉ាអ៊ីហ្គា ជាមួយស្វាមី និងកូន៤នាក់។ ក្នុងអំឡុងសង្គ្រាមដណ្តើមឯករាជ្យ អ្នកស្រីបានជួបប្រទះការរំលោភផ្លូវភេទ ទារុណកម្មចំពោះខ្លួនអ្នកស្រីផ្ទាល់ និងអ្នកដទៃផងដែរ អ្នកស្រីក៏បានឃើញករណីឃាតកម្មជាច្រើនផងដែរ។*

នៅឆ្នាំ១៩៨១ អ្នកស្រីនិងប្តី និងប្រជាជនផ្សេងទៀតនៅក្នុងភូមិបានជួយពួក ហ្វាលីនទីល (FALINTIL) ដែលជាកងទ័ពរំដោះប្រទេសទីម័រ នៅក្នុងតំបន់ពួកគេ និងកងទ័ពឥណ្ឌូនេស៊ីដែលធ្លាប់បានគេស្គាល់ថាជា អាប្រ៊ី (ABRI) បានរកឃើញថា មួយណាដែលធ្វើអោយកាលៈទេសៈកាន់តែគ្រោះថ្នាក់ឡើងៗ។ នៅថ្ងៃទី១១ កក្កដា ឆ្នាំ១៩៨២ កងទ័ពអាប្រ៊ី និងកងការពារជនស៊ីវិលដែលគេស្គាល់ថាជា (ហានស៊ីប) បានចាប់ផ្តើមយុទ្ធនាការចាប់ប្រជាជនណាដែលចូលរួមកិច្ចប្រជុំរបស់ហ្វាលីនទីល ដែលមានទាំងប្តីអ្នកស្រីផងដែរ។ អ្នកស្រីត្រូវបានគេវាយដំ ហើយបញ្ជូនទៅតំបន់ ហាទូ ប៊ូលីកូ ជាង១សប្តាហ៍មុនអ្នកស្រីត្រូវនិរទេសទៅតំបន់ អាតួរ៉ូ ដែលជាកន្លែងដែលអ្នកស្រីត្រូវរងទុក្ខវេទនាជាង២ឆ្នាំ។

មិនយូរប៉ុន្មានបន្ទាប់ពីនោះ នៅថ្ងៃទី ២០ សីហា ១៩៨២ កងទ័ព អាប្រ៊ី បានចាប់ផ្តើមដុតផ្ទះអ្នកស្រុក ហើយក៏មានផ្ទះអ្នកស្រីដែរ។ អ្នកស្រីបានជួយសមាជិកម្នាក់មកពី ហ្វាលីនទីល ដែលមានវត្តមាននៅពេលវាយប្រហារដូចនេះ អ្នកស្រីត្រូវគេសង្ស័យ ហើយក៏ចាប់ខ្លួននិងបញ្ជូនទៅដារ៉េ។ ក្នុងអំឡុងពេលឃុំឃាំងអ្នកស្រី និងស្រ្តីផ្សេងទៀតត្រូវ គេធ្វើទារុណកម្មដោយពួក អាប្រ៊ី និងហានស៊ីប។

"មុនពេលត្រូវគេរំលោភសេពសន្ថវៈ ខ្ញុំត្រូវគេវាយនឹងកៅអីឈើរហូតហូរឈាម។ ខ្ញុំត្រូវគេវាយចំឆ្អឹងជំនីរដោយកាំភ្លើង និងទាត់ដោយស្បែកជើងទាហានរហូតខ្ញុំដើរលែងរួច។ តែគេនៅតែបន្តដដែល ខ្ញុំត្រូវគេឆក់ខ្សែភ្លើងត្រង់ត្រចៀក ដៃ និងជើង។ ខ្ញុំត្រូវគេអោយលោតចុះលោតឡើងរហូតខ្ញុំមានអារម្មណ៍ថា ខ្សោះឈាម និងគ្មានកម្លាំងក្នុងខ្លួនទៀតទេ។ បន្ទាប់មកពួកគេចាប់ផ្តើមរំលោភខ្ញុំ។ បន្ទាប់មកពួកគេក៏អុចខ្ញុំជាមួយកន្ទុយបារីនៅលើមុខ និងដៃ។ ការរំលោភសេពសន្ថវៈ និងទារុណកម្មនេះបន្តអស់រយៈពេលជាង១ខែ។ នាពេលនោះដែរ ខ្ញុំត្រូវគេប្រើដូចទាសករដោយខ្ញុំត្រូវធ្វើការដូចជាបោកខោអាវ និងដាំស្លអោយពួកគេជាដើម។

អំឡុងពេលនោះ អ្នកស្រី អាម៉ារ៉ាល និងស្រ្តីដទៃទៀតត្រូវគេឃុំទុកនៅសាលាមួយគ្រប់គ្រងដោយពួក អាប្រ៊ី ។ ជារៀងរាល់ថ្ងៃអ្នកស្រីត្រូវបានសួរចម្លើយ អំពីព័ត៌មានដែលប្រឌិតឡើង ដោយជនជាតិទីម័រខាងកើតហានស៊ីបម្នាក់។

ប្រសិនបើអ្នកស្រីនិយាយអ្វីដែលមិនទំនងនឹងរឿងនោះទេ អ្នកស្រីប្រាកដជាត្រូវគេធ្វើទារុណកម្ម និងរំលោភទៀតមិនខាន។ សូម្បីតែស្ត្រីមានផ្ទៃពោះ និងម្តាយមានកូនតូចក៏ត្រូវគេរំលោភដែរ។ កូនរបស់ស្ត្រីទាំងនេះយំយ៉ាងខ្លាំងប៉ុន្តែពួកអាប្រីមិនខ្វល់ឡើយ។

ចុងក្រោយ អ្នកស្រីបានភៀសខ្លួន និងបានគេចទៅសាលាវិញ ដើម្បីជៀសពីគ្រោះថ្នាក់។ ប៉ុន្តែវាមិនបានរយៈពេលយូរឡើយ។ មានព័ត៌មានបន្តំមួយត្រូវបានគេរាយការណ៍មកថា អ្នកស្រីបានទាក់ទងជាមួយទាហាន ហ្វាលីនទីល ហើយអ្នកស្រីក៏ត្រូវគេចាប់ខ្លួនម្តងទៀតនៅខែ កញ្ញា ១៩៨២ ហើយនាំខ្លួនទៅកាន់ កូឌីម៉ុន អាយណារ៉ូ។

"នៅពេលមកដល់ខ្ញុំត្រូវចាំប្រធានផ្នែកស៊ើបការពារ រហូតដល់ម៉ោង២រសៀល។ គាត់បានសួរកូនចៅគាត់ថា "ណឹង ហើយឬនាង អ៊ុលហ្គានោះ? អីឡូវចាំសិនទៅយើងទៅងូតទឹកសិន។ " បន្ទាប់មក ខ្ញុំត្រូវបានគេហៅទៅមិនមែនបន្ទប់សួរចម្លើយទេ តែជាបន្ទប់ដេកគាត់ដើម្បីរួមដំណេក។ ភ្នាក់ងារស៊ើបការពារផ្សេងទៀតបានមកសួរចម្លើយខ្ញុំជាមួយពាក្យចោទប្រកាន់ដោយគ្មានភស្តុតាងជាច្រើន ដូចជា "តើអ្នកឯងធ្លាប់ជួយផ្តល់ស្បៀងដល់ទាហាន ហ្វាលីនទីលទេ? តើផ្ទះអ្នកឯងជាកន្លែងជួបប្រជុំរបស់ទាហាន ហ្វាលីនទីលមែនទេ?" ប៉ុន្តែខ្ញុំនៅតែប្រកែកហើយពួកគេនៅតែបន្តធ្វើទារុណកម្មខ្ញុំ។"

ចុងបញ្ចប់ អ្នកស្រី អាម៉ារ៉ាល ត្រូវបានដោះលែងហើយត្រលប់ទៅដារ៉េ វិញ។ មិនយូរប៉ុន្មាន ប្តីអ្នកស្រីក៏ត្រូវបានដោះលែងពីជំរំ អាតង់តូរ៉ូ ហើយគ្រួសារអ្នកស្រីទាំងពីរក៏បានជួបជុំ និងពិភាក្សាអំពីបញ្ហាទាំងឡាយដែលអ្នកស្រី អាម៉ារ៉ាល បានជួបប្រទះនៅពេលអ្នកស្រីនៅក្នុងកណ្តាប់ដៃកងទ័ពឥណ្ឌូនេស៊ី។ អ្នកស្រីទាំងពីរនាក់ប្តីប្រពន្ធបានទទួលការប្រឹក្សាពីអាចារ្យម្នាក់ ហើយអ្នកស្រីបានរៀបរាប់ប្រាប់រឿងគ្រប់យ៉ាងទៅប្តីអ្នកស្រី ដោយសាររឿងទាំងអស់នេះបានកើតឡើងខុសនឹងឆន្ទៈរបស់អ្នកស្រី។ អាចារ្យនោះបានសួរទៅប្តីអ្នកស្រីថា តើគាត់ព្រមទទួលអ្នកស្រីជាភរិយាវិញដែរឬទេ? គាត់ក៏បានឆ្លើយថាព្រម។

"ពួកយើងពិតជាចង់មានកូនខ្លាំងណាស់ ខ្ញុំបានព្យាយាមជាង១០ឆ្នាំហើយមុននឹងខ្ញុំទៅអោយពេទ្យពិនិត្យ។ គ្រូពេទ្យនិយាយថា ខ្ញុំប្រហែលជាមិនអាចមានកូនឡើយ ដោយសារតែការរងទារុណកម្ម និងអំពើរំលោភដែលប៉ះពាល់ដល់សរីរាង្គបន្តពូជ។ ខ្ញុំបានទៅរកគ្រូពេទ្យបុរាណដើម្បីម៉ាស្សា និងផឹកថ្នាំបុរាណ។ ជាសំណាងល្អ ខ្ញុំក៏មានគភ៌មែនតែការឆ្លងទន្លេពិតជាឈឺចាប់ខ្លាំងណាស់។ ខ្ញុំឆ្លងទន្លេបានកូន៤នាក់ទាំងអស់ តែកូនចុងក្រោយរបស់ខ្ញុំសឹងធ្វើអោយខ្ញុំស្លាប់ទៅហើយ។"

***អ្នកស្រី ម៉ារីយ៉ា ឞាឌីម៉ា*** *គឺជាស្ត្រីមេម៉ាយដែលមានមុខរបរលក់នំ។ រំលឹកពីបទពិសោធន៍*

"ទាហានឥណ្ឌូនេស៊ីតែងតែមកចាប់ខ្ញុំយកទៅ ហ្គូមេបូយាន សម្រាប់ធ្វើការសាកសួរ។ ខ្ញុំបានប្រាប់គេថា ខ្ញុំអត់ដឹងរឿងអ្វីទាំងអស់ ពួកយើងគ្រាន់តែដឹងថាមានកងទ័ពនៅក្នុងព្រៃ តែខ្ញុំមិនដឹងថាពួកគេបានសម្លាប់មនុស្ស ឬអត់ទេ។ ទាហានទាំងនេះ ក៏ចាប់ផ្តើមវាយ និងទាត់ខ្ញុំ និងប្រពន្ធរបស់មូអាប្រេនតាមអំពើចិត្ត។ បន្ទាប់មកពួកគេក៏ចាប់ផ្តើមដោះសម្លៀកបំពាក់ពួកខ្ញុំ នៅពេលដែលពួកគេមកប្រយុទ្ធពីព្រៃវិញ ពួកយើងត្រូវបានបង្ខំអោយរួមភេទជាមួយពួកគេ។ កូនស្រីខ្ញុំដែលនៅជាមួយទាហានបានកើតនៅឆ្នាំ ១៩៩៧ ហើយដោយសារនាងខ្ញុំបានទទួលប្រាក់ឧបត្ថម្ភ

ក្នុងនាមជាម្តាយ។ "

"ពេលខ្លះនៅ ហ្លមេបូយាន ជនជាតិទីម័រដែលបាននាំខ្លួនយើងមកពីផ្ទះបានដាក់ពួកយើងក្នុងបន្ទប់ទឹក។ ពួកគេបានបង្ខំពួកយើងអោយរួមដំណេក ហើយបន្ទាប់ពីនោះគឺពួកទាហានឥណ្ឌូនេស៊ីម្តង ពួកទីម័រទាំងនេះបានបិទមុខខ្លួនឯងជាមួយប្លាស្ទិកដើម្បីកុំអោយយើងស្គាល់ តែខ្ញុំដឹងថាពួកនេះ ជាជនជាតិទីម័រ ដូចជារដ្ឋបាល អាប្រាអូ និង មីហ្គូអេល។ ពួកគេបានស្លាប់អស់ហើយ។" ចុងក្រោយអ្នកស្រី ហ្វាទីម៉ា ត្រូវបានដោះលែង។

"ពេលខ្ញុំទៅរកកងទាហានប៉ូលីសវិញ ខ្ញុំបានសរសេរលិខិតមួយប្តឹងពីលោក ដានឌីម។ គេក៏បានដកលោក ដានឌីម ភ្លាមៗផងដែរ។ ទាហានទាំងនេះនៅតែចោទខ្ញុំថាខ្ញុំជាពួក ហ្វ្រេតទីលីន (ទាហានបដិវត្តន៍ដើម្បីឯករាជ្យ ទីម័រខាងកើត) ហើយចោទខ្ញុំទៀតថា បានយកស្បៀងអោយពួក ហ្វ្រេតទីលីន នៅក្នុងព្រៃ។ ខ្ញុំបានប្រាប់ពួកគេថា មែនហើយខ្ញុំជាពួក ហ្វ្រេតទីលីន ហើយពួកគេក៏វាយខ្ញុំ និងបានយកខ្ញុំធ្វើជា "ប្រពន្ធ" ពួកគេរំលោភខ្ញុំ ហើយធ្វើអោយខ្ញុំមានកូន៤នាក់ ដោយម្នាក់ៗមានឪពុកផ្សេងៗគ្នាទៀតផង។ "

.....................................................

# ឧបសម្ព័ន្ធ គ សេចក្តីថ្លែងការណ៍របស់គណៈវិនិច្ឆ័យ

## ការណែនាំ

ការស្តាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាយេនឌ័រពេលមានជម្លោះបានប្រារព្ធឡើងនៅមជ្ឈមណ្ឌលគូម៉េនាល ឌីអាកូនា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា នៅថ្ងៃទី១០-១១ ខែតុលា ឆ្នាំ ២០១២។ កម្មវិធីត្រូវបានរៀបចំឡើងដោយក្រុមអ្នកច្បាប់ការពារសិទ្ធកម្ពុជា អង្គការអន្តរវប្បធម៌ចិត្តសង្គម និងអង្គភាពគាំទ្រជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ កម្មវិធីនេះបានផ្សព្វផ្សាយជាសាធារណៈ និងបានចូលរួមដោយតំណាងរាជរដ្ឋាភិបាលកម្ពុជា តំណាងអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលទាំងក្នុងស្រុក និងអន្តរជាតិ និងសិស្ស និស្សិតជាច្រើន។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានផ្តល់អោយស្ត្រីដែលជាជនរងគ្រោះ និងសាក្សីនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងពេលមានជម្លោះនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជាមួយនឹងការពិភាក្សា ដើម្បីបំបែកភាពស្ងៀមស្ងាត់ ជុំវិញការបំពានប្រឆាំងនឹងស្ត្រីក្នុងផលប៉ះពាល់ពេលមានជម្លោះ និងដើម្បីទាមទារយុត្តិធម៌។ កម្មវីធីស្តាប់នេះ ចូលរួមដោយគណៈវិនិច្ឆ័យជំនាញ ដើម្បីស្តាប់សក្ខីកម្មរបស់ជនរងគ្រោះ និងអ្នកជំនាញផ្តល់សក្ខីកម្មផ្សេងទៀត ដោយថែមទាំងកំណត់ជាលទ្ធផលនិងផ្តល់ជាអនុសាសន៍ផងដែរ។ ក្នុងកិច្ចពិភាក្សានេះ មានអ្នកជំនាញ ដូចជា អ្នកស្រី លី វិច្ឆិតា (អ្នកការពារសិទ្ធមនុស្សមកពីប្រទេសកម្ពុជា) វ៉ាហ៊ីដា ណៃណា (អ្នកជំនាញយេនឌ័រ និងសិទ្ធិមនុស្សមកពីប្រទេសឥណ្ឌា) ឌីអាណេ អតតូ (សាស្ត្រាចារ្យច្បាប់ មកពីប្រទេសអូស្ត្រាលី) និង អ៊្សូរ៉ា ចាវ៉ាត ដេ ឌីអូស (អ្នកតំណាងហ្វីលីពិនរបស់គណៈកម្មការអាស៊ានលើការជម្រុញ និងការពារសិទ្ធិស្ត្រី និងកុមារ ACWC)។

គណៈវិនិច្ឆ័យ បានស្តាប់ពីសក្ខីកម្មពីស្ត្រីជនរងគ្រោះ និងសាក្សីហិង្សាផ្លូវភេទ ដែលកើតឡើងក្នុងអំឡុងមានជម្លោះ៤ នៅក្នុងតំបន់ៈ កម្ពុជា (១៩៧៥ ដល់ ១៩៧៩) បង់ក្លាដេស្ស (១៩៧១) នេប៉ាល់ (១៩៩៦ ដល់ ២០០៦) និងទីម័រ (១៩៧៤ ដល់ ១៩៩៩)។ សក្ខីកម្មទាំងនេះ បានអមទៅដោយសាររីដេអូមួយរបស់លោកស្រី ដែលជាអ្នកតំណាងពិសេស អគ្គលេខាធិការអង្គការសហប្រជាជាតិ លើករណីហិង្សាយេនឌ័រពេលមានជម្លោះ។ គណៈវិនិច្ឆ័យក៏បានស្តាប់សក្ខីកម្មពីអ្នកជំនាញអន្តរជាតិ ដោយរាប់បញ្ចូលទាំងការពិពណ៌នាទូទៅនៃដើមហេតុ និងទម្រង់ហិង្សាយេនឌ័រក្នុងជម្លោះប្រដាប់អាវុធដោយលោកស្រី ស៊ីលគី ស្វូឌហ្ស៊ីនស្គី (អ្នកប្រឹក្សាអន្តរជាតិចំពោះដើមបណ្តឹងរដ្ឋប្ប-វេណីនៅអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា) និងបទបង្ហាញអំពីការអនុវត្តដ៏ល្អបំផុត និងបញ្ហាទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ ចំពោះយុត្តិធម៌យេនឌ័រដោយសាស្ត្រាចារ្យ ស៊ូសាណា សាគូតូ (នាយក ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម សាកលវិទ្យាល័យច្បាប់សហរដ្ឋអាមេរិក ទីក្រុង វ៉ាស៊ីនតោន)។ ភ្ញៀវកិត្តិយស អេនី ម៉ារី ហ្គោអេស៍ (ប្រធានប្រឹក្សាការគ្រប់គ្រង សន្តិភាព និងសន្តិសុខស្ត្រីនៃអង្គការសហប្រជាជាតិ) បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់របស់សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលើស្ត្រី សន្តិភាព និងសន្តិសុខដែលបានចែងនៅក្នុងសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ១៣២៥, ១៨២០, ១៨៨៨, ១៨៨៩, ១៩៦០ ដែលជាផ្នែកនៃគម្រោងអន្តរជាតិមួយ ក្នុងការបញ្ចប់និទណ្ឌភាព ហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះ និងដើម្បី

សម្រេចអោយបាន ការពង្រឹងសិទ្ធិអំណាចស្ត្រីជាសកល។ កម្មវិធីនេះក៏ត្រូវបានបើកនូវការស្វាគមន៍ដោយលោកជំទាវ ហោ ម៉ាលីន (អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី នៃរាជរដ្ឋាភិបាលកម្ពុជា) និងបានបិទទៅវិញ ដោយអនុសាសន៍របស់ឯកឧត្តម អោម យិនទៀង (ប្រធានគណៈកម្មការអន្តរក្រសួងអាស៊ានលើសិទ្ធិមនុស្សនៅកម្ពុជា)។

កម្មវិធីស្តាប់សម្លេងស្ត្រីនេះ ក៏បានឮនូវសារនៃសាមគ្គីភាពពីអ្នករៀបចំកម្មវិធីស្ត្រីនៃការជំនុំជម្រះរបស់ប្រទេសហ្គោតាមេឡាដោយមនសិការ អ្នកស្រី ម៉ូនីកា ភីណាហ្សូន (អ្នកជំនាញចិត្តសាស្ត្រសង្គម សិក្សាសហគមន៍ និងសកម្មភាពចិត្តសាស្ត្រ (ECAP), ហ្គោតាម៉ាឡា)។ ហ្គោតាមេឡា "សម្ព័ន្ធមិត្តស្ត្រីដើម្បីទម្លាយភាពស្ងៀមស្ងាត់" មានរាប់បញ្ចូលដូចជា អ្នកជំនាញចិត្តសាស្ត្រសង្គម សិក្សាសហគមន៍ និងសកម្មភាពចិត្តសាស្ត្រ សម្ព័ន្ធភាពជាតិនៃស្ត្រីហ្គោតាមេឡា (UNAMG) និងស្ត្រីដើម្បីការផ្លាស់ប្តូរពិភពលោក (MTM)។ អ្នកស្រី ភីណាហ្សូន ក៏បាននិយាយពីការខិតខំប្រឹងប្រែងរបស់ស្ត្រីដែលរស់រានមានជីវិតក្នុងការរកយុត្តិធម៌។ គណៈវិនិច្ឆ័យ ដោយតាងនាមអោយជនរងគ្រោះ និងអ្នកមានជីវិតដែលមកពីប្រទេសកម្ពុជា បង់ក្លាដេស្ស នេប៉ាល់ និងទីម័រ អ្នករៀបចំកម្មវិធីសម្លេងស្ត្រី និងអ្នកចូលរួមទាំងអស់សូមពង្រីកនូវសាមគ្គីភាពចំពោះជនរងគ្រោះ ហ្គោតាម៉ាឡា និងគាំទ្រពួកគេក្នុងដំណើរស្វែងរកយុត្តិធម៌។

## លទ្ធផល

មុននឹងបង្ហាញពីលទ្ធផល និងមតិយោបល់គណៈវិនិច្ឆ័យបានផ្តល់នូវការគាំទ្រចំពោះសេចក្តីក្លាហានយ៉ាងធំធេងរបស់ជនរងគ្រោះ និងសាក្សីដែលបានបោះជំហានទៅមុខប្រឡូក និងយកឈ្នះ និងគាស់កកាយនូវស្លាកស្នាមទុយ៌ស ដែលភាគច្រើនទាក់ទងនឹងភាពជាជនរងគ្រោះចំពោះហិង្សាផ្លូវភេទ។ ដើម្បីជាជំនួយក្នុងការបំបែកភាពស្ងៀមស្ងាត់ជុំវិញរឿងដ៏យូរទាំងនោះ សក្ខីកម្មទាំងនេះ ជាវិភាគទានក្នុងការផ្តល់ការយល់ដឹងពីតថភាពទូទៅរបស់ហិង្សាយេនឌ័រពេលមានជម្លោះ និងការបន្តនូវឥទ្ធិពលអវិជ្ជមានមកលើជនរងគ្រោះ និងកូនរបស់ពួកគេជាច្រើនខែឆ្នាំមកហើយបន្ទាប់ពីការបញ្ចប់សង្គ្រាម។ សក្ខីកម្មទាំងនេះ ក៏បានឆ្លុះបញ្ចាំងអោយឃើញពីភាពអយុត្តិធម៌ដ៏គួរអោយស្អប់ខ្ពើមនៃនិទណ្ឌភាពរបស់ជនល្មើសដែលតែងតែកើតមាន។ គណៈវិនិច្ឆ័យបានសង្កត់ធ្ងន់ផងដែរថា ភាពអាម៉ាស និងការស្តីបន្ទោសត្រូវតែត្រូវបានដកចេញអោយឆ្ងាយពីជនរងគ្រោះ ហើយបង្វែទៅលើជនល្មើស រដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ ដែលមានកាតព្វកិច្ចបញ្ចប់និទណ្ឌភាព ហើយបង្កើតភាពប្រាកដប្រជាអំពីការទទួលបានរបស់ស្ត្រីនូវសិទ្ធិមនុស្សយ៉ាងពេញលេញក្នុងអំឡុងពេលមានជម្លោះ និងសន្តិភាពផងដែរ។

### ក. កត្តាជំរុញចំពោះហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ

១. ការយល់ដឹងដ៏ទូលំទូលាយ នៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធនៅមុនពេល អំឡុងពេល និងក្រោយពីជម្លោះប្រដាប់អាវុធ និងដាក់ជុំវិញស្ថានការណ៍ ការតស៊ូក្នុងនយោបាយ និងព្រឹត្តិការណ៍រីករវជ្សេងៗ ពិតជាមានសារៈសំខាន់ក្នុងការបំបាត់យ៉ាងមានប្រសិទ្ធិភាពនូវហិង្សាប្រភេទនេះដែលអាចបង្កការប៉ះពាល់ដល់សន្តិសុខ និងស្ថេរភាពអន្តរជាតិ។

២. ទម្រង់ និងមូលហេតុនៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធមានភាពស្រដៀងគ្នានៅគ្រប់ប្រទេសទាំងអស់ ដែលមាននៅក្នុងកម្មវិធីស្តាប់សម្លេងស្ត្រីនេះ បើទោះបីជាលក្ខណៈនៃជម្លោះរបស់ប្រទេសនីមួយៗ មានភាពពិសេសរៀងៗខ្លួនក៏ដោយ។ មូលហេតុចម្បងធំនោះគឺប្រវត្តិនៃវិសមភាពសិទ្ធិអំណាចរវាងបុរស និងស្ត្រីដែលជាហេតុនាំទៅកាន់ការត្រួតត្រាគ្រប់គ្រង និងរើសអើងចំពោះស្ត្រីពីសំណាក់បុរស។

៣. ហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ និងក្រោយជម្លោះ ធ្វើអោយបាត់បង់ឱកាសអភិវឌ្ឍន៍សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ជនរងគ្រោះ និងរារាំងស្ត្រី ក្នុងការអនុវត្តន៍សិទ្ធិមនុស្សរបស់គេយ៉ាងពេញលេញចំពោះការចូលរួមសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងភាពជាប្រជាពលរដ្ឋ។

៤. ទោះបីការរំលោភសេពសន្ថវៈជាប្រភេទនៃហិង្សាមួយដែលបានប្រើយ៉ាងទូលំទូលាយប្រឆាំងនឹងស្ត្រី និងក្មេងស្រីក្នុងអំឡុងជម្លោះប្រដាប់អាវុធវានៅតែជាឧក្រិដ្ឋកម្មអន្តរជាតិដែលទម្ងន់ទោសត្រូវបានថ្កោលទោសនៅមានកម្រិតនៅឡើយ។ វប្បធម៌ និងទម្លាប់ជាសកល ក្នុងការមិននិយាយស្តី និងស្លាកស្នាមទុយ៌សជុំវិញហិង្សាផ្លូវភេទត្រូវបានបន្ទោសទៅលើជនរងគ្រោះ និងនិទណ្ឌភាពចំពោះជនល្មើស។



៥. នៅពេលដែលហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ ត្រូវបានប្រព្រឹត្តិលើបុរស ហិង្សាផ្លូវភេទ និងយេនឌ័រដែលមានភាគតិចនេះ មិនត្រូវបានលើកយកមកពិភាក្សាក្នុងការកម្មវិធីនេះឡើយ។ វាត្រូវបានទទួលស្គាល់ថា ពិតជាកើតឡើងមែន ហើយទាំងនេះមិនត្រូវបានរាយការណ៍ និងពិនិត្យពិច័យឡើយ ដែលអាចជាហេតុនាំអោយមានបញ្ហាក្នុងសង្គម និងជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងផ្សេងទៀតទៅលើដំណើរជីវិតផងដែរ។

## ខ. អំពើទម្រង់នៃហិង្សា

៦. គ្រប់ភាគីទាំងអស់នៃជម្លោះ អាចមានចំណែកទាក់ទងគ្នាទៅនឹងហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ ដូចដែលបានឃើញច្បាស់ពីសក្ខីកម្មដែលបានមកពីប្រទេស នេប៉ាល់ និងទីម័រខាងកើត ហើយរដ្ឋអំណាច ត្រូវបានបង្ហាញអោយឃើញថា ជាអ្នកប្រព្រឹត្តិនូវអំពើហិង្សាទាំងនេះ បើទោះបីជាមានកាតព្វកិច្ចថ្នាក់ជាតិ អន្តរជាតិ និងច្បាប់ដើម្បីការពារ និងលើកតម្កើងសិទ្ធិស្ត្រីក៏ដោយ។

៧. ស្ត្រីទាំងឡាយដែលបានផ្តល់ជាសក្ខីកម្មដល់កម្មវិធីនេះ ត្រូវបានរាយការណ៍ថា កំពុងទទួលរងការឈឺចាប់នៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ។ ដូចដែលបានរៀបរាប់មកហើយនោះអំពើបំពានទាំងនេះ កើតឡើងនៅក្នុងបរិបទនៃអំពើឃោរឃៅផ្សេងៗទៀត ដែលនាំទៅរកការប្រឆាំងនឹងជនស៊ីវិល ដែលមានដូចជា ឃាតកម្ម ឃុំខ្លួនដោយខុសច្បាប់ ទារុណកម្មឆក់ខ្សែភ្លើង ការធ្វើអោយបាត់ខ្លួន ការបង្ខំអោយធ្វើការ និងជម្លៀសដោយបង្ខំ ការចាប់ខ្លួនតាមទំនើងចិត្ត ភាពអត់ឃ្លាន និង

ការកាប់សម្លាប់។ ដូចដែលអ្នករស់រានមានជីវិតដែលបានផ្តល់សក្ខីកម្ម ជាកម្មវត្ថុនៃឧក្រិដ្ឋកម្មទាំងនេះ កន្លងមក និងបទពិសោធន៍របស់ពួកគេក្នុងពេលមានជម្លោះ។

៨. ស្ត្រីដែលរស់រានមានជីវិត ដែលមកពីប្រទេស កម្ពុជា បង់ក្លាដេស្ស នេប៉ាល់ និងទីម័រខាងកើត បានរៀបរាប់ថា ពួកគេត្រូវបានរង ឬបានឃើញទម្រង់អំពើឃោរឃៅនៃហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធនេះដែលរួមមាន៖

ក. អំពើរំលោភសេពសន្ថវៈដូចជា ការរំលោភកុមារ រំលោភបូក រំលោភជាពួក រំលោភច្រើនដង រំលោភដោយប្រើវត្ថុផ្សេងៗ រំលោភស្ត្រីមានផ្ទៃពោះ ស្ត្រីដែលត្រូវមើលក្មេង រំលោភមុនសម្លាប់ និងការធ្វើទារុណកម្មផ្លូវភេទ។

ខ. ការពង្រត់ និងដាក់ជាទាសករផ្លូវភេទ

គ. ការឃុំខ្លួនដោយខុសច្បាប់ រួមទាំងក្នុងអំឡុងពេលមានគភ៌ និងពេលសម្រាលកូន

ឃ. ការបង្ខំអោយដោះខោអាវ ដូចជានៅកន្លែងសាធារណៈជាដើម

ង. ការប្រើប្រាស់ភាសាយេនឌ័រមិនសមរម្យ ដោយការយាយី និងរំលោភបំពាន

ច. ទាសករតាមផ្ទះ

ឆ. ការបង្ខំអោយធ្វើការក្នុងអំឡុងពពោះ និងធ្វើការភ្លាមបន្ទាប់ពីសម្រាលហើយ

ជ. ការរៀបការដោយបង្ខំដែលមានទាំង "អាពាហ៍ពិពាហ៍ដើម្បីបានរស់"

ឈ. ការមានផ្ទៃពោះដោយបង្ខំដែលបណ្តាលមកពីការរំលោភសេពសន្ថវៈ ការរៀបការដោយបង្ខំ និងពេស្យាកម្មដោយបង្ខំ

ញ. ទារុណកម្មផ្លូវភេទ ដែលមានទាំងការរួមភេទតាមមាត់ និងរន្ធគូទ ការកាត់អវៈយវៈភេទ របួសអវៈយវៈបន្តពូជដែលមិនអាចព្យាបាលបាន និងការបំពានសុខភាពសិទ្ធិបន្តពូជផ្សេងៗទៀត។

ដ. ការបំបែកបំបាក់គ្រួសារ

ឋ. ការបង្ខំអោយមើលស្ត្រីក្មេងៗ មិត្តភក្តិ និងសមាជិកគ្រួសារដ៏ទៃទៀត ទទួលរងដោយហិង្សាផ្លូវភេទ និងយេនឌ័រក្នុងពេលមានជម្លោះប្រដាប់អាវុធ។

៩. ជនរងគ្រោះជាច្រើនត្រូវបានកំណត់ជាគោលដៅនៃហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះដោយសារពួកគេជាស្ត្រី និងកុមារ។ ជនរងគ្រោះក៏ជាមុខសញ្ញា ដោយសារតែការជាប់ទាក់ទងដោយផ្ទាល់របស់ពួកគេនៅក្នុងពេលជម្លោះ ដោយធ្វើជាអ្នកប្រយុទ្ធ ឬក៏ដោយសារពួកគេទាក់ទង ឬបានជួយក្រុមផ្សេងទៀតនៅក្នុងជម្លោះ ឬក៏ដោយសារពួកគេត្រូវបានគេគិតថាជា"សត្រូវ"។

១០. ស្ត្រីដែលបានផ្តល់ជាសក្ខីកម្មដល់កម្មវិធីនេះ ដែលជាពិសេសមកពីប្រទេសកម្ពុជា និងបង់ក្លាដេស្សក៏បាននិយាយដែរអំពីភាពជាមិត្ត និងការអាណិតអាសូរ អំពីហិង្សាដែលបានកើតលើស្ត្រីមកពីបណ្តាប្រទេសដែលមានជនជាតិភាគតិច ឬក្រុមសាសនាផ្សេង ឬជាអ្នកដែលត្រូវឧក្រិដ្ឋជនបានគិតថាជា "អ្នក

ដ៏ទៃ"។ គណៈវិនិច្ឆ័យក៏បានធ្វើការសន្និដ្ឋានថា ស្ត្រីដែលមកពីសហគមន៍ជនជាតិភាគតិចនានា ជាពិសេស អ្នកដែលងាយរងគ្រោះដោយហិង្សាផ្លូវភេទអំឡុងពេលជម្លោះ ដែលមានសាមគ្គីភាពរវាងស្ត្រីមកពីសហគមន៍ទាំងអស់មានភាពចាំបាច់ជាខ្លាំងក្នុងកាលៈទេសៈនេះ។

១១. ឧទាហរណ៍ជាច្រើននេះ វាច្បាស់ណាស់ថា ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ គឺជាផ្នែកមួយដ៏ធំ ដែលមានទិសដៅមិនត្រឹមតែបំផ្លាញសេចក្តីថ្លៃថ្នូររបស់ស្ត្រី និងកុមារដែលពាក់ព័ន្ធដោយផ្ទាល់នោះទេ ថែមទាំងភ្ជាប់ជាមួយ "កិត្តិយស" របស់សហគមន៍ទាំងមូលទៀតផង។

## គ. ការប៉ះទង្គិចលើជនរងគ្រោះ គ្រួសារ និងសហគមន៍

១២. អ្នករស់រានមានជីវិតនិងសាក្សី នៃហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះបានរងនូវការឈឺចាប់ផ្លូវចិត្ត រយៈពេលយូរ ព្រមទាំងគម្លាតសង្គមដែលមានផលប៉ះពាល់យ៉ាងខ្លាំងលើស្មារតី ផ្លូវចិត្ត សេដ្ឋកិច្ច សង្គម និងសុខភាពរាងកាយទៀតផង ដែលមានដូចជាៈ

ក. ការបន្តនៃអារម្មណ៍អាម៉ាស់ ភាពមានកំហុស ភាពភ័យខ្លាច និងគម្លាតសង្គម និងវប្បធម៌ ភាពគ្មានមធ្យោបាយ និងភាពអស់សង្ឃឹម ដែលមានដូចជា ការប៉ងធ្វើអត្តឃាត ធ្វើអត្តឃាត និងរោគសញ្ញានៃរោគសញ្ញាការប៉ះទង្គិចផ្លូវចិត្ត (PSTD)

ខ. ការមិនអាចបង្កកំណើតបាន និងការរងរបួសសរីរាង្គបន្តពូជ ដែលបណ្តាលមកពីហិង្សាផ្លូវភេទ និងការរំលូតកូនដោយគ្មានសុវត្ថិភាព។

គ. ស្លាកស្នាមទុយ៌សនៃសង្គម នៃខ្លួនឯង និងគ្រួសារ ព្រមទាំងកូនដែលកើតមកពីការរំលោភសេពសន្ថវៈ

ឃ. ការបំបោះបង់ពីគ្រួសារ ការលែងលះ ភាពបាត់បង់ការគាំទ្រពីអ្នកនៅជុំវិញខ្លួន និងកាតព្វកិច្ចហួសសមត្ថភាព។

ង. ការបាត់បង់ទ្រព្យសម្បត្តិ និងកម្មសិទ្ធិដីធ្លី ភាពគ្មានជម្រក ការបន្តផ្លាស់ទីជម្រកញឹកញាប់ ភាពទាល់ក្រ កង្វះតំហែទាំសុខភាព និងការកើនឡើងនៃភាពងាយរងគ្រោះ ពីអំពើរំលោភផ្លូវភេទផ្ទួនៗ និងអំពើបំពានយេនឌ័រ។

ច. ការប៉ះពាល់ដល់ "ផែនការជីវិត" បង្អាក់ និងបំបាត់ឱកាសក្នុងជីវិត ដែលមានដូចជា កង្វល់ពីការសិក្សា ជីវភាពរស់នៅនិងការចូលរួមសកម្មភាពសេដ្ឋកិច្ច អាពាហ៍ពិពាហ៍ និងការចញ្ចឹមកូន។

ឆ. ការបន្តបំពានដោយឧក្រិដ្ឋជន បន្ទាប់ពីជម្លោះនៅក្នុងស្ថានភាពនៃនិទណ្ឌភាព និងភាពចុះខ្សោយនៃនិតិរដ្ឋសម្រាប់ជនរងគ្រោះ។

ជ. កំណើនឡើងនៃភាពងាយរងគ្រោះ ដោយការបង្ខំពេស្យាកម្ម និងការជួញដូរមនុស្ស។

១៣. ទោះបីជាមានបញ្ហាកើតឡើងជាបន្តបន្ទាប់ក៏ដោយ ក៏អ្នកនៅមានជីវិត និងសាក្សីនៃហិង្សាផ្លូវភេទ និងយេនឌ័រ កំពុងមានជម្លោះទាំងនេះ បានបញ្ចេញនូវភាពក្លាហាន និងរឹងមាំ មោះមុតដោយសមត្ថភាព

ពួកគេផ្ទាល់ក្នុងការបន្តជីវិត ដើម្បីបកស្រាយប្រឆាំងនឹងនិទណ្ឌភាពដែលជារឿយៗអាចមានភាពប្រថុយប្រថាន និងដើម្បីទប់ទល់ទៅនឹងឥទ្ធិពលអវិជ្ជមានជាច្រើន ដោយបទពិសោធន៍ពួកគេផ្ទាល់អមដោយកិត្តិយស និងកម្លាំងចិត្ត។ យុទ្ធសាស្ត្រដើម្បីរស់របស់ពួកគេដែលមានដូចជា "អាពាហ៍ពិពាហ៍ដើម្បីរស់" និង "ការរួមភេទដើម្បីរស់" ត្រូវបានទទួលស្គាល់ថាជាទង្វើវីរភាពមួយនៃការស៊ូទ្រាំប្រឆាំងនឹងរឿងចម្លែកៗដ៏ធំធេង។

១៤. កម្លាំងចិត្តនៃកូនៗរបស់អ្នករស់រានមានជីវិត និងការផ្តល់ការគាំទ្រដល់ម្តាយពួកគេ តែត្រូវបានទទួលស្គាល់ និងលើកទឹកចិត្ត។ ក្មេងៗទាំងនេះ ព្រមទាំងអ្នកជំនាន់ក្រោយដើរតួយ៉ាងសំខាន់ក្នុងការលុបបំបាត់ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ បញ្ចប់និទណ្ឌភាពរបស់ឧក្រិដ្ឋជនដែលកំពុងតែសប្បាយនឹងសិទ្ធិនេះ ព្រមទាំងផ្ទេរនូវការឈឺចាប់របស់ជនរងគ្រោះទៅអោយឧក្រិដ្ឋជន និងរដ្ឋាភិបាលទាំងនោះវិញ។

## ឃ. អំពីការទទួលខុសត្រូវ

១៥. ហិង្សាផ្លូវភេទនិងយេនឌ័រអំឡុងមានជម្លោះ ដូចដែលបានបកស្រាយនៅក្នុងសក្ខីកម្ម និងជាសរុបមករាប់បញ្ចូលថាជាឧក្រិដ្ឋកម្មអន្តរជាតិ និងបានប្រព្រឹត្តិដោយគ្រប់ភាគីទាំងអស់នៅក្នុងជម្លោះ ដែលរួមមានកងទ័ពដែលគាំទ្រដោយរដ្ឋាភិបាល និងអ្នកដែលមិននៅក្នុងជួរកងទ័ព។

១៦. មួយចំនួន ឬប្រហែលភាគច្រើននៃហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះត្រូវបានមើលរំលង ឬក៏រៀបចំដោយច្បាស់លាស់ជាយុទ្ធសាស្ត្រយោធាមួយដោយអ្នកនៅក្នុងជួររដ្ឋាភិបាលផ្ទាល់ដែលមានកាតព្វកិច្ចស្របច្បាប់ក្នុងការទប់ទល់នឹងហិង្សាទាំងនេះ ការពារជនរងគ្រោះ និងធ្វើអោយប្រាកដនូវការទទួលខុសត្រូវលើហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះនេះ។

១៧. ហេតុការណ៍ផ្សេងទៀតនៃហិង្សាផ្លូវភេទនិងយេនឌ័រកំពុងមានជម្លោះ ត្រូវបានបណ្តោយអោយកើតឡើង ឬរៀបចំដោយភាគីមិនមែនរដ្ឋាភិបាលនៅក្នុងជម្លោះនោះ ដែលមានកាតព្វកិច្ចទប់ទល់ការប៉ះពារមកលើជនស៊ីវិល ដែលមានទាំងស្ត្រីដែលបានធ្វើជាសាក្សី ចំពោះកម្មវិធីនេះ។

១៨. អ្នកប្រព្រឹត្តិ មានដូចជា អ្នកដែលមានឋានៈជាអ្នកដឹកនាំទាហានក្នុងកងប្រដាប់អាវុធ និងសមាជិកសេនាជន ប៉ូលីសក្នុងតំបន់ និងអង្គរក្សផ្ទាល់ខ្លួន។

១៩. យោងតាមចម្លើយដែលផ្តល់ដោយសាក្សី គ្មានឧក្រិដ្ឋជនណាមួយត្រូវបានយកមកកាត់ទោសចំពោះទង្វើរបស់ពួកគេឡើយ។

## ង. នីតិអន្តរជាតិ និងស្តង់ដារអន្តរជាតិដែលអាចអនុវត្តបាន

២០. នៅពេលដែលកើតឡើងនូវទង្វើទាំងនេះភាគច្រើនត្រូវបានបកស្រាយ នៅក្នុងចម្លើយជាភស្តុតាងដែលមានយ៉ាងហោចណាស់ការបំពាននិតិអន្តរជាតិ ដែលមានសុពលភាពអំឡុងពេលជម្លោះប្រដាប់អាវុធនោះ

ដោយបានតម្រូវថា ជនស៊ីវិលត្រូវបានរក្សា និងចាត់ទុកជាអំពើមនុស្សធម៌នៅគ្រប់កាលៈទេសៈទាំងអស់ ដោយគ្មានការរើសអើង រួមទាំងហេតុផលផ្លូវភេទផងដែរ (មាត្រារួមទី៣នៃអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩) រួមទាំងៈ

ក. ហិង្សាលើជីវិត និងមនុស្ស ដូចជាអំពើរំលោភសេពសន្ថវៈ ទារុណកម្មផ្លូវភេទ ការកាត់អវៈយវៈភេទ និងពេស្យាកម្មដោយបង្ខំ។

ខ. អំពើប្រមាថទៅលើកិត្តិយសផ្ទាល់ខ្លួន ដូចជា អំពើរំលោភសេពសន្ថវៈ ការចាប់ពង្រត់ និងទាសករផ្លូវភេទ ការឃុំខ្លួនដោយខុសច្បាប់ អាក្រាតដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយបង្ខំនិងដើម្បីរស់។

២១. លើសពីនេះទៅទៀត យោងទៅតាមសុពលភាពរបស់ច្បាប់នៅពេលដែលហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះ បានកើតឡើងអំពើទាំងនេះអាចរួមបញ្ចូលជាការបំពានលើនិតិព្រហ្មទណ្ឌអន្តរជាតិ ដែលមានដូចជាៈ

ក. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងករណីរំលោភសេពសន្ថវៈ ទារុណកម្មផ្លូវភេទ ការដាក់ជាទាសករផ្លូវភេទ ការឃុំខ្លួនដោយខុសច្បាប់ ពេស្យាកម្មដោយបង្ខំ ការមានគភ៌ដោយបង្ខំ ក្រៀវ ឬសកម្ម-ភាពផ្សេងទៀត ដែលមានទម្រង់ជាហិង្សាផ្លូវភេទដែលមានស្ថានទម្ងន់ប្រហាក់ប្រហែល ដែលបានប្រព្រឹត្តិជាទម្រង់រាលដាល ឬការវាយប្រហារជាប្រព័ន្ធដោយផ្ទាល់ទៅលើជនស៊ីវិល និងប្រព្រឹត្តិដោយការយល់ថាជាការវាយប្រហារ។

ខ. ឧក្រិដ្ឋកម្មសង្គ្រាម ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះរួមមានដល់ការធ្វើទារុណកម្ម ឬក៏ការប្រព្រឹត្តិអំពើអមនុស្សធម៌ ការប៉ុនប៉ងបង្កអោយមានការឈឺចាប់ជាទម្ងន់ ឬរបួសធ្ងន់ធ្ងរលើរាងកាយ ឬសុខភាព ការជម្លៀសដោយបង្ខំ ឬឃុំឃាំងដោយខុសច្បាប់ ព្រមទាំងទម្រង់ផ្សេងៗទៀតដែលធ្វើអោយមានភាពអាម៉ាស់ ឬការមើលងាយជាដើម។

២២. ជាពិសេស ករណីនៅប្រទេសកម្ពុជា ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ មានទាំងការរៀបការដោយបង្ខំ អំពើរំលោភសេពសន្ថវៈ និងការបំបែកបំបាក់គ្រួសារអាចជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ប្រសិនបើអំពើដែលបានប្រព្រឹត្តិប្រកបដោយឆន្ទៈក្នុងការបំផ្លាញទាំងអស់ ឬផ្នែកខ្លះនៃជាតិ ជនជាតិពូជសាសន៍ ឬក្រុមសាសន៍ណាមួយ។

២៣. អំពើដែលបានរៀបរាប់មកនេះក៏មានធាតុផ្សំ នៃការបំពានលើសទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនដែលអនុវត្តបានមួយចំនួន ក្នុងអំឡុងជម្លោះប្រដាប់អាវុធ និងដែលអាចអនុវត្តពេញលេញបានទៅលើផលប៉ះពាល់ជាបន្តបន្ទាប់ ដោយហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះនៅពេលជម្លោះបានបញ្ចប់ទៅ។ ប៉ុន្តែកត្តាដែលស្មុគស្មាញមួយនោះគឺ តម្រូវការថា ប្រទេសដែលពាក់ព័ន្ធត្រូវផ្តល់សច្ចាប័នលើសទ្ធិសញ្ញានោះ នៅពេលដែលអំពើ និងការប៉ះទង្គិចទាំងនោះបានកើតឡើង ដែលជាហេតុនាំអោយដែនអនុវត្ត ត្រូវបានកម្រិតភាគច្រើនទៅលើការប៉ះទង្គិចកំពុងបន្តដោយហិង្សាផ្លូវភេទ និងយេនឌ័រកំពុង

មានជម្លោះនោះ លើកលែងករណីប្រទេសនេប៉ាល់ដែលជាករណីជម្លោះថ្មីជាងគេ។ ដោយចងចាំចំណុចនេះ ការបំពានដែលអាចកើតមានលើសទ្ធិសញ្ញាកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ មានចំណុចគួរអោយកត់សម្គាល់ដូចជា

ក. ការរើសអើងលើស្ត្រី ចំពោះការអនុវត្តន៍សិទ្ធិជាមូលដ្ឋាន ដែលមានដូចជា ការឈឺចាប់ដោយវិបត្តិ និងគម្លាតសង្គម ដែលបណ្ដាលមកពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ការស្តារសរីរាង្គ បន្តពូជ និងកង្វះខាតវិធានការការពារចំពោះស្ត្រីមានផ្ទៃពោះ ការរៀបការ និងមានផ្ទៃពោះដោយបង្ខំ និងកើនឡើងនៃភាពងាយរងគ្រោះ ដោយសារហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះនាពេលអនាគត។ [(ការបំពានលើអនុសញ្ញាលើការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ដែលផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា (១៩៩២) បង់ក្លាដេស្ស (១៩៩០) នេប៉ាល់ (១៩៩០) និងទីម័រខាងកើត (២០០៣)]។

ខ. ការបំពានលើសិទ្ធិក្មេងស្រី ដែលមានដូចជា អំពើរំលោភកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ ការរៀបការជាមួយកុមារ ការបដិសេធចំពោះការសិក្សា ការបែកបាក់គ្រួសារ ការរើសអើង និងវិបត្តិផ្លូវចិត្ត ដែលទាក់ទងនឹងស្ថានភាពឪពុកម្តាយ [(ការបំពានលើអនុសញ្ញាសិទ្ធិកុមារ (CRC) ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា ឆ្នាំ (១៩៩២) បង់ក្លាដេស្ស (១៩៩០) នេប៉ាល់ (១៩៩០) និងទីម័រខាងកើត(២០០៣)]។

គ. ការបំពានលើសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានដូចជា ការបង្ខាំងខុសច្បាប់ ការឃុំខ្លួនតាមទំនើងចិត្ត ទាសភាពផ្លូវភេទ សិទ្ធិទាមទារសំណង [(ការបំពានលើកតិកាសញ្ញាអន្តរជាតិលើសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ (ICCPR) ផ្តល់សច្ចាប័នដោយកម្ពុជាឆ្នាំ (១៩៩២) បង់ក្លាដេស្ស (២០០០) នេប៉ាល់ (១៩៩១) និង ទីម័រខាងកើត (២០០៣)]។

ឃ. ការបំពានលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលមានដូចជា ការធ្វើការដោយបង្ខំ ទាសភាពក្នុងស្រុក ការបាត់បង់ទ្រព្យសម្បត្តិ ភាពគ្មានជម្រក ភាពទាល់ក្រ ការបាត់បង់កម្មសិទ្ធិដីធ្លី កង្វះឱកាសការងារ កង្វះសិទ្ធិសុខភាព និងបន្តពូជ [(ការបំពានលើកតិកាសញ្ញាអន្តរជាតិលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ផ្តល់សច្ចាប័នដោយកម្ពុជាឆ្នាំ (១៩៩២) បង់ក្លាដេស្ស (១៩៩៩) នេប៉ាល់ (១៩៩១) និងទីម័រខាងកើត (២០០៣)]។

ង. ទារុណកម្ម និងអំពើយង់ឃ្នង អមនុស្សធម៌ និងមើលងាយមើលថោកផ្សេងទៀត ដែលមានដូចជា អំពើរំលោភសេពសន្ថវៈ និងទម្រង់ធ្ងន់ធ្ងរផ្សេងទៀតនៃហិង្សាផ្លូវភេទ ការកាត់អវៈយវៈភេទ ការឃុំខ្លួនដោយគ្មានទំនាក់ទំនងមកខាងក្រៅ និងការអាក្រាតដោយបង្ខំ [(ការបំពានលើកតិកាសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (CAT) ផ្តល់សច្ចាប័នដោយកម្ពុជាឆ្នាំ (១៩៩២) បង់ក្លាដេស្ស (១៩៩៨) នេប៉ាល់ (១៩៩១) និងទីម័រខាងកើត (២០០៣)]។

២៤. វាក៏មានការកើតឡើងនៃការរួមបញ្ចូលគ្នានៃបទដ្ឋានអន្តរជាតិ ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ពីហិង្សាផ្លូវភេទនិងយេនឌ័រអំឡុងមានជម្លោះ និងផលប៉ះពាល់របស់វាដូចជាៈ

ក. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លើស្ត្រី សន្តិសុខ និងស្ថេរភាព ដែលផ្តួចផ្តើមដោយការអនុម័តជាឯកច្ឆ័ននៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជា-ជាតិ ១៣២៥ (ឆ្នាំ ២០០០) ដែលបន្ទាប់មកមានសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ១៨២០ (ឆ្នាំ ២០០៨) ១៨៨៩ (ឆ្នាំ ២០០៩) និង ១៩៦០ (ឆ្នាំ ២០១១) ដែលបានផ្តល់ជាគម្រោងដែលអាចទុកចិត្តបាន ក្នុងការបញ្ចប់និទណ្ឌភាពនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងធ្វើអោយមានជាប្រាកដនូវការចូលរួមរបស់ស្ត្រីយ៉ាងពេញលេញក្នុងការដោះស្រាយជម្លោះ ការចរចារដើម្បីសន្តិភាព ការស្ថាបនាសន្តិភាព យុត្តិធម៌អន្តរកាល សំណង និងដំណើរមករកភាពសះជាវិញ។

ខ. មូលដ្ឋានគ្រឹះ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិលើសិទ្ធិទាមទារសំណង និងការជួសជុលចំពោះជនរងគ្រោះនៃការបំពាននិតិសិទ្ធិមនុស្សអន្តរជាតិ និងការបំពានដ៏ធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្ស អន្តរជាតិ ដែលបានអនុម័តដោយ សេចក្តីសម្រេចសមាជរបស់អង្គការសហប្រជាជាតិ ៦០/១៤៧ នៅថ្ងៃទី ១៦ ធ្នូ ២០០៥ (មាត្រទី ១៦)។

គ. សេចក្តីថ្លែងការរបស់អង្គការសហប្រជាជាតិ លើគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការបំពានអំណាចដែលបានអនុម័តដោយសេចក្តីសម្រេចសមាជរបស់អង្គការសហប្រជាជាតិ ៤០/៣៤ នៅថ្ងៃទី ២៩ វិច្ឆិកា ១៩៨៥ (មាត្រាទី ១៣)

ឃ. គោលការណ៍ណែនាំនៃចំណុចគោលនៃយុត្តិធម៌ ដែលពាក់ព័ន្ធនឹងជនរងគោះ និងសាក្សីនៃឧក្រិដ្ឋកម្មដែលបានអនុម័តដោយ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហ-ប្រជាជាតិ ២០០៥/២០ ថ្ងៃទី ២២ កក្កដា ២០០៥ (មាត្រា ទី៣៥ និង៣៧)

ង. សេចក្តីប្រកាសរបស់ក្រុង ណៃរ៉ូប៊ី លើសិទ្ធិស្ត្រី និងកុមារី ក្នុងការទទួលសំណង និងការព្យាបាល ដែលបានអនុម័ត នៅថ្ងៃទី ២១ មីនា ២០០៧ (មាត្រ ទី៦) និង

ច. ការធ្វើបច្ចុប្បន្នភាពលើកម្រងនៃគោលការណ៍ សម្រាប់ការការពារ និងលើកតម្កើងសិទ្ធិមនុស្សតាមរយៈសកម្មភាព ដើម្បីប្រឆាំងនិទណ្ឌភាព ដោយដាក់ស្នើរទៅគណៈកម្មការសិទ្ធិមនុស្សនៅថ្ងៃទី ៨ កុម្ភៈ ២០០៥ (គោលការណ៍ ទី៣១)

## ច. អំពីភាពបរាជ័យក្នុងការអនុវត្តន៍

២៥. ស្របពេលក្នុងការទទួលស្គាល់ និងលើកទឹកចិត្ត ប្រទេសទាំងនោះ ដែលបានប្រឹងប្រែង ផ្តួចផ្តើមឱកាសដើម្បីដាក់បញ្ចូលការចូលរួមដ៏មានន័យរបស់ស្ត្រី ទស្សនៈវិស័យដ៏ពិសេសនៃការទទួលខុសត្រូវ និងយន្តការ

យុត្តិធម៌ អន្តរកាលគណៈវិនិច្ឆ័យបានបញ្ជាក់អំពីការខ្វះខាតយ៉ាងធ្ងន់ធ្ងរនូវឆន្ទៈនយោបាយ ក្នុងការធ្វើអោយប្រាកដថា យន្តការយុត្តិធម៌អន្តរកាលបន្ទាប់ពីជម្លោះបានដាក់បញ្ចូលយ៉ាងមានន័យ និងបញ្ជាក់អំពីហិង្សាផ្លូវភេទ និងយេនឌ័រ អំឡុងមានជម្លោះ ដែលត្រូវកំណត់ថា ជាបញ្ហានៅតាមប្រទេសនានាដែលត្រូវបានបង្ហាញដោយសាក្សីដែលផ្តល់សក្ខីកម្ម។ លទ្ធផលនោះគឺ យ៉ាងល្អតែនៅមានកម្រិតនៅឡើយ និងពិសេសបានព្យាយាមផ្តល់ជាសំណងមួយចំនួនសម្រាប់ជនរងគ្រោះ និងយ៉ាងអាក្រក់បំផុតនោះគឺ ការបដិសេធន៍យ៉ាងចំហក្នុងការទទួលស្គាល់ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ហើយចាត់ទុកវាថា មានការរួមបញ្ចូលការបំពានយ៉ាងធ្ងន់ធ្ងរនូវនិតិព្រហ្មទណ្ឌអន្តរជាតិ ជាផ្នែកនៃជម្លោះ និងដែលមាននៅក្រោមរបបមានការគាបសង្កត់។

២៦. សក្ខីកម្មក៏បានបង្ហាញអំពីភាពបរាជ័យរបស់រដ្ឋនានាក្នុងការអនុវត្តន៍និតិអន្តរជាតិ គោលនយោបាយ ការប្រឹងប្រែង និងស្តង់ដារដែលតម្រូវនូវការការពារ និងគាំទ្រសិទ្ធិស្ត្រី និងវិសមភាពពិតប្រាកដក្នុងអំឡុងជម្លោះប្រដាប់អាវុធបន្ទាប់ពីជម្លោះក្នុងអំឡុងអន្តរកាល និងសន្តិភាព។ បញ្ហានោះគឺមិនមែនមកពីភាពគ្មានច្បាប់ និងគោលការណ៍នោះទេ ប៉ុន្តែមកពីការបដិសេធន៍ ឬការតំអក់របស់ប្រទេសទាំងនេះក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ពួកគេ។



## ការផ្តល់អនុសាសន៍

ដោយយោងទៅតាមលទ្ធផលដែលបានមកពីការធ្វើសក្ខីកម្មបានបង្ហាញនៅក្នុងកម្មវិធីស្តាប់សម្លេងស្ត្រីមកគណៈវិនិច្ឆ័យ បានផ្តល់ជាសំណើរមួយចំនួនដែលក្នុងនោះសង្កត់ធ្ងន់លើការពាក់ព័ន្ធភាពបរាជ័យ ក្នុងការអនុវត្តកាតព្វកិច្ចជាតិ និងអន្តរជាតិដែលមានស្រាប់។

### ក. ចំពោះប្រទេស កម្ពុជា បង់ក្លាដេស្ស នេប៉ាល់ និងទីម័រខាងកើត

១. ធ្វើអោយប្រាកដថា អ្នករស់រានមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងគ្រួសាររបស់ពួកគេអាចស្វែងរកយុត្តិធម៌បានតាមរយៈយន្តការតុលាការឯករាជ្យ។

២. ធ្វើអោយជឿនលឿនយន្តការនៃជម្រើសផ្សេងក្រៅប្រព័ន្ធតុលាការ និងការស្ថាបនាសន្តិភាពដើម្បីផ្តល់ឱកាសអោយជនរងគ្រោះនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ក្នុងការជួយអោយសម្លេងពួកគេត្រូវបានឮ និងបើកទូលាយចំពោះការទទួលស្គាល់ជាសាធារណៈ និងពិភាក្សាជុំវិញបញ្ហាហិង្សាយេនឌ័រទាំងនេះ។

៣. គាំទ្រគំនិតផ្តួចផ្តើមក្នុងស្រុកដូចជា កម្មវិធីការស្តាប់សម្លេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីហិង្សាយេនឌ័រ ពេលមានជម្លោះ ដើម្បីអោយស្ត្រីអាចចែករំលែកបទពិសោធន៍ និងដើម្បីអាចទាមទារយុត្តិធម៌។

៤. បង្កើត និងអនុវត្តកម្មវិធីសំណងសម្រាប់ជនរងគ្រោះហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះ។

៥. ធ្វើអោយប្រាកដពីលទ្ធផលយូរអង្វែងនៃយន្តការយុត្តិធម៌អន្តរកាល ដោយអនុវត្តនូវសេចក្ដីសម្រេច និងមតិយោបល់ទាំងអស់ ធ្វើអោយប្រាកដពីមត៌ករបស់ពួកគេ ចំពោះច្បាប់ក្នុងស្រុក និងអភិបាលកិច្ច ហើយបោះជំហាន ដើម្បីការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី សិទ្ធិសេដ្ឋកិច្ច និងសង្គមដោយគ្មានការរើសអើង។

៦. បន្តផ្ដល់នូវ ការគាំទ្រចិត្តសង្គម ដល់ជនរងគ្រោះតាមដែលពួកគេត្រូវការ។

៧. ជូនជាលិខិតអញ្ជើញទៅតំណាងពិសេសរបស់អង្គការសហប្រជាជាតិ ផ្នែកយុត្តិធម៌អន្តរកាលដើម្បីមកធ្វើទស្សនកិច្ច និងវាយតម្លៃលើគុណភាពនៃយុត្តិធម៌ ដែលកំពុងត្រូវបានផ្ដល់អោយជនរងគ្រោះហិង្សាផ្លូវភេទ និងយេនឌ័រពេលមានជម្លោះក្នុងយន្តការយុត្តិធម៌អន្តរកាល។

៨. ចំពោះអ្វីដែលមិនទាន់មានត្រូវបង្កើតទៅតាមសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ ១៣២៥/១៨២០ ជាមួយគម្រោងសកម្មភាពរបស់ជាតិដែលភ្ជាប់សិទ្ធិស្ត្រី និងសិទ្ធិមនុស្សរបស់អង្គការក្រៅរដ្ឋាភិបាលជាមួយនឹងពេលវេលាជាក់លាក់ ការចង្អុលបង្ហាញច្បាស់លាស់ និងធនធានគ្រប់គ្រាន់ព្រមទាំងផ្ដល់អាទិភាព លើការអនុវត្តន៍របស់ពួកគេ។



## ខ. ចំពោះប្រទេសនីមួយៗ

### ១. ប្រទេសកម្ពុជា
### ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

៩. ចំពោះអង្គជំនុំជម្រះ: ពង្រីកនូវវិសាលភាពបច្ចុប្បន្នរបស់សំណុំរឿង ០០២/០១ ដើម្បីបន្ថែមនូវ ផ្នែកដីការដំណោះស្រាយដែលទាក់ទងនឹងការរៀបការដោយបង្ខំ

១០. ចំពោះសហព្រះរាជអាជ្ញា: ទាក់ទងនឹងករណី ០០៣ និង ០០៤ ត្រូវពិនិត្យយ៉ាងហ្មត់ចត់នូវឯកសារសំអាងភស្តុតាងរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលទាក់ទងនឹងការរំលោភសេពសន្ថវៈ និងប្រភេទផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ ព្រមទាំងឯកសារផ្សេងៗទៀត ដែលបានប្រមូលដោយអង្គការក្រៅរដ្ឋាភិបាល ចាប់តាំងពីតំណាក់កាលស៊ើបសួរ ត្រូវបានដាក់ជូនជាមួយនឹងការពិនិត្យមើល ដើម្បីបញ្ជាក់ថាតើបទល្មើសហិង្សាផ្លូវភេទ កើតឡើងនៅកន្លែងកើតហេតុ មាននៅក្នុងតំណាក់កាលស៊ើបសួរ។ ប្រសិនបើត្រូវបានចាប់ខ្លួន ត្រូវដាក់ទៅជាមួយនឹងសហចៅក្រមស៊ើបអង្កេត។

១១. ចំពោះសហចៅក្រមស៊ើបអង្កេត: សម្រួលសំនួរអោយសាមញ្ញ ដែលទាក់ទងនឹងហិង្សាផ្លូវភេទ និងយេនឌ័រ កំពុងមានជម្លោះ និងការចោទប្រកាន់ផ្សេងទៀតដែលបានស៊ើបសួរសម្រាប់ករណី ០០៣ និង ០០៤។

១២. ចំពោះតុលាការៈ ធ្វើអោយប្រាកដថា បទពិសោធន៍នៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ត្រូវបានដាក់បញ្ចូលក្នុងគម្រោងកេរ្តិ៍តំណែល។

១៣. ចំពោះតុលាការៈ បង្កអោយមានការចូលរួមរបស់អង្គការសង្គមស៊ីវិល និងជនរងគ្រោះនៅក្នុងការធ្វើគម្រោងកេរ្តិ៍តំណែលផ្សេងទៀតនាថ្ងៃអនាគត និង/ឬ គំនិតផ្តើមវិធានការក្រៅប្រព័ន្ធតុលាការជាពិសេសការចូលរួមរបស់ស្ត្រី និងជនរងគ្រោះនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ។

១៤. ចំពោះអង្គភាពគាំទ្រជនរងគ្រោះៈ ដោយសហការជាមួយអង្គការសង្គមស៊ីវិល អនុវត្តវិធានការក្រៅតុលាការដែលបញ្ជាក់អំពីតម្រូវការរបស់ជនរងគ្រោះនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ឧទាហរណ៍ដូចជា ការធ្វើអោយមានការចងចាំ ការនិយាយការពិត និងជួយដល់ការស្រាវជ្រាវ និងការផ្តល់នូវឯកសារផ្សេងៗ ដើម្បីបំពេញការទទួលខុសត្រូវរបស់តុលាការចំពោះសហគមន៍ ដើម្បីធ្វើអោយប្រាកដថា ជនរងគ្រោះមានជីវិតប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ។

## ចំពោះតុលាការជាតិប្រទេសកម្ពុជា

១៥. សម្របសម្រួល និងជម្រុញការកាត់ទោស បទល្មើសហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះនៅតុលាការក្នុងស្រុក ដោយធ្វើអោយប្រាកដថា ជនរងគ្រោះមានឱកាសដែលសម្លេងពួកគេត្រូវបានឮ។

## ចំពោះរាជរដ្ឋាភិបាលកម្ពុជា

១៦. ផ្តួចផ្តើមនូវការស៊ើបអង្កេតភ្លាមៗ និងដោយគ្មានលម្អៀង ពីភស្តុតាងដែលមានស្រាប់ ធ្វើអោយប្រាកដ ការកាត់ទោសដោយមានប្រសិទ្ធភាពទៅលើហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ដោយតម្រូវអោយឧក្រិដ្ឋជនម្នាក់ៗ ទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តិក្នុងអតីតកាល និងដែលកំពុងបន្តការបំពាន

១៧. គាំទ្រគំនិតផ្តួចផ្តើម ការផ្សះផ្សាររបស់អង្គការសង្គមស៊ីវិល នៅថ្នាក់ស្រុក

១៨. ការពារសហគមន៍ជនជាតិភាគតិចនានា នៅក្នុងប្រទេសកម្ពុជា និងគោរពសិទ្ធិរបស់ពួកគេដោយត្រូវធ្វើឡើងដោយស្មើភាពគ្នា និងដោយគ្មានការរើសអើង។

១៩. គាំទ្រនូវការផ្តល់ឯកសារ ដើម្បីរក្សាទុកជាប្រវត្តិសាស្ត្រ នូវបទពិសោធន៍ពីអតីតកាលរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិត ចំពោះការទម្លាយភាពស្ងៀមស្ងាត់ និងដើម្បីជួយក្នុងដំណើរការសះជា

២០. បង្កើតកម្មវិធីសំណង ដោយធ្វើការប្រឹក្សាជាមួយជនរងគ្រោះហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះដែលឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។

## ចំពោះក្រសួងកិច្ចការនារីប្រទេសកម្ពុជា

២១. ផ្តល់ភាពជាអ្នកដឹកនាំក្នុងជួររដ្ឋាភិបាល ដើម្បីគាំទ្រដល់ការកាត់ទោសហិង្សាផ្លូវភេទ និងយេនឌ័រ អំឡុងមាន ជម្លោះ និងផ្តល់វិធានការក្រៅប្រព័ន្ធតុលាការ ដើម្បីផ្តល់គាំទ្រដល់ជនរងគ្រោះ។

## ២. ប្រទេសបង់ក្លាដេស

គណៈវិនិច្ឆ័យបានផ្តល់ជាមតិចំពោះរដ្ឋាភិបាលបង់ក្លាដេស្ស ក្នុងការបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសបង់ក្លាដេស្ស (ICTB) ដើម្បីកាត់ទោសឧក្រិដ្ឋជន ដែលបានបង្កអំពើឃោឃៅក្នុងអំឡុងសង្គ្រាមដើម្បីរំដោះប្រទេសនាឆ្នាំ ១៩៧១ និងដើម្បីដាក់បញ្ចូលឧក្រិដ្ឋកម្មនៃហិង្សាផ្លូវភេទ នៅក្នុងអណត្តិរបស់ប្រទេសនេះ។ ការផ្តួចផ្តើមអោយមានវាឡើង និងដែលធ្វើអោយអ្នកនៅមានជីវិតមួយចំនួនអាចទទួលបានយុត្តិធម៌។ គណៈវិនិច្ឆ័យក៏បានសាទរចំពោះការទទួលស្គាល់ជានិមិត្តរូប ដែលរដ្ឋាភិបាលបង់ក្លាដេស្សបានផ្តល់អោយដល់ជនរងគ្រោះនៃការរំលោភទាំងនេះជា "ប៊ីរ៉ុងហ្គោណាស" ឬ "វីរនារីនៃសង្គ្រាម" ។ ការទទួលស្គាល់ជាវិជ្ជមានទាំងនេះ ត្រូវតែមានការគាំទ្រដោយមានជាការផ្តល់សំណងជាសម្ភារៈជាក់ស្តែង និងការគាំទ្រផ្សេងទៀត ដែលនឹងជួយដល់ប៊ីរ៉ុងហ្គោណាស ទាំងនោះសះជាពីអតីតកាល និងរស់នៅដោយភាពថ្លៃថ្នូរ។ ចំណុចនេះហើយ ដែលរដ្ឋាភិបាលបង់ក្លាដេស្សកំពុងតែមានភាពចន្លោះប្រហោងនៅឡើយ។



## ចំពោះសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិបង់ក្លាដេស

២២. បង្កើតយន្តការដែលអាចធ្វើអោយសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិបង់ក្លាដេស្សអាចផ្តល់ការការពារជូនដល់ស្ត្រីដែលនៅមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រក្នុងអំឡុង និងក្រោយមានជម្លោះដើម្បីការចូលរួមក្នុងសាលាក្តី ឧក្រិដ្ឋកម្មអន្តរជាតិបង់ក្លាដេស្សនេះ ក្នុងនាមជាសាក្សី ដោយមានអង្គភាពគាំទ្រជនរងគ្រោះ ផ្តល់ជាជំនួយតាមដែលអាចធ្វើទៅបានសម្រាប់អ្នកមានជីវិតដើម្បីអាចអោយពួកគេផ្តល់ជាសក្ខីកម្មដល់សាលាក្តីនេះ។

## ចំពោះរដ្ឋាភិបាលបង់ក្លាដេស

២៣. ក្នុងការសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីរៀបចំជាយន្តការក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដូចជា កម្មវិធីការស្តាប់ជាសាធារណៈ គណៈកម្មការស្វែងរកការពិត ឬយន្តការដែលសមស្របផ្សេងទៀត សម្រាប់បរិបទ ប្រទេសបង់ក្លាដេស្ស ដើម្បីផ្តល់អោយស្ត្រីដែលមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះនូវសុវត្ថិភាព នូវការគោរព និងវេទិការដែលមានសុវត្ថិភាពដើម្បីទម្លាយភាពស្ងៀមស្ងាត់របស់ពួកគេ និងដើម្បីចែករំលែករឿងរបស់ពួកគេ ត្រូវចងចាំដែរថា

មានស្ត្រីមួយចំនួនត្រូវការធានានូវការសម្ងាត់ និងអនាមិកភាព។

២៤. ក្នុងការសហការជាមួយអង្គការសង្គមស៊ីវិល អនុវត្តវិធានការដើម្បីកំណត់អត្តសញ្ញាណអ្នកមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ធានានូវការសម្ងាត់ ចងក្រងឯកសារនូវរឿងរបស់ពួកគេ និងធានានូវសិទ្ធិយ៉ាងច្បាស់លាស់ ការទទួលស្គាល់ និងផលសំណងក្នុងនាមជាអ្នកប្រយុទ្ធដើម្បីសេរីភាព។ សំណងទាំងនេះត្រូវតែមានដូចជា ប្រាក់សោធនជារៀងរាល់ខែ ការផ្តល់ជាឱសថ និងការព្យាបាលផ្នែកស្មារតីដោយមិនគិតកម្រៃ និងវិធានការសេដ្ឋកិច្ចសង្គមផ្សេងទៀតដែលត្រូវការដោយស្ត្រីដែលរស់រានមានជីវិត ដែលនឹងអាចអោយពួកគេរស់នៅក្នុងជីវិតប្រកបដោយភាពថ្លៃថ្នូរ។

២៥. សហការជាមួយគម្រោងផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល ដែលមានស្រាប់ការពារកេរ្តិ៍ដំណែលសង្គ្រាមរំដោះជាតិជាអាទិភាព។ ហេតុនេះ រដ្ឋាភិបាលត្រូវបង្កើតកម្មវិធីអប់រំប្រជាជន រួមទាំងអ្នកជំនាន់ក្រោយអំពីតថភាពនៃសង្គ្រាម។ ប្រជាជនត្រូវតែត្រូវបានផ្តល់ការយល់ដឹងអំពីការតស៊ូរបស់បីរ៉ុងហ្គោណាស ការឈឺចាប់ដែលពួកគេបានទ្រាំទ្រ និងការលះបង់របស់ពួកគេសម្រាប់ជាតិ ដើម្បីលុបបំបាត់ស្លាកស្នាមទុយ៌ស និងគម្លាតសេដ្ឋកិច្ចសង្គម ដែលអ្នកជាបីរ៉ុងហ្គោណាសបានឆ្លងកាត់ និងលើកពួកគេអោយសាកសមជា "វីរនារីនៃសង្គ្រាម"

២៦. ការពារសហគមន៍ ជនជាតិភាគតិចហិណ្ឌូក្នុងប្រទេសបង់ក្លាដេស្ស និងគោរពសិទ្ធិរបស់ពួកគេដោយចាត់ទុកពួកគេដោយសមភាព និងដោយគ្មានការរើសអើង។

## ៣. ប្រទេសនេប៉ាល់

គណៈវិនិច្ឆ័យបានកត់សម្គាល់ថា នៅក្នុងប្រទេសនេប៉ាល់ អង្គការសង្គមស៊ីវិលមួយចំនួនដូចជា អង្គការអេរ៉ូខេស៊ីបានចូលរួមក្នុងប្រព័ន្ធច្បាប់ជាតិតាមដែលអាចធ្វើទៅបាន ហើយបានបញ្ចេញទាំងអស់នូវមធ្យោបាយដែលមាន និងដែលអាចប្រើប្រាស់បាន។ បច្ចុប្បន្ននេះ នយោបាយប្រទេសនេប៉ាល់កំពុងជួបវិបត្តិដែលមានដូចជា ការរំលាយសភា និងតម្រូវការ ការបង្កើតការបោះឆ្នោតថ្មី។ ប៉ុន្តែរដ្ឋធម្មនុញ្ញដែលមានសព្វថ្ងៃមិនបានផ្តល់នូវនិតិវិធីលើព្រឹត្តិការណ៍ជាយថាហេតុដូចនេះឡើយ ដែលជាហេតុធ្វើអោយមានតម្រូវការធ្វើវិសោធនកម្ម។ ដោយសារតែស្ថាប័នមានអំណាចនានាធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញនោះគឺសភា ត្រូវបានរំលាយបានធ្វើអោយគ្មានលទ្ធភាព ណាមួយក្នុងការធ្វើវិសោធន-កម្មលើរដ្ឋធម្មនុញ្ញឡើយ។ រដ្ឋាភិបាលបណ្តោះអាសន្នត្រូវតែចាត់វិធានការជាបន្ទាន់ ដើម្បីបំបាត់វិបត្តិនេះធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញបង្កើតការបោះឆ្នោតដើម្បីបង្កើតសភាថ្មីមួយ និងបង្កើនលទ្ធភាពក្នុងការអនុវត្តលិទ្ធិប្រជាធិបតេយ្យរបស់រដ្ឋាភិបាល។

## ចំពោះរដ្ឋាភិបាលនេប៉ាល់

២៧. រាយការណ៍ទៅក្រុមប្រឹក្សាសន្តិសុខ លើការចង្អុលបង្ហាញនៃការអនុវត្តន៍ផែនការសកម្មភាពជាតិដោយរាប់បញ្ចូលទាំងចំនួននៃករណីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ដែលត្រូវបានស៊ើបអង្កេតចំនួនករណីដែលយកមកជំនុំជម្រះ ចំនួនស្ត្រីដែលបានផ្តល់ជាសំណង និងអំពីការចងចាំនិងការឈឺចាប់របស់ប្រជាជន និងស្ត្រីនៃប្រទេសនេប៉ាល់ដែលត្រូវបានទទួលស្គាល់ និងរក្សាសម្រាប់អ្នកជំនាន់ក្រោយ។

២៨. បង្កើតកម្មវិធីបង្ហាញការពិត និង/ឬ យន្តការក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដើម្បីលើកឡើងពីហិង្សាដែលទាក់ទងនឹងជម្លោះ ដែលមានទាំងហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះដោយគ្មានវិធានណាមួយក្នុងការលើកលែងអោយឧក្រិដ្ឋជននៃឧក្រិដ្ឋកម្មដ៏ឃោរឃៅ ដូចជាហិង្សាផ្លូវភេទ និងយេនឌ័រកំពុង មានជម្លោះនោះឡើយ

២៩. ដកមកវិញនូវសំណើរក្នុងការផ្តល់ជាការលើកលែងទោសជាទូទៅដល់ឧក្រិដ្ឋជន ដែលបានប្រព្រឹត្តិហិង្សាដែលទាក់ទងនឹងជម្លោះ និងផ្តល់នូវការធានាដល់ជនរងគ្រោះហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ដែលថា ឧក្រិដ្ឋជនទាំងនោះមិនត្រូវរួចខ្លួនឡើយ។

៣០. ពង្រឹងគណៈកម្មការសិទ្ធិមនុស្សក្នុងប្រទេសលុបបំបាត់នូវការដាក់កម្រិតទៅលើអាណត្តិរបស់ពួកគេធ្វើដូចនេះវាអាចបង្កលក្ខណៈក្នុងការលើកឡើងនូវការបំពានដែលបានកើតឡើងក្នុងរយៈពេល៦ខែនៃការកើតឡើង និងបានផ្តល់អំណាចក្នុងការនិយាយពីហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះ។

៣១. ធ្វើវិសោធនកម្មច្បាប់ ដើម្បីអោយស្របទៅតាមសេចក្តីបង្គាប់របស់តុលាការកំពូល ប្រទេសនេប៉ាល់ដកចេញនូវកម្រិតដែលមានរយៈពេលត្រឹម ៣៥ថ្ងៃ ក្នុងការរាយការណ៍អំពីបទល្មើសរំលោភនិងហិង្សាផ្លូវភេទ។

៣២. ធ្វើវិសោធនកម្មលើវិធានភស្តុតាង ដែលទាក់ទងនឹងហិង្សាផ្លូវភេទ ដើម្បីអនុវត្តតាមស្តង់ដានិតិ-អន្តរជាតិ និងដាក់បន្ថែមនូវភស្តុតាងសំអាងហេតុ និងភស្តុតាងស្ថិតក្នុងល័ក្ខខ័ណ្ឌបង្ខិតបង្ខំរួមទាំងភស្តុតាងវេជ្ជសាស្រ្ត និងភស្តុតាងទាក់ទងនឹងផ្លូវច្បាប់។

៣៣. ទទួលស្គាល់ជាផ្លូវការនៃការកើតឡើងហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងការបញ្ចប់ការធ្វើអោយរងគ្រោះទ្វេដងទៅលើអ្នករស់រានមានជីវិតនៃហិង្សាផ្លូវភេទ ដែលបណ្តាលមកពីការបដិសេធជាបន្តបន្ទាប់។

៣៤. ទទួលស្គាល់ថាជាជនរងគ្រោះ ដល់អ្នករស់រានមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះគ្រប់មធ្យោបាយទាំងអស់នៃការផ្តល់សំណង ដោយមានទាំងការផ្តល់ជាជំនួយនូវការធូរ

ស្រាលបណ្ដោះអាសន្ន។

៣៥. ធ្វើអោយប្រាកដថា ករណីទាំងអស់នៃហិង្សាទាក់ទងនឹងជម្លោះ រួមទាំងហិង្សាផ្លូវភេទ និងយេនឌ័រ មិនត្រូវបានដកចេញដោយសេចក្ដីសម្រេចនានាឡើយ ហើយជនរងគ្រោះ សាក្សី និងភស្តុតាងត្រូវបានរក្សា និងការពារ។

## ៤. ប្រទេសទីម័រខាងកើត

វិធានការយុត្តិធម៌អន្តរកាលត្រូវបានអនុវត្តរួចហើយ ដោយរដ្ឋាភិបាលទីម័របានផ្ដល់វិភាគទានដ៏សំខាន់ ដើម្បីសម្រេចបាននូវយុត្តិធម៌បន្ទាប់ពីជម្លោះ ប៉ុន្តែនៅតែមិនទាន់គ្រប់គ្រាន់នៅឡើយ។ រដ្ឋាភិបាលចាំបាច់ជាបន្ទាន់ត្រូវអនុវត្តតាមវិធានការណ៍ផ្សេងជាច្រើនទៀតដើម្បីបញ្ចប់វប្បធម៌និទណ្ឌភាព ដែលរដ្ឋាភិបាលខ្លួនឯងផ្ទាល់បានជម្រុញ (ឧទាហរណ៍ តាមរយៈការលើកលែងទោសដល់អ្នកដែលមិនទាន់បានផ្ដន្ទាទោសពីឧក្រិដ្ឋកម្មសង្គ្រាម) ហើយត្រូវធ្វើអោយបានហ្មត់ចត់នូវការលើកឡើងពីឧក្រិដ្ឋកម្មហិង្សាផ្លូវភេទ និងយេនឌ័រ ដែលបានប្រព្រឹត្តិក្នុងជម្លោះអតីតកាល ហើយផ្ដល់អោយជនរងគ្រោះមកវិញនូវយុត្តិធម៌ខាងសេដ្ឋកិច្ច និងសង្គមព្រមទាំងយុត្តិធម៌តាមផ្លូវតុលាការ។



### ចំពោះរដ្ឋាភិបាលទីម័រខាងកើត

៣៦. ទទួលស្គាល់ភ្លាមៗ ស្ត្រីដែលរងគ្រោះដោយសារហិង្សាផ្លូវភេទ និងយេនឌ័រក្នុងអំឡុងជម្លោះដើម្បីឯករាជ្យ ជាវិរនារីនៃសង្គ្រាម ហើយធ្វើអោយពួកគេទទួលបាននូវផលប្រយោជន៍ និងឯកសិទ្ធិដូចទាហានជើងចាស់ផ្សេងៗទៀតផងដែរ។

៣៧. ពិនិត្យ និងអនុវត្តភ្លាមៗនូវសេចក្ដីច្បាប់ ដែលអស់សុពលភាពតាំងពីការបោះឆ្នោតលើកចុងក្រោយ ដើម្បីបង្កើតកម្មវិធីសំណងយេនឌ័ររួមសម្រាប់ជនរងគ្រោះ ធ្វើអោយប្រាកដនូវការដាក់បញ្ចូលអ្នករស់រានមានជីវិតនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ បង្កើតវិទ្យាស្ថាននៃការចងចាំដែលនឹងអនុវត្តភាគច្រើនទៅលើមតិយោបល់របស់ CAVR និងរៀបចំធនធានថវិកាអោយបានគ្រប់គ្រាន់ដើម្បីគាំទ្រការអនុវត្តរបស់ពួកគេ។

៣៨. បង្កើតជាមូលនិធិសាមគ្គីភាព ដូចដែលត្រូវបានផ្ដល់ជាយោបល់ដោយលោក អគ្គលេខាធិការនៅក្នុងរបាយការណ៍របស់លោកនៅឆ្នាំ ២០០៦ ស្ដីពីយុត្តិធម៌ និងការផ្សះផ្សារសម្រាប់ប្រទេសទីម័រដែលនឹងទទួលយកវិភាគទានពីប្រទេសជាសមាជិកអង្គការសហប្រជាជាតិ និងប្រាក់ចំណូលពីប្រទេសទីម័រខ្លួនឯងផ្ទាល់ផ្ទេរទៅកាន់កម្មវិធីសំណងជនរងគ្រោះ។

៣៩. ទទូចសុំអោយប្រធានាធិបតីសាធារណៈរដ្ឋប្រទេសនេះ ទទួលស្គាល់នូវកម្រិតរបស់សិទ្ធិរដ្ឋធម្មនុញ្ញស្ដីពីការលើកលែងទោស ដែលនឹងធានានូវកំណើននៃតម្លាភាព និងការផ្ដល់យោបល់ក្នុងការសម្រេចចិត្ត។

៤០. ត្រូវធានាថា ឯកសារទាំងអស់នៃអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងក្រុមស៊ើបអង្កេតឧក្រិដ្ឋកម្មកម្រិតធ្ងន់ រួមបញ្ចូលទាំងភស្តុតាងដែលប្រមូលបានទាំងអស់តាមរយៈការស៊ើបអង្កេតរបស់ក្រុមនេះ អំពីហិង្សាផ្លូវភេទ និងយេនឌ័រ អំឡុងមានជម្លោះ ត្រូវបានរក្សាយ៉ាងមានសុវត្ថិភាពរហូតដល់ពេលបទបញ្ជា UNMIT ត្រូវចប់នៅចុងឆ្នាំ ២០១២ និងធានាថា ឯកសារទាំងនេះអាចយកមកប្រើប្រាស់បានសម្រាប់ការកាត់ទោសនាពេលអនាគត ការនិយាយការពិត និងដំណើរយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការផ្សេងទៀត ការចងចាំ និងកម្មវិធីផ្តល់សំណង។

៤១. ចុះបញ្ជីដីការបណ្តោះអាសន្ននៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ជាមួយប៉ូលីសអន្តរជាតិអាំងទែប៉ូល ព្រមទាំងចេញជាដីការបណ្តោះអាសន្ន ដោយផ្អែកទៅលើការប្រឹក្សាដោយក្រុមស៊ើបអង្កេតឧក្រិដ្ឋកម្មកម្រិតធ្ងន់។

៤២. ត្រូវធានាថា ក្រសួងយុត្តិធម៌ប្រទេសទីម័រ និងការិយាល័យអគ្គព្រះរាជអាជ្ញាស្នើសុំ ជំនួយអន្តរជាតិដើម្បីបង្កើនសមត្ថភាពនៃបុគ្គលិកតុលាការ ដើម្បីកាត់ទោសលើឧក្រិដ្ឋកម្មអន្តរជាតិ។

៤៣. ត្រូវធានាថាតុលាការក្នុងស្រុកមានឯករាជ្យភាព ដើម្បីតាមដាន ដោយគ្មានការជ្រៀតជ្រែកពីនយោបាយនូវករណីទាំងអស់អំពីភស្តុតាង ដែលបានប្រមូលដោយក្រុមស៊ើបអង្កេតឧក្រិដ្ឋកម្មកម្រិតធ្ងន់ដោយមានទាំងអ្នកដែលពាក់ព័ន្ធនឹងហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះនៅពេលដែលបេសកកម្ម UNMIT បានបញ្ចប់។

៤៤. អភិវឌ្ឍកម្មវិធីសេដ្ឋកិច្ច និងជំនួយសង្គមដោយជំនួស ជាពិសេសសម្រាប់ជនរងគ្រោះ ដែលងាយនឹងរងគ្រោះ ដោយការបំពានសិទ្ធិមនុស្សដ៏គួរអោយស្អប់ខ្ពើម ជាពិសេសជនរងគ្រោះនៃហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះ

៤៥. គាំទ្រនូវការរាប់បញ្ចូលគម្រោងផ្តួចផ្តើមការចងចាំថ្នាក់ជាតិផ្តោតលើជនរងគ្រោះ ដែលទទួលស្គាល់គ្រប់ជនរងគ្រោះនៃជម្លោះទាំងអស់ដោយមិនគិតពីការពាក់ព័ន្ធរឿងនយោបាយទាំងពីមុន និងពេលបច្ចុប្បន្ន។

៤៦. ផ្តល់សច្ចាប័នជាបន្ទាន់លើអនុសញ្ញាស្តីពីការប្រឆាំងនឹងការការពារ ការបំបោះបង់ដោយបង្ខំដល់មនុស្សគ្រប់រូប និងបង្កើតគណៈកម្មាការសម្រាប់អ្នកបាត់ខ្លួន ដោយមានទាំងការផ្តល់ជាភាពប្រាកដប្រជាលើច្បាប់ និងយុត្តិធម៌ចំពោះគ្រួសារជនរងគ្រោះ និងភាពច្បាស់លាស់របស់អ្នកជាទីស្រលាញ់របស់ពួកគេដែលកំពុងតែបាត់ខ្លួន។

## ចំពោះអង្គការសហប្រជាជាតិ

៤៧. អគ្គលេខាធិការអង្គការសងប្រជាជាតិ ត្រូវខិតខំប្រឹងប្រែងជាបន្ទាន់ ដើម្បីប្រាកដថា ក្រុមស៊ើបអង្កេតឧក្រិដ្ឋកម្មកម្រិតធ្ងន់ មានធនធាន និងពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើការស៊ើបអង្កេត។

អង្គការសហប្រជាជាតិ ត្រូវតែធ្វើអោយជឿនលឿនដល់យន្តការដែលមានប្រសិទ្ធិភាព ដើម្បីផ្តល់ជាការត្រួតពិនិត្យដោយមិនឈប់ឈរ ហើយធ្វើអោយប្រាកដថា អាជ្ញាធរជាតិចាត់វិធានការលើករណីទាំងនេះ ត្រូវបានផ្តល់ជាឯកសារដោយក្រុមស៊ើបអង្កេតឧក្រិដ្ឋកម្មកម្រិតធ្ងន់នេះ។

## គ. ចំពោះស្ថាប័នក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក

៤៨. ដោយមានការដឹកនាំរបស់ក្រុមប្រឹក្សាតំបន់អាស៊ីប៉ាស៊ីហ្វិកចំពោះសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ១៣២៥ សម្រួលលើការរៀបចំ និងការអនុវត្តន៍ផែនការសកម្មភាពក្នុងតំបន់នៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ១៣២៥/១៨២០ ដោយគ្រប់ប្រទេសទាំងអស់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមិនទាន់បានអនុវត្តនៅឡើយនូវស្តង់ដាគំរូនៃពេលវេលាសុចណាករណ៍ដោយជាក់លាក់ និងធនធានគ្រប់គ្រាន់។

៤៩. សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ត្រូវធានានូវការយកចិត្តទុកដាក់លើបញ្ហាហិង្សាផ្លូវភេទ និងយេនឌ័រ អំឡុងមានជម្លោះនៅក្នុងរបៀបវារៈ និងផែនការការងាររបស់ខ្លួន ជាពិសេសការផ្តោតទៅលើកាតព្វកិច្ច ដែលស្ថិតក្រោមសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ១៣២៥/១៨២០ ដើម្បីលើកឡើងពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះក្នុងតំបន់ និងលើកតំកើងទស្សនវិស័យយេនឌ័រ ស្តីពីសន្តិភាព និងស្ថេរភាព។ ជាពិសេស បញ្ចប់និទណ្ឌភាពនៃហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងធានានូវសំណងដែលមានប្រសិទ្ធិភាពដល់ជនរងគ្រោះត្រូវតែជាចំណុចយកចិត្តទុកដាក់ដោយអន្តរគណៈកម្មការ ស្តីពីសិទ្ធិមនុស្សរបស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (IACHR) ដោយគណៈកម្មការសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ចំពោះការលើកតំកើង និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) និងពីស្ថាប័នដែលពាក់ព័ន្ធផ្សេងទៀត។

៥០. សមាគមន៍សហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង (SAARC) ក្នុងអាណត្តិរបស់ខ្លួនបង្កើតជាយន្តការអនុតំបន់ដើម្បីលើកពីបញ្ហាសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មអន្តរជាតិ ដែលរួមទាំងហិង្សាផ្លូវភេទ និងយេនឌ័រកំពុងមានជម្លោះ។

## ឃ. ចំពោះសហគមន៍អន្តរជាតិ

### ចំពោះអង្គការសហប្រជាជាតិ

៥១. ជម្រុញយ៉ាងខ្លាំងក្លា ដល់រដ្ឋាភិបាលនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដើម្បីរាយការណ៍ដល់គ្រប់ស្ថាប័នសទ្ធិសញ្ញា សិទ្ធិមនុស្សទាំងអស់អំពីការប្រឹងប្រែងអនុវត្តស្តីពីស្ត្រី សន្តិសុខ និងស្ថេរភាព

៥២. ប្រើប្រាស់ និងបញ្ចេញអោយអស់លទ្ធភាពនូវរាល់និតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត ក្នុងសាលាក្តីរបស់ពួកគេ ដើម្បីតស៊ូមតិបញ្ចប់និទណ្ឌភាពនៃហិង្សា

ផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដោយតំណាងពិសេសនៃអគ្គ-លេខាធិការទទួលបន្ទុកលើហិង្សាផ្លូវភេទពេលមានជម្លោះ តំណាងពិសេសលើហិង្សាប្រឆាំងនឹងស្ត្រី ដើមហេតុ និងលទ្ធផលតំណាងពិសេស ប្រឆាំងនឹងការធ្វើទារុណកម្ម និងតំណាងពិសេសលើការលើកតម្កើងការពិត យុត្តិធម៌ សំណង និងការធានានូវការមិនកើតឡើងម្តងទៀត។

៥៣. ទទូចសុំអោយប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិកដែលពាក់ព័ន្ធ បង្កើតមូលនិធិស្វែងរកការពិតថ្នាក់ជាតិសម្រាប់ជនរងគ្រោះហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះស្របទៅតាមកាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ និងស្ថាប័នរួមនៃបទដ្ឋានស្តីពីសិទ្ធិទទួលបានសំណង ដូចដែលបានចែងនៅក្នុងមាត្រាទី៨ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស មាត្រាទី៩ នៃកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ មាត្រាទី៦ នៃកិច្ចព្រមព្រៀង អន្តរជាតិស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រាទី១៤ នៃកិច្ចព្រមព្រៀងស្តីពីការប្រឆាំងការធ្វើទារុណកម្ម និងទណ្ឌកម្មឃោរឃៅ និងអំពើអមនុស្សធម៌ផ្សេងទៀត មាត្រាទី១៦ នៃគោលការណ៍ណែនាំ និងវិធានបឋមរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធទទួលបានសំណងដល់ជនរងគ្រោះនៃការបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការបំពានលើនិតិសិទ្ធិមនុស្សអន្តរជាតិ មាត្រាទី១៣ នៃសេចក្តីថ្លែងការណ៍ លើគោលការណ៍មូលដ្ឋាន ស្តីពីយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការបំពានអំណាចមាត្រាទី៣៥ និង៣៧ នៃគោលការណ៍ណែនាំស្តីពីចំណុចគោលនៃយុត្តិធម៌ដែលពាក់ព័ន្ធនឹងជនរងគ្រោះជាកុមារ និងសាក្សីនៃឧក្រិដ្ឋកម្មមាត្រាទី៦ នៃសេចក្តីថ្លែងការណ៍ទីក្រុងណៃរ៉ូប៊ី លើសិទ្ធិស្ត្រី និងកុមារក្នុងការទទួលបានសំណងនិងគោលការណ៍ទី៣១ នៃបណ្តុំគោលការណ៍ ស្តីពីការការពារ និងលើកតម្កើងសិទ្ធមនុស្សតាមរយៈសកម្មភាពលុបបំបាត់នូវនិទណ្ឌភាព។ (ធ្វើបច្ចុប្បន្នភាព ឆ្នាំ២០០៥)

## ចំពោះគណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រី (CEDAW)

៥៤. នៅក្នុងការផ្តោតលើអនុសាសន៍ទូទៅ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រីស្តីពីសិទ្ធិស្ត្រីក្នុងស្ថានភាពជម្លោះប្រដាប់អាវុធត្រូវទទូចអោយគណៈកម្មាធិការនៃអនុសញ្ញានេះ ស្នើសុំជាពិសេសដល់ប្រទេសជាសមាជិកក្នុងការរាយការណ៍ទៅលើការអនុម័ត និងអនុវត្តផែនការសកម្មភាពជាតិរបស់ខ្លួននូវសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ ១៣២៥/១៨២០ ដោយបង្កើតនូវចំណងទាក់ទងរវាងផែនការសកម្មភាពជាតិ និងកាតព្វកិច្ច អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រីរបស់ប្រទេសទាំងនេះ។

## ចំពោះម្ចាស់ជំនួយអន្តរជាតិ

៥៥. គាំទ្រកម្មវិធីពង្រឹងការផ្តល់អំណាចដល់ស្ត្រី និងវិធានការធនធាន ដើម្បីគាំទ្រការសងសំណង និងបដិទានសម្រាប់ហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ ដោយរួមទាំងការផ្តល់ជាការអប់រំ សេវាកម្មសុខភាពបន្តពូជ សេវាកម្មគាំទ្រចិត្តសង្គម ការទទួលបានការបណ្តុះបណ្តាល និងមីក្រូហិរញ្ញវត្ថុ និងវិធានការផ្សេងទៀត ដើម្បីធានានូវជីវិតប្រកបដោយភាពថ្លៃថ្នូរចំពោះពួកគេ និងកូនៗរបស់ពួកគេ។

៥៦. គាំទ្រលក្ខ័ខ័ណ្ឌចំពោះយន្តការក្នុង និងក្រៅប្រព័ន្ធតុលាការ លើការអនុម័តវិធានការដើម្បីធានាអោយបាននូវការកាត់ទោសលើហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងធ្វើអោយប្រាកដថាយន្តការយុត្តិធម៌អន្តរកាលក្រោយជម្លោះទាំងអស់ជាបញ្ហារួមពិសេសខាងយេនឌ័រ។

## ង. ចំពោះអង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល

៥៧. ត្រួតពិនិត្យការអនុវត្តន៍ កាតព្វកិច្ចសមភាពយេនឌ័ររបស់ប្រទេសនីមួយៗ ដែលតម្រូវអោយមានការយល់ដឹងនូវសារៈសំខាន់នៃសមភាពរបស់ស្ត្រី ដូចជាតាមរយៈការដាក់ស្នើរបាយការណ៍ស្រមោលទៅគណៈកម្មាធិការសន្ធិសញ្ញា សិទ្ធិមនុស្ស និងប្រើប្រាស់និតិវិធីបណ្តឹងបុគ្គល (ជាពិសេសគណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រី និងគណៈកម្មការសិទ្ធិមនុស្ស) ចំពោះប្រទេសដែលបានផ្តល់សច្ចាប័ន ពង្រាងអនុស្សារណៈតាមជម្រើសដែលពាក់ព័ន្ធ ដើម្បីនាំយកការបំពានដែលទាក់ទងនឹងហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះ និងផលប៉ះពាល់របស់វាដែលកំពុងបន្តមកចំពោះមុខគណៈកម្មាធិការសន្ធិសញ្ញាទាំងនេះ។

៥៨. ប្រមូលផ្តុំជាប្រចាំ ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីទាមទារការការពារសិទ្ធិមនុស្ស និងការលើកតម្កើងចំពោះស្ត្រី និងកុមារក្នុង និងបន្ទាប់ពីការមានជម្លោះ។ ដាក់បញ្ចូលអ្នករស់រានមានជីវិតពីហិង្សាផ្លូវភេទ និងភ្ជាប់ទំនាក់ទំនងទៅនឹងបុរសក្នុងការជួយគាំទ្រដល់ការលុបបំបាត់ហិង្សាលើស្ត្រី

៥៩. នៅក្នុងការផ្តោតលើអនុសាសន៍ទូទៅ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រីលើសិទ្ធិស្ត្រីក្នុងស្ថានភាពជម្លោះប្រដាប់អាវុធដាក់ស្នើជារបាយការណ៍ស្រមោលជូនទៅគណៈកម្មាធិការនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រី ស្តីពីសិទ្ធិស្ត្រីក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ និងការអនុវត្តន៍ ផែនការសកម្មភាពជាតិ ១៣២៥/១៨២០ ដែលមានហើយ។

៦០. ប្រឹងប្រែងពង្រឹងអោយកាន់តែខ្លាំងថែមទៀតនូវបណ្តាញអង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន ដោយភ្ជាប់ទៅនឹងអង្គការអន្តរជាតិឃ្លាំមើលសកម្មភាពសិទ្ធិស្ត្រីប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (IWRAW-AP) ដើម្បីលើកកម្ពស់ការយល់ដឹងពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមាន

ជម្លោះ និងបង្កើនការដាក់សំពាធលើរដ្ឋាភិបាលនៅក្នុងតំបន់ដើម្បីអោយប្រទេសទាំងនេះ អនុវត្ត កាតព្វកិច្ចអន្តរជាតិរបស់ខ្លួនក្នុងការបញ្ចប់និទណ្ឌភាព និងផ្តល់សំណងដល់ជនរងគ្រោះយ៉ាង ប្រាកដ។

៦១. ផ្តួចផ្តើមជម្រុញ និងគាំទ្រគម្រោងផ្តើមគំនិតរបស់អង្គការសង្គមស៊ីវិលក្នុងស្រុក និងក្នុងតំបន់ដើម្បី អភិវឌ្ឍយន្តការយុត្តិធម៌អន្តរកាលក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដូចជាកម្មវិធីស្តាប់សម្លេងស្ត្រីដែល បានផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីហិង្សាផ្លូវភេទ និងយេនឌ័រអំឡុងមានជម្លោះក្នុងការ និយាយរឿងរបស់ពួកគេចូលរួមក្នុងការលុបបំបាត់បុរេវិនិច្ឆ័យក្នុងសង្គម និងវប្បធម៌ដែលនៅបន្ត បន្សល់ស្លាកស្នាមទុយ៌ស និងគម្លាតដល់អ្នករស់រានមានជីវិតព្រមទាំងទទួលស្គាល់ និងសាទរនូវ ភាពក្លាហាន និងរឹងមាំដ៏ធំធេងរបស់ពួកគេ។

# ឧបសម្ព័ន្ធ ឃ៖ ប្រវត្តិរូប

## សមាជិកគណៈវិនិច្ឆ័យ

**អ្នកស្រី អ៊ូរ៉ា ចាវ៉ាតា ខេ ឌីយូស៍** ដោយបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យប្រទេសហ្វីលីពិន ដែលអ្នកស្រី បានចាប់យកអនុបរិញ្ញាប័ត្រ (បរិចារកិច្ចបរទេស) និងការសិក្សាបញ្ចប់ (ការសិក្សាពីអាស៊ី និងហ្វីលីពិន) អ្នកស្រី បច្ចុប្បន្នជាសាស្ត្រាចារ្យ ផ្នែកទំនាក់ទំនងអន្តរជាតិ អភិបាលកិច្ចជាសកល និងការសិក្សាពីអន្តោប្រវេសន៍នៅ មហាវិទ្យាល័យ មើរីយៀម ប្រទេសហ្វីលីពិន ទន្ទឹមនឹងនេះដែរ អ្នកស្រីស្ថិតក្នុងតំណែងជាប្រធានប្រតិបត្តិនៃ វិទ្យាស្ថានស្ត្រី និងយេនឌ័រ (WAGI)។ សាស្ត្រាចារ្យ ខេ ឌីយូស៍ ក៏ធ្លាប់ជាប្រធាន កាឡាយ៉ាន ដែលជាអង្គការគាំទ្រ ស្ត្រីមួយជាប្រធានសម្ព័ន្ធគណៈកម្មការតំបន់អាស៊ីប៉ាស៊ីហ្វិក និងអន្តរជាតិប្រឆាំងការជួញដូរស្ត្រី និងជាប្រធានដំបូង បង្អស់ក្នុងចំណោមអ្នកផ្សេងទៀតរបស់សមាគមន៍ការសិក្សាអំពីស្ត្រីប្រទេសហ្វីលីពិន។ បច្ចុប្បន្ន អ្នកស្រីជាអ្នកសង្កេត ការណ៍លើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងលើស្ត្រី (CEDAW-WATCH) ក្នុងប្រទេសហ្វីលីពិន។

នៅឆ្នាំ ១៩៩៤ អ្នកស្រីត្រូវបានតែងតាំងជាអ្នកតំណាង នៃគណៈកម្មការជាតិសំម្រាប់តួនាទីរបស់ស្ត្រីហ្វីលីពិន (NCRFW) ហើយក៏ត្រូវបានជ្រើសរើសជាប្រធាន ចាប់ពីឆ្នាំ ២០០១ ដល់ ២០០៤។ នៅក្នុងតំណែងជាគណៈកម្មការ និងប្រធាននៃគណៈកម្មការជាតិលើតួនាទីរបស់ស្ត្រីហ្វីលីពិន (NCRFW) អ្នកស្រីបានចូលរួមជាតំណាងប្រទេស ហ្វីលីពិន នៅសន្និសិទស្តីពីស្ត្រីមួយនៅទីក្រុងប៉េកាំង សន្និសិទនៅវីយ៉េន ស្តីពីសិទ្ធិមនុស្ស ព្រមទាំងសន្និសិតប្រចាំ ឆ្នាំស្តីពីឋានៈស្ត្រី ក្នុងសន្និសិទទីក្រុងញូយ៉ក។ ចាប់ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៨ អ្នកស្រីមានតួនាទីជាអ្នកជំនាញ និង តំណាងពិសេសនៅក្នុងគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ហើយក្នុងខែ មករា ឆ្នាំ ២០១១ អ្នកស្រីត្រូវបានតែងតាំងជាអ្នកតំណាងប្រទេសហ្វីលីពិនសម្រាប់ គណៈ កម្មការអាស៊ានស្តីពីការលើកតម្កើង និងការការពារស្ត្រី និងកុមារ។ សាស្ត្រាចារ្យ ខេ ឌីយូស៍ ក៏ជាសមាជិក ក្រុមព្រះ រាជអាជ្ញាក្នុងសាលាក្តីរបស់ស្ត្រីនាឆ្នាំ ២០០០ ទៅលើការបង្កើតអោយមានទាសករផ្លូវភេទដោយទាហាន ជប៉ុន ជាតុលារ ការប្រជាជនដែលផ្តើមដោយអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើឡើងនៅទីក្រុង តូក្យូ ឆ្នាំ ២០០០ ដែលចោទប្រកាន់ អធិរាជជប៉ុនថាជាឧក្រិដ្ឋជនសង្គ្រាម។

**កញ្ញា លី វិជ្ជតា** បានទទួលសញ្ញាប័ត្រច្បាប់ និងអនុបណ្ឌិតគីមីវិទ្យាពីប្រទេសកាណាដា។ កញ្ញាបានចូល រួមកម្មវិធី Chevening Fellowship Porgramme របស់ស្ថានទូតអង់គ្លេស នៃមហាវិទ្យាល័យ ទីក្រុងឡុង ចក្រភព អង់គ្លេស និងទទួលបានវិញ្ញាបនប័ត្រស្តីពីយេនឌ័រ យុត្តិធម៌សង្គម និងភាពជាប្រជាពលរដ្ឋដែលមានជំនាញអំពីការវិភាគ យេនឌ័រ និងការពង្រាងគោលនយោបាយ។ អ្នកស្រីក៏ជានិស្សិតថ្នាក់បណ្ឌិតផងដែរ។ កញ្ញា គឺជាស្ថាបនិក និង នាយករបស់អង្គការការគាំទ្រផ្នែកច្បាប់សម្រាប់ស្ត្រី និងកុមារនៅកម្ពុជា (LSCW)។ អង្គការនេះ គឺជាអង្គការមិនរក កម្រៃ និងមិនពាក់ព័ន្ធនឹងនយោបាយដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០២ ដែលមានគោលការណ៍ចម្បងគឺចូលរួម ក្នុងការអភិវឌ្ឍន៍និតិរដ្ឋ ជម្រុញការស្វែងរកយុត្តិធម៌ និងការពារសិទ្ធិមនុស្សដោយរួមបញ្ចូលទាំងជនចំណាកស្រុក។ កញ្ញាក៏ជាសាស្ត្រាចារ្យក្រៅម៉ោងលើមុខវិជ្ជាការសិក្សាពីយេនឌ័រនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាផងដែរ ហើយ

ក៏ជាអ្នកភ្ជាប់ទំនាក់ទំនងទៅនឹងមជ្ឈមណ្ឌលស្រាវជ្រាវ និងការអភិវឌ្ឍន៍អន្តរជាតិ ប្រទេសកាណាដា ដែលកញ្ញាគឺជាប្រធានក្រុមនៃគម្រោងស្រាវជ្រាវមួយ ស្តីពីយុត្តិធម៌ និងការយល់ឃើញនៃយុត្តិធម៌សម្រាប់ជនជាប់ចោទជាស្ត្រី និងស្ត្រីរងគ្រោះដោយឧក្រិដ្ឋកម្មក្នុងប្រទេសកម្ពុជា។ កញ្ញា លី ក៏បានធ្វើការសិក្សាស្រាវជ្រាវលើគម្រោងជាច្រើន ដែលទាក់ទងនឹងហិង្សាយេនឌ័រក្នុង និងក្រៅប្រទេសកម្ពុជា។ នៅឆ្នាំ ២០០៩ កញ្ញាត្រូវបានអញ្ជើញជាសាក្សីជំនាញនៅតុលាការសម្រាប់ស្ត្រី នៅទីក្រុង បាលី ប្រទេស ឥណ្ឌូនេស៊ី។

**អ្នកស្រី វ៉ាហ៊ីដា ណៃណា** បានធ្វើការទាក់ទងនឹងបញ្ហាសិទ្ធិស្ត្រីនិងសិទ្ធិមនុស្ស រយៈពេល១៨ឆ្នាំមកហើយ។ អ្នកស្រីគឺជា ស្ថាបនិកនិងជានាយកនៃការស្រាវជ្រាវពីស្ត្រី និងក្រុមសកម្មភាព ទីក្រុងម៉ុមបៃ ហើយនៅតែបន្តធ្វើការក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់គ្រប់គ្រងមូលនិធិហិរញ្ញវត្ថុ។ អ្នកស្រីជាអតីត នាយកប្រតិបត្តិរបស់ក្រុមស្ត្រីដើម្បីយុត្តិធម៌យេនឌ័រ ទីក្រុង ញូវយ៉ក ដើម្បីដាក់វិស័យយេនឌ័រចូលទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ អ្នកស្រីមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគំនិតផ្តួចផ្តើមដោយស្ត្រីដើម្បីយុត្តិធម៌យេនឌ័រ ទីក្រុងហេយ្គ និងមូលនិធិសកម្មភាពបន្ទាន់សម្រាប់សិទ្ធិស្ត្រី ប្រទេសអាមេរិក និងកេនយ៉ា និងបណ្តាញសាមគ្គីអន្តរជាតិរបស់ស្ត្រីដែលរស់នៅក្រោមច្បាប់មូស្លីម ទីក្រុងឡុង។ អ្នកស្រីជាជំនួយការសាស្ត្រាចារ្យច្បាប់នៅគ្រឹះស្ថានសិទ្ធិស្ត្រីអន្តរជាតិ គ្រឹះស្ថានច្បាប់ CUNY ទីក្រុងញូវយ៉ក។ អ្នកស្រីជាសមាជិកសកម្មម្នាក់ក្នុងសមាគមន៍ឥណ្ឌានៃការសិក្សាអំពីស្ត្រី។ អ្នកស្រីធ្វើការទាំងក្នុង និងក្រៅប្រទេសលើបញ្ហាទាក់ទងនឹងយុត្តិធម៌ សិទ្ធិមនុស្សយេនឌ័រ និងជម្លោះ។

**សាស្ត្រាចារ្យ ដាយអាណេ អតត្ទូ** គឺជានាយកវិទ្យាស្ថាននីតិអន្តរជាតិ និងមនុស្សសាស្ត្រ (IILAH) នៃគ្រឹះស្ថានច្បាប់ ទីក្រុងមែលប៊ន។ អ្នកស្រី ដាយអាណេ គឺជាអ្នកជំនាញលើបញ្ហាយេនឌ័រក្នុងនិតិអន្តរជាតិ ហើយចំណាប់អារម្មណ៍ ការស្រាវជ្រាវរបស់អ្នកស្រីមានការបញ្ចូលស្ត្រីទៅក្នុងនិតិសិទ្ធិមនុស្សអន្តរជាតិ ដោយលើកឡើងពីហិង្សាផ្លូវភេទអំឡុងប្រតិបត្តិការរក្សាសន្តិភាព ពាក្យស្នើរសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ ១៣២៥ និងការងាររបស់អង្គការក្រៅរដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្ស។ អ្នកស្រីជាសាមាជិកសកម្មម្នាក់នៅក្នុងអង្គការក្រៅរដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្សមួយចំនួនមានអង្គការសកម្មភាពបណ្តាញនៃសិទ្ធិស្ត្រីប្រទេសអូស្ត្រាលី (WRANA) គម្រោងសមភាពសេដ្ឋកិច្ច ស្ត្រីប្រទេសកាណាដា (WEEP) អង្គការអន្តរជាតិឃ្លាំមើលសកម្មភាព សិទ្ធិស្ត្រីប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ប្រទេស ម៉ាឡេស៊ី (IWRAW-AP) មជ្ឈមណ្ឌលសវនាកាស្ត្រីអន្តរជាតិ ទីក្រុងញូវយ៉ក (IWTC)។ អ្នកស្រីបានជួយពង្រាងសេចក្តីអធិប្បាយទូទៅនៃសមភាពស្ត្រី ជូនទៅគណៈកម្មការ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងអនុសាសន៍ទូទៅស្តីពីកាតព្វកិច្ចសិទ្ធិសញ្ញាជូនទៅគណៈកម្មការស្តីពីការបំបាត់ការរើសអើងស្ត្រី។

## គណៈវិនិច្ឆ័យជំនាញ

**អ្នកស្រី ម៉ៃហ្សណាប់ ហាវ៉ា បាងហ្គូរ៉ា** នៃប្រទេសហ្ស៊ីរ៉ាលីអន មានតួនាទីជាតំណាងពិសេសនៃអគ្គលេខាធិកា ស្តីពីហិង្សាផ្លូវភេទអំឡុងមានជម្លោះក្នុងនាមជាអគ្គលេខាធិការរង នៅថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១២។

ក្នុងបន្ទុកនេះ អ្នកស្រីមានឋានៈជាប្រធានបណ្ដាញអន្តរភ្នាក់ងារនៃសកម្មភាពរបស់អង្គការសហប្រជាជាតិប្រឆាំងហិង្សាផ្លូវភេទអំឡុងពេលមានជម្លោះ។ អ្នកស្រី បាងហ្គូរ៉ា មានបទពិសោធន៍លើគោលនយោបាយការទូត និងជាក់ស្តែងលើវិស័យអភិបាលកិច្ច ដំណោះស្រាយជម្លោះ និងផ្សះផ្សារក្នុងប្រទេសអាហ្វ្រិក។ ថ្មីៗនេះ អ្នកស្រីបន្តធ្វើជារដ្ឋមន្ត្រីសុខាភិបាល និងអនាម័យនៃរដ្ឋាភិបាលប្រទេសហ្សាំ៊ាលីអន ហើយក៏ជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាតំណែងស្ត្រីទីពីគត់នៅប្រទេសហ្សាំ៊ាលីអនដែលកាន់តំណែងនេះ។ អ្នកស្រីក៏ជាប្រធានប្រឹក្សា និងជាអ្នកនាំពាក្យជូនប្រធាននាធិបតីលើបញ្ហាទ្វេរភាគី និងអន្តរជាតិ។ អ្នកស្រី បាងហ្គូរ៉ា បានជួយក្នុងការអភិវឌ្ឍន៍កម្មវិធីជាតិស្តីពីសុខភាពអាចទទួលយកបានគាំទ្រការបំបាត់ការកាត់អវៈយវៈភេទ រៀបចំគណៈកម្មកាស្តារសន្តិភាពជាតិ និងជួយសម្របសម្រួលដល់ទំនាក់ទំនងទ្វេរ និងពហុភាគី ជាមួយនឹងសហគមន៍អន្តរជាតិ។ អ្នកស្រីមានបទពិសោធន៍ទូលំទូលាយក្នុងការទំនាក់ទំនងជាមួយភាគីនៃរដ្ឋ និងក្រៅរដ្ឋ ស្តីពីបញ្ហាផ្សេងៗដែលទាក់ទងនឹងហិង្សាផ្លូវភេទរួមទាំងការទាក់ទងជាមួយក្រុមបះបោរទៀតផង។ អ្នកស្រី បាងហ្គូរ៉ា មានបទពិសោធន៍ជាក់ស្តែងអំពីប្រតិបត្តិការរក្សាសន្តិភាពរបស់បេសសកម្មអង្គការសហប្រជាជាតិក្នុងប្រទេស លីបេរីរៀ ដែលនៅទីនោះ អ្នកស្រីរៀបចំផ្នែកជនស៊ីវិលធំបំផុតមួយក្នុងបេសសកម្មនោះ លើកតម្កើងការពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាល និងការផ្សះផ្សារសហគមន៍។ អ្នកស្រីជាអ្នកធ្វើយុទ្ធនាការដែលមានបទពិសោធន៍ ដែលជម្រុញដោយសង្គមស៊ីវិល ដើម្បីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងប្រជាធិបតេយ្យប្រឆាំងនឹងអំពើពុករលួយ និងនិទណ្ឌភាព ដែលគួរកត់សម្គាល់ដោយអ្នកស្រីជាប្រធានប្រតិបត្តិក្រុមទំនួលខុសត្រូវជាតិ ប្រធាន និងសហស្ថាបនិកនៃគណៈបក្សចលនាដើម្បីការរីកចម្រើន នៅប្រទេសហ្សាំ៊ាលីអន ហើយក៏ជាអ្នកសម្របសម្រួល និងសហស្ថាបនិកនៃយុទ្ធនាការដើម្បីអភិបាលកិច្ចល្អ។ អ្នកស្រីបានទទួលពានរង្វាន់ថ្នាក់ជាតិ និងអន្តរជាតិជាច្រើនរួមទាំងរង្វាន់អន្តរជាតិប្រទេសអាហ្វ្រិកស្តីពីគុណសម្បត្តិ ជាអ្នកដឹកនាំ មិត្តភាពដើម្បីប្រជាធិបតេយ្យ រីហ្គិន-ហ្វាសែល ពានរង្វាន់មនុស្សជាតិ បាយ៉ាត រ៉ាស់ទីន ពានរង្វាន់សិទ្ធមនុស្សផ្តល់ដោយគណៈកម្មការមេធាវីដើម្បីសិទ្ធិមនុស្ស ពានរង្វាន់ការចែកចាយទ្រព្យសម្បត្តិជាតិ ដើម្បីប្រជាធិបតេយ្យ និងពានរង្វាន់វិទ្យាស្ថានអាហ្វ្រិក អាមេរិក នៃអតីតនិស្សិតស្រី។

**អ្នកស្រី ម៉ូនីកា ពិនហ្សូន** ជានជនជាតិហ្គោតាមេឡាដែលអរគុណដល់បុព្វជនរបស់អ្នកស្រី សព្វថ្ងៃគឺជាសាស្ត្រាចារ្យមហាវិទ្យាល័យចិត្តវិទ្យា និងការសិក្សាការគាំទ្រស្ត្រី។ អ្នកស្រីក៏ជាអ្នកជំនាញចិត្តសាស្ត្រក្នុងករណីយុត្តិធម៌ជាតិទាក់ទងនឹងស្ត្រីដែលរងគ្រោះដោយហិង្សាផ្លូវភេទក្នុងជម្លោះប្រដាប់អាវុធនៅប្រទេសហ្គោតាមេឡា។

**អ្នកស្រី ពិនហ្សូន** គឺជាក្រុមប្រឹក្សាអ្នកឯកទេសម៉ាយ៉ានៅប្រទេសហ្គោតាមេឡា។ អ្នកស្រីបានលះបង់អស់រយៈពេលច្រើនជាង១២ឆ្នាំ ដោយធ្វើជាអ្នកការពារសិទ្ធិស្ត្រី និងសិទ្ធិជនជាតិភាគតិច។ អ្នកស្រីបានផ្តល់ការគាំទ្រផ្នែកស្មារតីដល់ជនរងគ្រោះដែលរស់រានមានជីវិតពីទារុណកម្មផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ជាមួយ និងគ្រួសាររបស់អ្នកបាត់ខ្លួន និងជាមួយស្ត្រីរងគ្រោះពីហិង្សាផ្លូវភេទក្នុងជម្លោះប្រដាប់អាវុធ និងអ្នកដែលបានជួបនិងរងគ្រោះហិង្សាផ្លូវភេទដែលប្រព្រឹត្តិដោយកងកម្លាំរដ្ឋដោយសារតែកាតព្វកិច្ចការពារស្ថិតក្នុងដៃពួកគេ។

**អ្នកស្រី ស៊ុសាណា សាឃុតូ** ជាប្រធានការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម (WCRO) នៃសាកលវិទ្យាល័យច្បាប់ ទីក្រុង វ៉ាស៊ីតោន (WLC) ដែលលើកតម្កើងការអភិវឌ្ឍន៍ និងការអនុវត្តន៍និតិព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ អ្នកស្រីក៏ចាត់ចែង កម្មវិធីច្បាប់នារដូវក្តៅរបស់ WLC នៅទីក្រុង ហេក ដែលអនុញ្ញាតអោយបណ្ឌិតច្បាប់ និងនិសិត្សអនុបណ្ឌិតមានឱកាសសិក្សានិតិព្រហ្មទណ្ឌអន្តរជាតិ។ លើសពីនេះទៅទៀត អ្នកស្រី សាឃុតូ គឺជាសាស្ត្រាចារ្យជំនាញម្នាក់ ក្នុងវ៉េស៊ីដេន នៅ WLC ដែលនៅទីនោះ អ្នកស្រីបង្រៀនពីប្រធានបទកម្រិតខ្ពស់ដែលទាក់ទងនឹងនិតិព្រហ្មទណ្ឌអន្តរជាតិ ច្បាប់យេនឌ័រនិងសិទ្ធិមនុស្ស និងចម្លើយតបគតិយុត្តអន្តរជាតិ ចំពោះស្ត្រីដែលរងគ្រោះដោយជម្លោះ។ អ្នកស្រីក៏ជាសមាជិកក្រុមប្រឹក្សា មហាវិទ្យាល័យនៅកម្មវិធីនារដូវក្តៅ WLC's academy ស្តីពីសិទ្ធិមនុស្ស និងច្បាប់សិទ្ធិមនុស្សដែលនៅទីនោះ អ្នកស្រីបានបង្រៀនរួមលើមុខវិជ្ជាយុត្តិធម៌អន្តរជាតិនៃការបំពានសិទ្ធិមនុស្ស និងច្បាប់សិទ្ធិមនុស្ស។ មុនពេលចូលរួម WCRO អ្នកស្រី សាឃុតូ ចាត់ចែងកម្មវិធីសេវាកម្មច្បាប់នៅអង្គការពង្រឹងអំណាចស្ត្រីប្រឆាំងនឹងហិង្សា (WEAVE) ជាស្មៀនការិយាល័យព្រះរាជអាជ្ញានៃសវនាការព្រហ្មទណ្ឌអន្តរជាតិរបស់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងធ្វើការនៅមជ្ឈមណ្ឌលសកម្មភាពច្បាប់ដើម្បីសិទ្ធិមនុស្សក្នុងប្រទេសហ្គោតាមេឡា។ អ្នកស្រីក៏ធ្វើជាសហប្រធាននៃក្រុមគោលដៅរួមរបស់ស្ត្រីនៃនិតិអន្តរជាតិ នៃសង្គមអាមេរិកដើម្បីនិតិអន្តរជាតិ (នៅឆ្នាំ ២០០៦ ដល់ ២០០៩) និងត្រូវផ្តល់ពានរង្វាន់រំលឹកប្រចាំឆ្នាំលើកទី២២នៃមជ្ឈមណ្ឌលច្បាប់របស់ស្ត្រី ដ្យ៉ូហ្ស៊ី ប៊ីធី ក្នុងការផ្តល់វិភាគទានយ៉ាងសំខាន់ដល់សិទ្ធិស្ត្រី។



**អ្នកស្រី ស៊ីលគី ស្ទូហ្សិនស្គី** ចាប់ពីឆ្នាំ ២០០៨ អ្នកស្រី ស៊ីលគី ស្ទូហ្សិនស្គី បានធ្វើជាអ្នកតំណាងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ រហូតដល់ឆ្នាំ ២០០៩ អ្នកស្រីគឺជាអ្នកប្រឹក្សាច្បាប់ ជាន់ខ្ពស់ម្នាក់ សំរាប់កម្មវិធីសាលាក្តីខ្មែរក្រហមរបស់អង្គការសិទ្ធិមនុស្សកម្ពុជា អាដហុក ហើយរហូតដល់ខែ កុម្ភៈ ឆ្នាំ ២០១២ អ្នកស្រីកាន់មុខតំណែងដ៏ដែលនេះ នៅក្នុងអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយទៀតឈ្មោះថា អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ ចាប់ពីឆ្នាំ ១៩៩០ អ្នកស្រី ស៊ីលគី ស្ទូហ្សិនស្គី មានតួនាទីជាអ្នកការពារក្តីខាងព្រហ្មទណ្ឌនៅអឺរ៉ុប។ វិស័យការងាររបស់អ្នកស្រីដែលចម្បងជាងគេគឺ ពង្រឹងសិទ្ធិជនរងគ្រោះហិង្សាផ្លូវភេទ រំលោភបំពានផ្លូវភេទ ការជួញដូរ និងជនរងគ្រោះដោយការរើសអើងជាតិសាសន៍ទាំងក្នុង និងក្រៅបន្ទប់សវនាការ។ អ្នកស្រីមានជំនាញលើផ្នែកនិតិព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស។ អ្នកស្រីបានចូលរួមសមាគមមេធាវីប្រជាធិបតេយ្យ អឺរ៉ុប ក្នុងឆ្នាំ ២០០០ និងបន្តជាអគ្គលេខាធិការ ចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៧។ អ្នកស្រីបានចូលរួម និងរៀបចំបេសសកកម្មសិទ្ធិមនុស្សជាច្រើនដូចជា ការសង្កេតសវនាការ និងគណៈប្រតិភូក្នុងប្រទេស ទួគី អេស្ប៉ាញ ក្រិច អ៊ីស្រាអែល កូរ៉េខាងត្បូង និងកាស្មៀ។ នៅឆ្នាំ២០០៦ អ្នកស្រីត្រូវតែងតាំងជាអ្នកប្រឹក្សានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ទីក្រុងហេក។

## អ្នកសម្របសម្រួល

**អ្នកស្រី ប៉ុក បញ្ញាវិចិត្រ** ទទួលបានបរិញ្ញាប័ត្រអនុបណ្ឌិត ផ្នែកការអភិវឌ្ឍន៍កសិកម្ម និងជនបទ ពីវិទ្យាស្ថានអន្តរជាតិ សិក្សាសង្គម ក្នុងទីក្រុងហេក ប្រទេសហូឡង់។ អ្នកស្រីមានបទពិសោធន៍ច្រើនជាង២០ឆ្នាំ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ និងប្រធានប្រតិបត្តិក្នុងស្ថាប័នអភិវឌ្ឍជាច្រើន ក្នុងប្រទេសកម្ពុជារួម ទាំងដៃគូអភិវឌ្ឍន៍ ភ្នាក់ងារអង្គសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ អ្នកស្រី បញ្ញា មានប្រវត្តិការងារយ៉ាងល្អ ក្នុងការលើកតម្កើងសិទ្ធិស្ត្រី និងសមភាពយេនឌ័រ។

**អ្នកស្រី ខាស៊ូមី ណាកាហ្គាវ៉ា** មកពីប្រទេសជប៉ុន បានមកប្រទេសកម្ពុជា ដើម្បីធ្វើការពង្រឹងសិទ្ធអំណាចស្ត្រី ចាប់តាំងពីឆ្នាំ ១៩៩៧។ ក្នុងឆ្នាំ ២០០៦ អ្នកស្រី ណាកាហ្គាវ៉ា បានធ្វើការសិក្សាដំបូងបង្អស់អំពីហិង្សាយេនឌ័រ អំឡុងពេលខ្មែរក្រហមកាន់អំណាច ដែលមានចំណងជើងថា "ហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម" (ឆ្នាំ២០០៧) សព្វថ្ងៃ អ្នកស្រីជាសាស្ត្រាចារ្យមុខវិជ្ជាសិក្សាយេនឌ័រ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ទីក្រុងភ្នំពេញ។

## អ្នកតំណាងពិសេស

**អ្នកស្រី ថេរ៉ាសា ឌេ ឡាងហ្គីស** ជាបណ្ឌិត ហើយក៏ជាអ្នកប្រឹក្សាឯករាជ្យអន្តរជាតិ ស្តីពីសិទ្ធិស្ត្រីអំឡុងពេលជម្លោះបន្ទាប់ពីជម្លោះ និងការកំណត់អន្តរកាល ប្រកបដោយជំនាញខ្ពស់ លើបទដ្ឋាននិងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ មុនមកប្រទេសកម្ពុជា អ្នកស្រីគឺជានាយករងលើកម្មវិធីក្នុងប្រទេសអាហ្គានីស្ថាន ជាមួយស្ត្រីអង្គការសហប្រជាជាតិ ដោយគាំទ្រទៅលើការប្រឹងប្រែងដ៏មានន័យ ក្នុងការដាក់បញ្ចូលស្ត្រីក្នុងដំណើរឈានទៅរកសន្តិភាព ស្ថេរភាព និងការផ្សះផ្សារ។ ចាប់ពីឆ្នាំ ២០១១មក អ្នកស្រីបានរស់នៅប្រទេសកម្ពុជា ហើយធ្វើការផ្តោតលើវិធានការសមស្រប ដើម្បីលើកបញ្ហាហិង្សាផ្លូវភេទ និងយេនឌ័រ អោយជាផ្នែកមួយនៃភាពរឹករវជាទូទៅដែលប្រព្រឹត្តិដោយរបបខ្មែរក្រហម។ សព្វថ្ងៃនេះ អ្នកស្រីកំពុងរៀបចំគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់អំពីបទពិសោធន៍ស្ត្រីដែលស្ថិតក្រោមរបបខ្មែរក្រហមរួមទាំងការរំលោភសេពសន្ថវៈ និងទម្រង់ផ្សេងទៀតនៃហិង្សាយេនឌ័រ។ អ្នកស្រី ឌេ ឡាងហ្គីស ទទួលបិរញ្ញប័ត្របណ្ឌិតដោយទទួលការហ្វឹកហ្វឺនលំដាប់ខ្ពស់ ស្តីពីដំណើរនៃការនិយាយការពិត និងយុត្តិធម៌ អន្តរកាល និងស្តីពីការចងក្រងឯកសារពីការបំពានសិទ្ធិមនុស្សដោយដកស្រង់ចេញពីជីវិតពិត។ អ្នកស្រីក៏មាននាទីជាសមាជិកនៃអ្នកជំនួយសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ទីក្រុងភ្នំពេញ) និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ (ទីក្រុងភ្នំពេញ)។ អ្នកស្រីក៏បានផ្សព្វផ្សាយយ៉ាងទូលំទូលាយស្តីពីបញ្ហាដែលទាក់ទងនឹងស្ត្រី សន្តិភាព និងស្ថេរភាព។




WOMEN'S HEARING
ON GENDER - BASED VIOLENCE IN CONFLICT





រៀបចំដោយ

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT

ដៃគូរជាមួយ:

TPO
Transcultural Psychosocial Organization
Community Mental Health Programme

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

VSS/ECCC

ឧបត្ថម្ភដោយ:

OPEN SOCIETY FOUNDATIONS
giz
ifa
UNITED NATIONS TRUST FUND TO END VIOLENCE AGAINST WOMEN
UN WOMEN